# ពុទ្ធសាសនា និង វិទ្យាសាស្ត្រ



ទស្សនវិជ្ជា

តក្កវិជ្ជា

វិទ្យាសាស្ត្រ

4.30
5

# ពុទ្ធសាសនា និង វិទ្យាសាស្ត្រ

MARYKNOLL
Date 2004

ក្នុងវិចារណកិច្ច

**សុខ - ស៊ីវ**

និពន្ធទី ៣៨

ការផ្សាយរបស់

00011368
បណ្ណាល័យ ហ៊ុន សែន
HUN SEN LIBRARY
R.U.P.P.
សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

បណ្ណាគារ
យាយតាធម៌
ផ្ទះ ៩៧-៩៨ ផ្សារអូរឫស្សី
ទូរស័ព្ទ 012 731 912

លេខ ៩៥ វិថីយុគន្ធរ ភ្នំពេញ

រក្សាសិទ្ធិ

បោះពុម្ពលើកទី២

ព. ស ២៥១៦ គ. ស. ១៩៧២

# អារម្ភបទ

អត្ថបទក្នុងសៀវភៅនេះ មានភាគខ្លះខ្ញុំសរសេរ ផ្ទុយពីទម្លាប់មតិចាស់ ដែលធ្លាប់សំគាល់ថា ជាសច្ចៈហើយនោះ គ្រាន់តែជាបទពិចារណារាវរករួមគ្នា ជាមួយមិត្តអ្នកអានប៉ុណ្ណោះក្រែងលោមានសច្ចៈថ្មីផ្សេងនៅក្នុងនោះទៀត ។ សូមមិត្ត អ្នកអានកុំអាលទទួលស្គាល់ កុំអាលបដិសេធមុនធ្វើវិចារណកិច្ច ។

ព្រោះថា ជាម្រៅនៃអត្ថបទមួយៗក្នុងទ្រឹស្តីពុទ្ធសាសនាក្តី ទ្រឹស្តីវិទ្យាសាស្ត្រក្តី យើងមិនអាចវាស់បានស្ទាន់ត្រូវនោះឡើយ ជាពិសេសទ្រឹស្តីពុទ្ធសាសនា ដែលកើតឡើងដោយសព្វញ្ញុតញ្ញាណរបស់ព្រះអរហន្តសម្ពុទ្ធនោះ យើងជាបុថុជ្ជនមិនអាចវែកញែកកំណត់ព្រំដែនតាមទម្លាប់ថា ពុទ្ធ-សាសនាដោយឡែក វិទ្យាសាស្ត្រដោយឡែក, ដូចជាកំណត់ថាពុទ្ធសាសនាជាបរលោកវិទ្យា សម្រាប់រៀនទៅស្រុកខ្មោច ជាដើមនោះឡើយ ។

ភ្នំពេញ, ថ្ងៃទី ១កុម្ភៈ ១៩៦៩

**សុខ - ស៊ីច**

# ពុទ្ធសាសនា និង វិទ្យាសាស្ត្រ

អត្ថបទ ក្នុងសៀវភៅនេះមាន៦វគ្គគឺ :

**១- ពុទ្ធសាសនាគឺអ្វី ?**

**២- ពុទ្ធសាសនានៅប្រទេសកម្ពុជា**

**៣- ពុទ្ធសាសនា ជាសាសនារបស់រដ្ឋកម្ពុជា**

**៤- អំពីវិទ្យាសាស្ត្រ**

**៥- អំពីទស្សនវិជ្ជា និងតក្កវិជ្ជា**

**៦- ការថែកញែកពុទ្ធសាសនា និងវិទ្យាសាស្ត្រ ៗ**

## វគ្គទី១

## ពុទ្ធសាសនា គឺអ្វី ?

អ្នកអានធ្លាប់ដឹងស្រាប់ហើយគឺ «ពាក្យប្រៀនប្រដៅរបស់ព្រះសម្ពុទ្ធ» ពាក្យប្រៀនប្រដៅនោះឯងឈ្មោះថាព្រះធម៌ ប្រែជាច្បាប់, ជាធម្មជាតិ, ថាសភាវៈទ្រទ្រង់លោក ។ល។ មិនមែន ជាសរណវត្ថុ សម្រាប់បន់ស្រន់ ដូចសាសនាដទៃឡើយ ។

ដែលប្រែថាច្បាប់គឺពុទ្ធសាសនា ជាទ្រឹស្តីប្រកបដោយនីតិសាស្ត្រ ជាឃ្លាំងនៃក្បួនច្បាប់ប្រចាំពិភពលោក មានមាត្រាចែងពីបទបញ្ញត្តិ និងអនុញ្ញាតប្រកបដោយហេតុផល ត្រឹមត្រូវឥតខ្ចោះសម្រាប់សត្វលោកប្រតិបត្តិតាម បានសុខចំរើន ក្នុងលោកនេះ ក្នុងបរលោក និងព្រះនិព្វាន ។

ឯច្បាប់យុត្តិធម៌របស់រដ្ឋទាំងឡាយក្នុងលោក សុទ្ធតែបានបង្កើតឡើងតាមលំនាំព្រះធម៌នេះឯង, បើបង្កើតឱ្យខុសពីលំនាំព្រះធម៌នេះហើយ

ឈ្មោះថាច្បាប់យុត្តិធម៌មិនបានឡើយ ។

ដែលប្រែថាធម្មជាតិគឺពុទ្ធសាសនា ជាទ្រឹស្តីប្រកបដោយធម្មជាតិសាស្ត្រ ប្រាប់បង្ហាញសេចក្តីពិតរបស់ធម្មជាតិ គឺ មនុស្ស សត្វ ដី ទឹក ភ្លើង ខ្យល់ អាកាស ព្រៃព្រឹក្សា ភ្នំ ទន្លេ សមុទ្រទាំងអស់ដែលកើតមានក្នុងមនុស្សលោកទេវលោកព្រហ្មលោក យមលោក និងក្នុងលោកព្រះអាទិត្យព្រះចន្ទព្រមទាំងផ្កាយទាំងឡាយ ដើម្បីឱ្យសត្វលោកចេះដឹងស្គាល់ ។

ហេតុបច្ច័យកើតរលត់នៃធម្មជាតិនោះៗតាមសភាវៈពិតដែលជាបញ្ហាចាំបាច់បំផុតចំពោះជីវិតរូបកាយជាតិកំណើតរបស់ ខ្លួន និងវត្ថុធាតុនៅជុំវិញខ្លួន ។

ឯពួកវិទ្យាករទាំងឡាយក្នុងលោក មានអ្នកវិទ្យាសាស្ត្រជាដើម សុទ្ធតែបានរិះរកហេតុបច្ច័យនៃធម្មជាតិ បង្កើតវិជ្ជាវត្ថុសិក្សាតាមលំនាំព្រះធម៌នេះឯង, បើមិនត្រិះរិះរាវរកតាមលំនាំព្រះធម៌នេះទេ បង្កើតវិជ្ជាអ្វីមួយក៏មិនកើតដែរ ព្រោះប្រាសចាកហេតុបច្ច័យ ។

ដែលប្រែថា សភាវៈទ្រទ្រង់លោកគឺ ពុទ្ធសាសនាជា ទ្រឹស្តីប្រកបដោយកម្មវិបាកសាស្ត្រ ប្រាប់បង្ហាញអំពើល្អ អាក្រក់បុណ្យបាប គឺប្រាប់សកម្មភាពរបស់សត្វលោក ដែលជាហេតុបច្ច័យនាំអោយបានសុខទុក្ខវិនាសចំរើនក្នុងលោកនេះក្នុងបរលោកនិងក្នុងព្រះនិព្វាន ។

ឯការវិនិច្ឆ័យរកយុត្តិធម៌ និងអយុត្តិធម៌របស់រដ្ឋទាំងឡាយក្នុងលោក សុទ្ធតែយកលំនាំតាមព្រះធម៌នេះឯង, បើមិនយកលំនាំតាមព្រះធម៌នេះទេ, ការវិនិច្ឆ័យរកយុត្តិធម៌និងអយុត្តិធម៌នោះក៏មិនឃើញដែរ ។

រួមឱ្យខ្លី ពុទ្ធសាសនាគឺព្រះធម៌នេះឯង ជាទ្រឹស្តីលោកកើតមានប្រចាំពិភពលោក សម្រាប់ទ្រទ្រង់សត្វលោក បើគ្មានពុទ្ធសាសនាទេ ពិភពលោកក៏គ្មានដែរ ។ ប៉ុន្តែអ្នកពិភពលោក ដែលរស់នៅក្នុងលោកបានដោយសារព្រះធម៌នោះមិនដឹងពុទ្ធសាសនាជាសាសនារបស់ខ្លួនឡើយ ,មានជនពួកខ្លះភាន់ច្រឡំ តាំងខ្លួនជាសត្រូវនឹងពុទ្ធសាសនារបស់ខ្លួននោះទៅវិញ ដោយប្រកាន់យកគ្រិស្តសាសនា ឥស្លាមសាសនា ឬ ព្រហ្មញ្ញសាសនា ដែលជាសាសនាមនុស្សបង្កើតប្រចាំប្រទេសជាតិ ភូមិស្រុកនោះថាជាសាសនារបស់ខ្លួន ឥតដឹងឬស្គាល់ពិតប្រាកដថា សាសនាទាំងនោះ មានមូលហេតុកើតមកពីពុទ្ធសាសនា ដែលជាទ្រឹស្តីលោកនោះឡើយ ។

ទ្រឹស្តីលោក ( Théorie du monde )នេះជាពាក្យថ្មីរបស់ខ្ញុំបង្កើតឡើងសម្រាប់និយាយក្នុងសៀវភៅនេះ អោយមានទំហំអត្ថន័យស្មើនឹងពាក្យថា ពុទ្ធសាសនា ។

ដែលហៅថាទ្រឹស្តីលោកនោះគឺគោលការណ៍លោកដែល ប្រាប់នូវដំណើរទំនងនៃកិច្ចការ ដែលត្រូវប្រព្រឹត្តធ្វើយ៉ាងណា អោយបានស្របតាមសភាវៈពិតរបស់ពិភពលោក អាចដោះស្រាសបញ្ហាលោកបាន គឺអាចកែជាតិ ជរា ព្យាធិ មរណៈឱ្យមាននោះបាន ។

ឯការដែលគ្រាន់តែកែកុនជាតិ ជរា ព្យាធិ មរណៈដោយវិជ្ជាពេទ្យប៉ុណ្ណោះគ្មានវិធីលុបបំបាត់ចោលជាតិជរាព្យាធិមរណៈបាននោះមិនឈ្មោះថាទ្រឹស្តីលោក ( Théorie du monde ) នេះបានឡើយព្រោះដោះស្រាយបញ្ហាលោកមិនទាន់រួច ។

ចំណែកពាហិរសាសនាទាំងអស់និងពួកវិទ្យាករទាំងឡាយមានអ្នកវិទ្យាសាស្ត្រជាដើម មិនអាចស្រាវជ្រាវរាវរកឃើញនូវទ្រឹស្តីលោកឱ្យបានសព្វគ្រប់ តាមសភាវៈពិតឡើយច្រើនតែភាន់ច្រលំប្រកាន់យកសភាវៈមិនពិតរបស់ពិភពលោក ថាជាសភាវៈពិតវិញគ្រាន់តែរកឃើញសាខានៃសភាវៈពិតខ្លះខាងផ្លូវចិត្តនិងខាងសម្ភារៈបន្តិចបន្តួចប៉ុណ្ណោះ។ដូចពួកពាហិរសាសនិកខ្លះបានរកឃើញឈានសមាបត្តិ ប៉ុន្តែរកមិនឃើញមគ្គផលនិព្វានមិនយូរប៉ុន្មានឈានសមាបត្តិនោះ ត្រូវវិនាសបាត់បង់ទៅវិញ ។ ខាងសម្ភារៈដូចពួកអ្នកវិទ្យាសាស្ត្រជាដើម បានរកឃើញវត្ថុធាតុពិតខ្លះក្នុងលោកយកមកផ្សំគ្នាបង្កើតជាឱសថ- ជាអគ្គិសនី វិទ្យុ វិទ្យុទូរទស្សន៍ និងយានយន្តជាដើម ផលនៃការរកឃើញនោះ គ្រាន់តែផ្តល់ការងាយស្រួលដល់ជីវិតមនុស្សជំពូកខ្លះមួយភ្លែតៗហើយត្រូវវិនាសបាត់បង់ទៅវិញ នៅតែរងទុក្ខវេទនាស្លាប់កើតៗជាប់ជំពាក់ស្មុគស្មាញក្នុងបញ្ហាជីវិតរកដោះស្រាយមិនរួច ។

បណ្តាអ្នកប្រាជ្ញទាំងអស់ក្នុងពិភពលោក មានតែព្រះសម្មាសម្ពុទ្ធទាំងឡាយប៉ុណ្ណោះ ដែលអាចរកឃើញច្បាប់នូវទ្រឹស្តីលោក អាចដោះស្រាយបញ្ហាលោករួច ទើបទ្រឹស្តីលោកនោះឈ្មោះថាពុទ្ធសាសនា អនុលោមទៅតាមឈ្មោះបុគ្គលដែលមានសមត្ថភាពអាចរកឃើញ ។

អាស្រ័យហេតុនេះទើបពុទ្ធសាសនា មិនប្រកាន់យកការសែនព្រេនបួងសួង បន់ស្រន់ ពឹងអ្នកដទៃឱ្យជួយខ្លួន ដូចពាហិរសាសនាជាដើមឡើយ ប្រកាន់យកតែទ្រឹស្តីច្បាប់ជាធំ «ខ្លួនត្រូវទីពឹងខ្លួន, ត្រូវជួយខ្លួនដោយខ្លួនឯង» ព្រោះទ្រឹស្តីលោកបានបញ្ញត្តិដាច់ខាតជាសច្ចៈបែបនេះ ។ ដែលពុទ្ធសាស-

និកខ្លះនៅមានការប្លុងស្លុងបន់ស្រន់នោះ ព្រោះធ្លាប់គោរពតាមលទ្ធិពាហិរ-សាសនា ពីបុរាណកាលមក ។

ត្រង់ចំនុចអាចិកំបាំងនេះ អ្នកអានប្រហែលជាធ្លាប់គិតដល់ទេដឹង? បើមានគិតដល់ដែរខ្ញុំសូមសរសើរ ធានាថាពិតជាត្រូវតាមសភាវៈពិត សមហេតុផលឥតខ្ចោះ ។ បើបែរជាគិតឃើញផ្ទុយពីនេះទៅវិញ មកពីធ្លាប់ឃើញក្បួនច្បាប់សាសនាទាំងឡាយដែលគេបង្រៀនទូទៅគ្រប់វិជ្ជាឋានក្នុងលោកតាមទស្សនៈជនភាគច្រើន ដែលសុទ្ធតែជាពួកពាហិរសាសនា ។ ពួកនេះទោះបីបានស្រាវជ្រាវរកឃើញចំនុចអាចិកំបាំងនេះក៏គេមិនព្រមាត់ដែរ ដើម្បីអោយពាហិរសាសនារបស់គេមានប្រៀបលើពុទ្ធសាសនា ឬក៏អោយស្មើនឹងពុទ្ធសាសនាដែលជាទ្រឹស្តីលោក ។

ចំណែកពុទ្ធសាសនិកខ្លះវិញ កាលបើឃើញអ្នកប្រាជ្ញធំៗក្នុងសាកលលោក ដែលប្រកបដោយមហាអំណាចមានឥទ្ធិពលខាងវិទ្យា-សាស្ត្រគួរឱ្យស្ញប់ស្ញែង គេនាំគ្នា យល់យ៉ាងនេះហើយក៏លែងគិតគូរហើយយល់តាមគេថា ក្បួនច្បាប់ដែលគេនិយាយពីប្រវត្តិសាសនាទាំងឡាយនោះត្រឹមត្រូវហើយគិតតែនាំគ្នាខំរៀនតាមគេទៅដើម្បីឱ្យស្របតាមមតិភាគច្រើននេះម្យ៉ាង ។ ម្យ៉ាងទៀតមកពីមានឧបស័គ្គពាទាំងគំនិតពុទ្ធសាសនិកនោះគឺៈ

១- ធ្លាប់ដឹងថាព្រះធម៌ ដែលជាពុទ្ធសាសនានោះ ព្រះសម្មាសម្ពុទ្ធត្រាស់ដឹងបង្កើតឡើងដោយព្រះអង្គឯងឥតគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ, ដូចជាមេសាសនាដទៃៗដែលគេបង្កើតសាសនាតាមគំនិតខ្លួននោះដែរ ។

២- ធ្លាប់ដឹងថា ព្រះធម៌ដែលជាពុទ្ធសាសនានោះ មានកំណត់-

កាល, ដូចពុទ្ធសាសនាព្រះសមណគោតមបរមគ្រូយើង កំណត់៥ពាន់ឆ្នាំ កាលបើផុតកំណត់ហើយ ត្រូវអស់ពុទ្ធសាសនា ។

៣- ធ្លាប់ដឹងថា ព្រហ្មញ្ញសាសនា កើតមានក្នុងលោកមុនពុទ្ធសាសនា ដូចកាលព្រះសមណគោតមបរមគ្រូយើងបួសហើយទៅសិក្សាធម៌អាថ៌ក្នុងសំណាក់អាឡារតាបស និង ឧទកតាបស ដែលជាមេអ្នកប្រាជ្ញខាងព្រហ្មញ្ញសាសនា ។

ឧបសគ្គទាំង៣នេះឯង ដែលរាំងគំនិតពុទ្ធសាសនិកនោះមិនឱ្យគិតឃើញតាមសភាវៈពិត ថាពុទ្ធសាសនាជាទ្រឹស្ដីលោកជាសាសនាប្រចាំពិភពលោក និងគិតមិនឃើញថាពួកពាហិរសាសនាទាំងអស់ក្នុងលោក កើតអំពីព្រះពុទ្ធសាសនា ។

## ការដោះស្រាយឧបសគ្គទាំង៣

១- ព្រះសម្ពុទ្ធគ្រប់ព្រះអង្គ សុទ្ធតែមានព្រះនាមថា«សម្មាសម្ពុទ្ធ» ដែលប្រែថា «ព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ឥតមានគ្រូអាចារ្យណាប្រដៅព្រះអង្គឡើយ » ។

ត្រង់ន័យនេះ មានពុទ្ធសាសនិកខ្លះយល់ច្រឡំថា ព្រះពុទ្ធទាំងឡាយក្នុងអតីតកាលរាប់ចំនួនមិនអស់ ដែលពាក្យបុរាណថា ព្រះពុទ្ធអម្បាលខ្សាច់ គឺព្រះពុទ្ធដែលកើតឡើងក្នុងលោកហើយបរិនិព្វានទៅជាច្រើនអង្គ ដូចគ្រាប់ខ្សាច់ក្នុងមហាសមុទ្រខ្សាច់នោះ, ព្រះពុទ្ធមួយអង្គៗ សុទ្ធតែចេះដឹងឯងបង្កើតធម៌ ផ្សេងគ្នាតាមប្រាជ្ញាញាណរបស់ព្រះអង្គ ព្រោះឥតមានការចេះ-

ដឹងតាមក្បួនច្បាប់គ្រូអាចារ្យណាឡើយ ។

តាមយោបល់នេះឃើញថា ធម៌គឺពុទ្ធសាសនារបស់ព្រះពុទ្ធគ្រប់ព្រះអង្គមិនដូចគ្នាទេ មានលក្ខណៈផ្សេងៗគ្នាតាមប្រាជ្ញាញាណ របស់ព្រះពុទ្ធមួយអង្គ ៗ ។

ការយល់ខុសបែបនេះ រកមិនឃើញថាពុទ្ធសាសនា ជាទ្រឹស្តីលោក ជាសាសនាប្រចាំពិភពលោកឡើយ ព្រោះជាសាសនាគ្មានឯកភាព ដូចជាពួកសាសនាដទៃៗ ទៀតដែរ ។

តាមសភាវៈពិត ពុទ្ធសាសនា ជាសាសនាមានឯកភាពបំផុតក្នុងលោក ព្រោះជាទ្រឹស្តីលោក ប្រកបដោយសច្ចៈភាវៈក្នុងលោក, ព្រះពុទ្ធទាំងឡាយ គ្រាន់តែមានប្រាជ្ញាញាណ អាចត្រាស់ដឹងនូវព្រះធម៌គឺពុទ្ធសាសនាបានដោយព្រះអង្គឯង ឥតមានគ្រូអាចារ្យណាប្រដៅដឹកនាំព្រះអង្គឱ្យត្រាស់ដឹងបានប៉ុណ្ណោះ ព្រះអង្គមិនមែនជាអ្នកបង្កើតព្រះធម៌តាមគំនិតផ្ទាល់ព្រះអង្គឡើយទោះបីព្រះពុទ្ធអង្គណា ក៏ត្រាស់ដឹងនូវព្រះធម៌តែមួយដូចៗគ្នាទាំងអស់ បើបែរជាត្រាស់ដឹងខុសធម៌គ្នាវិញនោះមិនឈ្មោះថាព្រះពុទ្ធឡើយ។ ព្រោះព្រះធម៌ជាសច្ចវាចា មិនចេះផ្លាស់ប្តូរប្រែប្រួល មិនចេះស្លាប់បាត់បង់សាបសូន្យនិងមិនចេះចាស់គ្រាំគ្រាឡើយ ដូចពុទ្ធភាសិតថា «សច្ចំ វេ អមតា វាចាព្រះធម៌គឺពាក្យពិត ជាពាក្យមិនចេះស្លាប់» សតញ្ច ធម្មោ ន ជរំ ឧបេតិ ធម៌របស់សប្បុរសគឺពុទ្ធសាសនា មិនចេះចាស់គ្រាំគ្រាឡើយ ចេះតែមានជីវិតរស់នៅក្នុងលោកចេះតែថ្មីទាន់សម័យជានិច្ច រកទីដើមកំណើតនិងទីចុងចប់មិនឃើញ ។ កាលបើអ្នកពិភពលោកមានចិត្តគំនិតអាក្រក់ ឃ្លាតពីព្រះ

ធម៌កាន់តែឆ្ងាយ កាន់តែមានចំនួនច្រើនហើយ ជាធម្មតាត្រូវមានព្រះពុទ្ធមួយអង្គមកកើតក្នុងលោក ដើម្បីត្រាស់ដឹងនូវធម៌ដែលនោះប្រកាសផ្សាយក្នុងលោកឡើងវិញ ។

តើនរណា ដែលបង្កើតព្រះធម៌គឺពុទ្ធសាសនាជាទ្រឹស្ដីលោកនេះទុកក្នុងលោកមុខគេបង្អស់ ? បើព្រះពុទ្ធទាំងឡាយគ្រាន់តែត្រាស់ដឹងព្រះធម៌តាមសភាវៈ ពិតប៉ុណ្ណោះ ?

ឆ្លើយៈ ព្រះធម៌គឺពុទ្ធសាសនា ជាទ្រឹស្ដីលោកនេះគ្មាននរណាអាចបង្កើតបានទេ ពិភពលោកកើតមានក្នុងពេលណា ព្រះធម៌គឺពុទ្ធសាសនាជាទ្រឹស្ដីលោកក៏កើតមានក្នុងពេលនោះដែរ ដូចជាប្រទីបកើតឡើងពន្លឺក៏មានឡើង, បើគ្មានពន្លឺទេ ពាក្យថា ប្រទីបក៏គ្មានដែរ ។

ឯដើមកំណើតព្រះធម៌គឺពុទ្ធសាសនា និងដើមកំណើតពិភពលោកនោះសូម្បីពុទ្ធញ្ញាណ ដែលមានអានុភាព ឈ្លាសវៃ បំផុតអាចត្រាស់ដឹងនូវព្រះធម៌គឺទ្រឹស្ដីលោក បានដោយងាយនោះគឺពិចារណារកទីដើមកំណើតនិងទីចុងចប់នៃព្រះធម៌ នៃពិភពលោកមិនឃើញដែរ ។

ត្រង់ចំនុចនេះហើយ ដែលយើងដឹងច្បាស់តាមសភាវៈពិតថា ព្រះធម៌គឺពុទ្ធសាសនានេះឯង ជាសាសនាប្រចាំពិភពលោក សម្រាប់ពិភពលោក របស់ពិភពលោក ព្រោះជាទ្រឹស្ដីលោក មិនមែនជាសាសនាប្រចាំប្រទេសជាតិភូមិស្រុកដូចពាហិរសាសនា ដែលកើតឡើងដោយគំនិតមនុស្សនោះឡើយ ។

ត្រង់ចំនុចដដែលនេះឯង អាចឱ្យយើងដឹងច្បាស់ថែមទៀតថា -

ពាហិរសាសនាទាំងអស់ក្នុងលោក សុទ្ធតែយកព្រះធម៌គឺពុទ្ធសាសនាជាទ្រទ្រង់លោកទៅផ្សំនឹងគំនិតខ្លួន ទើបបង្កើតជាសាសនាបាន, ព្រោះថាបើមិនយកព្រះធម៌ គឺសេចក្ដីល្អប្រកបដោយហេតុផលគ្រប់យ៉ាង ដែលធ្លាប់មានប្រចាំពិភពលោកទៅផ្សំនឹងគំនិតខ្លួនផងទេ អ្នកពិភពលោកមិនជ្រះថ្លាគោរពស្ដាប់តាមឡើយ ទោះបីប្រើអំណាចយ៉ាងណា ក៏ជាការឥតអំពើ ។

ដូចសាសនាថ្មីសម័យថានព្រះចន្ទនេះគឺ សាសនាកុម្មុយនិស្ដដែលធ្លាប់និយាយ លទ្ធិឬមនោគមវិជ្ជាក្រហម និងសាសនាលោកសេរីដែលធ្លាប់និយាយថា លទ្ធិឬមនោគមវិជ្ជាខៀវនោះក៏សុទ្ធតែកើតឡើងដោយព្រះធម៌គឺពុទ្ធសាសនានេះឯង ។ ពួកមេសាសនាមេលទ្ធិទាំងនោះយកព្រះធម៌ពុទ្ធសាសនា គឺសេចក្ដីល្អ ដែលមនុស្សលោកប្រាថ្នាចង់បានទៅផ្សំនឹងគំនិតខ្លួនដែលប្រកបដោយលោភៈ ទោសៈ មោហៈ បង្កើតជាអង្គការ ជាសាសនាខ្លួនឡើង ដើម្បីទាក់ទាញមនុស្សឱ្យភាន់ច្រឡំចូលក្នុងអំណាចក្រខ្លួន ។ ដូចជាគេបង្កើតឱ្យមានអង្គការ ផ្ដល់ជំនួយឱ្យប្រទេស ទ័ល ក្រខ្សត់ខ្សោយ អង្គការមិត្តភាព អង្គការក្រុមកាកបាទក្រហម និងអង្គការសហប្រជាជាតិ ដែលជាអង្គការយុត្តិធម៌ពិភពលោកជាដើម សុទ្ធតែព្រះធម៌ពុទ្ធសាសនាទាំងអស់ ។ ប៉ុន្តែមេសាសនាមេលទ្ធិទាំងនោះ ឥតដឹងថាជាព្រះធម៌ពុទ្ធសាសនា ឥតដឹងខ្លួនជាពុទ្ធសាសនិក ដែលខ្លួនកើតក្នុងលោក ជាសមាជិកពិភពលោកដែរនោះថែមទៀតដោយមោហៈបិទបាំងវង្វេងយល់ខុសថា សេចក្ដីល្អ សុចរិតយុត្តិធម៌ មនុស្សធម៌ សីលធម៌ អារ្យធម៌និង សុជីវធម៌ទាំងអស់ ដែលខ្លួនចេះដឹងនោះគឺចេះដឹងពីបុព្វបុរស ពីគ្រូអាចារ្យពីមែឪ ពីការសិក្សាតាមក្បួនច្បាប់

ដែលមាននៅក្នុងសាលាស្រុកទេសខ្លួន ឥតបានគិតឱ្យវែងឆ្ងាយថាតើក្បួនច្បាប់សេចក្ដីល្អ សុចរិត យុត្តិធម៌ជាដើមដែលគ្រូអាចារ្យម៉ែឪខ្លួនចេះដឹងនោះ កើតពីណាបានពីណាមកឡើយ ។ បើទោះជាបានគិត ក៏មោហៈបាំងគំនិត មិនឱ្យគិតឃើញត្រូវដែរ ។

ឯលទ្ធិសាសនាទាំងនោះ ដែលត្រឡប់ជាមិនបានផលល្អ តាមលំនាំព្រះធម៌ ចំពោះមនុស្សលោកវិញនោះ មកអំពី **មេសាសនាទាំង**នោះ មិនអនុវត្តតាមអង្គការដែលខ្លួនបង្កើត បែរជាដឹកនាំអង្គការឱ្យអនុវត្តតាមគំនិតលោភៈ ទោសៈ មោហៈ របស់ខ្លួនទៅវិញ ។

២- ធ្លាប់ដឹងថា ពុទ្ធសាសនាមានកំណត់កាល ដូចសាសនាព្រះសមណគោតម បរមគ្រូយើងកំណត់ ៥ពាន់ឆ្នាំ លុះគ្រប់ឆ្នាំហើយ ព្រះពុទ្ធសាសនាក៏អស់ដែរ, ពេលនោះពិភពលោកគ្មានពុទ្ធសាសនាទេ ។ បើតាមន័យនេះឃើញថា ពុទ្ធសាសនា មិនមែនជាសាសនាប្រចាំពិភពលោកឡើយ

នោះជាយ៉ាងនេះក៏ដោយ ត្រូវយកពាក្យថា «កំណត់កាល» នោះមកវែកញែកឱ្យឃើញថា កំណត់កាលបែបណា? កំណត់អ្វី?

ពាក្យថា កំណត់កាលនោះគឺកំណត់នីតិកាលព្រះពុទ្ធមួយ អង្គៗ, ព្រះពុទ្ធអង្គខ្លះដែលមានព្រះជន្មវែងរាប់ម៉ឺនឆ្នាំនោះ គ្មានកំណត់កាលទេ ព្រះអង្គបរិនិព្វានហើយ ផុតនីតិកាលត្រឹមនោះ ។ ឯព្រះពុទ្ធដែលមានព្រះជន្មខ្លី ដូចព្រះសមណគោតមបរមគ្រូយើង ទើបមានកំនត់កាលគឺព្រះអង្គបរិនិព្វានហើយនៅមាននីតិកាលបន្ត ៥ពាន់ឆ្នាំទៀត ។

លុះផុតពី ៥ពាន់ឆ្នាំមក ទើបឈ្មោះថាអស់នីតិកាលព្រះពុទ្ធព្រះ-

នាមសមណគោតម គឺអស់ពួកមនុស្សដែលមានសទ្ធាមុតមាំចំពោះព្រះធម៌ពុទ្ធសាសនា, អស់មនុស្សដែលមានវាសនាអាចត្រាស់ដឹងនូវមគ្គផលនិព្វានដែលជាធម៌ថ្នាក់ខ្ពស់ក្នុងទ្រឹស្ដីពុទ្ធសាសនា ។

ឯព្រះធម៌ពុទ្ធសាសនានៅតែមានក្នុងលោកដដែលគឺនៅមានអ្នកបានឈានជាលោកិយ នៅមានមនុស្សប្រកបដោយព្រហ្មវិហារធម៌រវាងមាតាបិតានិងបុត្រជាដើម នៅមានមនុស្សប្រកបដោយសុចរិតធម៌ សង្គ-ហធម៌ លោកបាលធម៌ ចេះជួយសង្គ្រោះមនុស្សសត្វ មានសេចក្ដីអៀនខ្មាសខ្លាចខុសចង់បានត្រូវស្រឡាញ់អំពើល្អ ស្អប់អំពើអាក្រក់ ចេះស្គាល់ខុសត្រូវដែលជាធម៌ថ្នាក់កណ្ដាលនិងថ្នាក់ទាបក្នុងទ្រឹស្ដីពុទ្ធសាសនា មិនមែនគ្រប់៥ពាន់ឆ្នាំហើយអស់ពុទ្ធសាសនា គឺអស់ព្រះធម៌រលីងពីក្នុងលោកនោះឡើយ។ បើអស់ព្រះធម៌ពុទ្ធសាសនារលីងពីក្នុងលោកហើយ សេចក្ដីល្អតែបន្តិចគ្រាន់តែម្ដាយចេះបំបៅដោះកូនតូចនោះក៏គ្មានដែរ ពិភពលោកត្រូវតែសូន្យជាអាកាសទទេ ព្រោះអស់ទ្រឹស្ដីលោកទៅហើយ ។

រឿងកំណត់នីតិកាលរបស់ព្រះពុទ្ធមួយអង្គៗនោះបើប្រៀបឱ្យងាយយល់មិនខុសពីនីតិកាលរបស់រដ្ឋសភា ក្នុងរដ្ឋមួយៗនោះឡើយ, ក្នុងពេលផុតនីតិកាលរបស់រដ្ឋសភាម្ដងៗ ហើយច្បាប់រដ្ឋធម្មនុញ្ញរបស់រដ្ឋស្ថិតនៅជាធរមានដដែលមិនបានសាបសូន្យបាត់ពីរដ្ឋឡើយ គឺពលរដ្ឋនៅតែគោរពតាមច្បាប់រដ្ឋដដែល ឯច្បាប់ពុទ្ធសាសនា គឺព្រះធម៌ក៏ដូចជាច្បាប់រដ្ឋធម្ម-នុញ្ញ នោះដែរ ឥតបាត់បង់ចាកពិភពលោកឡើយ បើពិភពលោកមាននៅដរាបណា, ព្រះធម៌ពុទ្ធសាសនាក៏មាននៅដរាបនោះ ព្រោះជាទ្រឹស្ដីលោក

ជាធម៌ទ្រទ្រង់ពិភពលោក ។

ឧទាហរណ៍ = ក្នុងពេលផុតនីតិកាលព្រះពុទ្ធមួយអង្គៗ ជាយូរអង្វែងរាប់ពាន់ឆ្នាំហើយ ដែលធ្លាប់ហៅថា លង្វែកពុទ្ធសាសនានោះក៏នៅតែមានព្រះធម៌ពុទ្ធសាសនាជានិច្ច ដូចពុទ្ធដីកាក្នុងគម្ពីរទីឃនិកាយថា «ភវិស្សតិ ភិក្ខវេ សោ សមយោ យំ ឥមេសំ មនុស្សានំ ទសវស្សាយុកា បុត្តា ភវិស្សតិ» ។ល។

ម្នាលភិក្ខុទាំងឡាយតទៅខាងមុខ និងមានសម័យដែលគួររបស់មនុស្សទាំងនេះមានអាយុ ១០ឆ្នាំស្លាប់ ពួកកុមារិកាមានអាយុ៥ឆ្នាំ ល្មមឱ្យមានប្តី ។ ពេលនោះមានកើតអន្តរធានយ៉ាងធំហៅថា សត្ថន្តរកប្ប មនុស្សទាំងឡាយត្រូវវិនាសបាត់បង់ជីវិតដោយគ្រឿងសាស្ត្រាវុធ ព្រោះមនុស្សសម័យនោះមិនគោរពព្រះធម៌ មានចិត្តឃោឃៅមានគ្រឿងអាវុធគ្រប់ដៃលែងស្គាល់បងប្អូនម៉ែឪ កាប់គ្នា ៧ថ្ងៃសូន្យ មនុស្សក្នុងលោក ។

ពេលនោះមានមនុស្សខ្លះ ដែលរត់ពួនក្នុងព្រៃភ្នំ,កាលបើដឹងថាគេកាប់គ្នាស្លាប់សូន្យពីភូមិស្រុកហើយក៏លបៗចេញមក រកស្រុកភូមិវិញ បានជួបនឹងអ្នករត់ពួនដូចគ្នាក៏ឱបគ្នាយំ ស្រឡាញ់រាប់អានគ្នាដូចបងប្អូនបង្កើត ហើយជំនុំគ្នាថាពួកមនុស្សដែលវិនាសយ៉ាងនេះ មកតែពីមានចិត្តអាក្រក់គ្មានអាណិតអាសូរគ្នាទៅវិញទៅមក ដូច្នេះ យើងមិនត្រូវកាប់សំលាប់គ្នាព្រោះគេក៏ចង់រស់ យើងក៏ចង់រស់ បើយើងសំលាប់គេគេក៏សំលាប់យើងដែរ, ពួកយើងត្រូវវៀរចាកបាណាតិបាតតមមិនសំលាប់មនុស្សសត្វអស់មួយជីវិត ។

កាលបើពួកមនុស្សទាំងនោះ បាននាំគ្នាគោរពកាន់រក្សាតាម-

ព្រះធម៌ពុទ្ធសាសនាគឺកុសលកម្មបថទី១ នេះគ្រប់គ្នាហើយពិភពលោក ក៏បានសុខចំរើនឡើងវិញ, ពួកកូនរបស់មនុស្សទាំងនោះចំរើនអាយុបាន២០ឆ្នាំទើបស្លាប់ ។ ពួកមនុស្សទាំងឡាយបានឃើញផលល្អរបស់ខ្លួនយ៉ាងនេះក៏មានសេចក្តី ត្រេកអរនាំគ្នាពិនិត្យហេតុផលល្អអាក្រក់តៗទៅទៀត ក៏ឃើញថា ការលួចទ្រព្យគេជាអំពើអាក្រក់, បើយើងលួចគេ គេនឹងលួចយើងវិញ ឬសម្លាប់យើងមិនខាន, ដូច្នេះយើងត្រូវវៀរចាកអទិន្នាទានតមមិនលួចទ្រព្យគេអស់មួយជីវិត ។ កុសលកម្មបថទី២ក៏មានមនុស្សគោរពកាន់រក្សាឡើងទៀត ។ល។ មនុស្សទាំងនេះចេះតែនាំគ្នាពិនិត្យហេតុផលល្អអាក្រក់ ហើយរកឃើញកាន់តមរក្សាយ៉ាងនេះដរាប់ដល់គ្រប់កុសលកម្មបថទាំង១០ ។

កាលពួកមនុស្សនាំគ្នាគោរពរក្សាព្រះធម៌ពុទ្ធសាសនា គឺកុសលកម្មទាំង១០នេះហើយ, ពិភពលោកក៏ចេះតែចំរើនដរាបដល់មនុស្សមានអាយុ ៨ ម៉ឺនឆ្នាំទើបស្លាប់ ។ បន្ទាប់ពីពេលនោះមក ទើបព្រះពុទ្ធព្រះនាមមេត្តេយ្យដែលធ្លាប់ហៅថា(ព្រះសិអារមេត្រី) ព្រះអង្គចុះចាប់បដិសន្ធិក្នុងលោក។ល។

**ព្រះពុទ្ធភាសិតនេះ បញ្ជាក់ឱ្យឃើញច្បាស់ការពិត២យ៉ាង គឺ :**

**ក-** ព្រះធម៌ពុទ្ធសាសនា ពិតជាទ្រឹស្តី លោកជាសាសនាប្រចាំពិភពលោក សម្រាប់ទ្រទ្រង់លោកជានិច្ច ទោះក្នុងសម័យណាក៏ដោយឱ្យតែមានអ្នកគោរពកាន់រក្សាព្រះធម៌ ពិភពលោកត្រូវចំរើន បើមិនមានអ្នកកាន់រក្សាព្រះធម៌ទេ ពិភពលោកត្រូវវិនាស មានភស្តុតាងជាក់ស្តែង ដូចពួកមនុស្សដែលស្លាប់ដោយកើតសត្ថន្តរកប្បនោះ ព្រោះមិនគោរពកាន់រក្សា-

ព្រះធម៌ ។ ឯពួកមនុស្សដែលចំរើនឡើងវិញនោះ ព្រោះពោរពកាន់រក្សា ព្រះធម៌ ។

**ខ**- ព្រះពុទ្ធសាសនាដែលមានកំណត់កាលនោះគឺ កំណត់ចំពោះនីតិកាលរបស់ព្រះពុទ្ធមួយអង្គៗដែលជាបុគ្គលទេ ឯព្រះធម៌គឺពុទ្ធសាសនានៅតែមានក្នុងលោកជានិច្ច ដូចពួកមនុស្សដែលបានរួចខ្លួនពីស្លាប់ក្នុងពេលកើតសត្ថន្តរកប្បនោះជាភស្តុតាងស្រាប់ បើគ្មានព្រះធម៌ពុទ្ធសាសនាក្នុងលោកទេ ពួកមនុស្សទាំងនោះ ក៏នឹករកកុសលកម្មបថ១០ នោះមិនឃើញដែរ ព្រោះពេលនោះ ជាពេលលង្វែកនីតិកាលពុទ្ធសាសនា រាប់ពាន់ឆ្នាំទៅហើយ ។

ឯការកំណត់នីតិកាលព្រះពុទ្ធមួយអង្គៗនោះដូចតទៅនេះតាមទម្លាប់ដែលធ្លាប់ដឹងមកថា កាលបើគ្រប់៥ ពាន់ឆ្នាំហើយព្រះពុទ្ធសាសនាព្រះសមណគោតមបរមគ្រូយើងត្រូវសាបសូន្យបាត់អស់ក្នុងលោកនេះ គឺអស់តែព្រះអរិយបុគ្គល ដែលបានត្រាស់ដឹងនូវបដិវេធធម៌ទេ ដូចព្រះពុទ្ធឃោសាចារ្យលោកបានពន្យល់ក្នុងគម្ពីរសមន្តបាសាទិក អដ្ឋកថាព្រះវិន័យថា :

- ពីពុទ្ធសតវត្សរ៍ទី១ ដល់ទី១០ នៅមានព្រះអរហន្តបដិសម្ភិទាញាណ
- ពីពុទ្ធសតវត្សរ៍ទី១១ ដល់ទី២០ នៅមានព្រះអរហន្ត សុក្ខវិបស្សកៈ
- ពីពុទ្ធសតវត្សរ៍ទី២១ ដល់ទី ៣០ នៅមានព្រះអនាគាមី
- ពីពុទ្ធសតវត្សរ៍ទី ៣០ ដល់ ៤០ នៅមានព្រះសកទា គាមី

- ពីពុទ្ធសតវត្សរ៍ទី៤១ ដល់ទី ៥០ នៅមានព្រះសោតាបន្នៈ ។

ហួសពីពុទ្ធសតវត្សរ៍ទី ៥០ គឺហួសពី៥ពាន់ឆ្នាំទៅ សាបសូន្យអស់អ្នកដែលបានសំរេចមគ្គផលហើយ មិនមែនអស់ព្រះធម៌ពុទ្ធសាសនាពីក្នុងលោកឡើយ ។

ម្យ៉ាងទៀតក្នុងគម្ពីរមនោរថបូរណី អដ្ឋកថាអង្គុត្តរនិកាយដែលនិយាយពីអន្តរធាន៥យ៉ាងរបស់ពុទ្ធសាសនានោះគឺ :

**ក**- បរិយត្តិអន្តរធាន ការសាបសូន្យបរិយត្តិធម៌ គឺគ្មានអ្នកចេះចាំព្រះត្រៃបិដក សម្បី១គាថា ក៏គ្មានមនុស្សចាំស្ទូត្របានដែរ ។ ប៉ុន្តែការយល់ខុសត្រូវល្អ អាក្រក់ តាមលំនាំព្រះធម៌ នៅមានក្នុងចិត្តគំនិតមនុស្ស ។

**ខ**- បដិបត្តិអន្តរធាន ការសាបសូន្យបដិបត្តិធម៌ គឺគ្មានភិក្ខុប្រតិបត្តិតាមសិក្ខាបទក្នុងបាតិមោក្ខ ។

**គ**- បដិវេធអន្តរធាន ការសាបសូន្យបដិវេធធម៌គ្មានអ្នកបានសម្រេចមគ្គផលនិព្វាន ។

**ឃ**- លិង្គអន្តរធាន ការសាបសូន្យភេទសមណៈ គ្មានភិក្ខុ សាមណេរ ។

**ង**- ធាតុអន្តរធាន ការសាបសូន្យអស់ព្រះសារីរិកធាតុ ។ នេះជាការសាបសូន្យ ផុតនីតិកាលព្រះពុទ្ធមួយអង្គៗ ។

ការសាបសូន្យទាំង៥នេះ ឃើញសាបសូន្យអស់តែមនុស្សអ្នកមានសទ្ធាមុតមាំចំពោះពុទ្ធសាសនា អស់ភេទអ្នកបួស អស់ព្រះសារីរិកធាតុនោះ

ទេ ។ ឯព្រះធម៌គឺពុទ្ធសាសនា ឥតខូចបាតបង់សោះឡើយ ស្ថិតនៅមានក្នុង លោកជាធម្មតា គឺនៅមានសុចរិតធម៌ទ្រទ្រង់មនុស្សអោយស្គាល់ខុសត្រូវ ចេះគោរពច្បាប់រដ្ឋចេះកាន់រក្សាច្បាប់ទម្លាប់ប្រពៃណី ចៀសវាងអំពើអាក្រក់ ស្រឡាញ់អំពើល្អ នៅមានសង្គហធម៌ទ្រទ្រង់មនុស្សឱ្យចេះជួយសង្គ្រោះគ្នា រវាងម៉ែ ឪ កូនប្រុសស្រី ញាតិមិត្ត បងប្អូននិងអ្នកកំសត់ទុគ៌ត, នៅមាន ព្រហ្មវិហារធម៌ទ្រទ្រង់មនុស្ស ឱ្យមានមេត្តា **ករុណាមុទិតា** ឧបេក្ខារវាងមាតា បិតា និង បុត្រធីតា ជាដើម គ្រាន់តែមានចំនួនតិចច្រើនប៉ុណ្ណោះ ។

ក្នុងរយៈកាលអស់ភេទ អ្នកបួសជាភិក្ខុសាមណេរនោះតែង មាន អ្នកបួសនិងមានសាសនាផ្សេងៗទៀតជានិច្ចព្រោះថាកាលបើមនុស្សលោក បានជួបប្រទះសេចក្ដីទុក្ខវេទនាហើយ តែងនឹករកសេក្ដីសុខ ស្រេចឃ្លាន សេចក្ដីសុខ ,អ្នកទាំងនោះតែងតែបើជំនឿច្រើនជាងបញ្ញា ជាឱកាសល្អដល់ អ្នកដែលបានចេះដឹង ព្រះធម៌ពុទ្ធសាសនាបន្តិចបន្តួចស្គាល់ហេតុស្គាល់ សេចក្ដីសុខខ្លះនោះក៏បង្កើតជាសាសនាអ្វីមួយឡើង ហើសន្មត់ជាសាសនា របស់គេទៅ ដូចជាសាសនាព្រាហ្មណ៍ជាដើម គេក៏មាននាមថាព្រះគ្រូឬអ្នក សច្ចំ តាបសឥសីទៅ ។ ពួកមនុស្សទាំងឡាយដែលនាំគ្នាគោរពកាន់រក្សាអំពើ ល្អទាំងឡាយតាមឱវាទព្រះគ្រូអ្នកសច្ចំ តាបសឥសីនោះ ឥតដឹងថាខ្លួនបាន គោរពកាន់រក្សា ព្រះធម៌ពុទ្ធសាសនាឡើយ ។

៣- ដែលធ្លាប់ដឹងថា ព្រហ្មសាសនា កើតក្នុងលោកមុនពុទ្ធ សាសនានោះ គឺមុនតែសាសនាព្រះសមណគោតមបរមគ្រូយើងនេះទេ មិន មែនកើតក្នុងលោកមុនពុទ្ធសាសនាឡើយ, ព្រោះពុទ្ធសាសនាកើតមាន-

មានសម្រាប់លោកយូរអង្វែងហើយ មានព្រះពុទ្ធត្រាស់ដឹង ប្រកាសផ្សាយពុទ្ធសាសនា ក្នុងអតីតកាល ច្រើនអនេកអនន្តរាប់មិនអស់ ដូចគ្រាប់ខ្សាច់ក្នុងមហាសមុទ្រខ្សាច់ ។

ឯពួកពាហិរសាសនាទាំងឡាយ ដូចព្រាហ្មណ្ណសាសនាគ្រិស្តសាសនា និង ឥស្លាមសាសនាជាដើមនេះ មិនមែនធ្លាប់កើតមានទៀងទាត់ក្នុងលោកតាំងពីអតីតកាល ដូចពុទ្ធសាសនាដែលជាទ្រីស្តីលោកនោះឡើយ ។ ចួនកាលពួកពាហិរសាសនានោះមានឈ្មោះមានលទ្ធិផ្សេងៗទៅតាមកាលៈទេសៈ និងតាមគំនិតមនុស្ស គ្មានការចាំបាច់ទៀងទាត់ដូចពុទ្ធសាសនាឡើយ ។

ឧទាហរណ៍ក្នុងសម័យនេះ កើតមានពាហិរសាសនាថ្មីពីរទៀតគឺសាសនាកុម្មុនិស្ត ដែលមានអាស្រម គ្រូមហាឥសី នៅមូស្គូនៅប៉េកាំង និងសាសនាលោកសេរីដែលមានអាស្រមគ្រូមហាឥសូរនៅវ៉ាស៊ីតុន ។ ទៅអនាគត លទ្ធិទាំងនេះអស់ពួកមនុស្សរាប់អាន ត្រូវសាបសូន្យ នឹងកើតមានសាសនាថ្មីៗតាមគំនិតមនុស្សរាប់ឈ្មោះមិនអស់ថែមទៀត នេះជាធម្មតាលោក ។

ចំណែកខាងព្រះធម៌ពុទ្ធសាសនា ជាទ្រីស្តីលោកនេះ មានតែមួយនៅជាពុទ្ធសាសនាដដែលគឺនៅតែសច្ចៈសុចរិតយុត្តិធម៌ដដែល, ទោះក្នុងអនាគត ដែលត្រូវមានព្រះពុទ្ធជាអសង្ខេយ្យអង្គកើតឡើងក្នុងលោកនោះ ក៏នៅតែពុទ្ធសាសនាដដែល ទាំងលក្ខណៈព្រះធម៌ ក៏នៅតែដដែលគឺនៅតែព្រះត្រៃបិដកដែលមាន គំនរធម៌ចំនួន ៨ ម៉ឺន៤ពាន់ធម្មក្ខន្ធគត់ ឥតលើសខ្វះ

... SEN LIBRARY

មួយមាត់ ។

ឯឧប្បត្តិនាម របស់ព្រះពុទ្ធគ្រប់ព្រះអង្គជាអសង្ខេយ្យនោះក៏នៅតែ ១០ៗដូចគ្នា « ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ ។ល។ ភគវាតិ » ដូច្នេះឥតខុសគ្នាឡើយព្រោះព្រះធម៌ពុទ្ធសាសនា គឺទ្រឹស្តីលោកនេះជាសុ ធម៌ ព្រះពុទ្ធទាំងឡាយគ្រាន់តែមានសព្វញ្ញុតញ្ញាណ ត្រាស់ដឹងតាមលំន ព្រះធម៌ ដែលព្រះពុទ្ធមុនៗធ្លាប់ត្រាស់ដឹងហើយប៉ុណ្ណោះ ។

# ពុទ្ធសាសនាដែលជាទ្រឹស្តីលោកមានលក្ខណៈ ពិសេស៣យ៉ាងគឺ :

១-វិធីសាស្ត្រ ( Méthodologie )បានដល់ការហាត់រៀនធ្វើពិធី ផ្សេងៗក្នុងពុទ្ធសាសនា មានពិធីនមស្សការព្រះរតនត្រ័យ ពិធីថ្វាយខ្លួនជា ឧបាសកឧបាសិកា ពិធីបំបួសកុលបុត្រ ពិធីប្រើប្រាស់បច្ច័យ៤ ពិធីធ្វើទាន រក្សាសីលចំរើនមេត្តាភាវនានិងពិធីបុណ្យផ្សេងៗមាន មាឃវិសាខបូជា ជាដើម ។ បានជាមានវិធីសាស្ត្រដូច្នេះ ដើម្បីអប់រំពុទ្ធសាសនិកឱ្យមានការ ចាប់អារម្មណ៍នឹករលឹកចំពោះ អភិលក្ខិតសម័យ ក្នុងពុទ្ធសាសនាផងឱ្យមាន របៀបបែបបទល្អ មានសុជីវធម៌ចំពោះការងារផងជាកត្តាមួយអាចបំបាត់ ទម្លាយសំដែងមិនល្អ ឱ្យបានទទួលនូវទម្លាប់ថ្មីដែលល្អ ។

២- និទស្សនៈ (démontration )វិចារណកិច្ចជាគ្រឿងបង្ហាញហេតុ ផលនៃសច្ចៈ មានដល់បុគ្គលាធិដ្ឋានធម៌ និយាយប្រកាសពីផលបុណ្យបាប នរក សួគ៌ ឱ្យឃើញច្បាស់នូវសកម្មភាពរបស់អ្នកធ្វើអំពើល្អបានផលល្អ-

អ្នកធ្វើអាក្រក់បានផលអាក្រក់ ដូចក្នុងទេវទូតសូត្រ និងក្នុងគម្ពីរធម្មបទ វិមានវត្ថុបេតវត្ថុជាដើម។ បានជាមាននិទស្សនៈដូច្នេះ ដើម្បីអប់រំសតិសម្បជញ្ញៈ របស់ពុទ្ធសាសនិក ឱ្យចេះស្រឡាញ់អំពើល្អ ស្អប់ខ្ពើមអំពើអាក្រក់ផង ឱ្យមានសទ្ធាជឿនូវកម្មផលច្បាស់លាស់តាមសភាវៈពិតផង ។

៣- ទស្សនវិជ្ជា ( Philosophie )បានដល់បដិច្ចសមុប្បាទធម៌ និង អរិយសច្ចធម៌ជាដើម សម្រាប់ពុទ្ធសាសនិកសិក្សាពិសោធ ឱ្យមានប្រាជ្ញាញាណជាបញ្ញវន្ត ដឹងស្គាល់ច្បាស់នូវ សភាវៈពិតរបស់លោកធាតុ ដើម្បីសាងជីវិតឱ្យបានសុខសន្តិភាព និង បរមសុខជាអមតៈ ។

ចំណែកខាងពាហិរសាសនា ទាំងអស់ក្នុងលោកដូចព្រហ្មញ្ញសាសនាជាដើម មានតែលក្ខណៈ២យ៉ាងទេ គឺមានតែវិធីសាស្ត្រនិងទស្សនៈ ប៉ុណ្ណោះ ឯវិធីសាស្ត្រ និង និទស្សនៈ របស់ពាហិរសាសនានោះក៏មិនដូចខាងពុទ្ធសាសនាឡើយ ច្រើនតែខ្វះហេតុផល ។

# វគ្គទី២

# ពុទ្ធសាសនានៅប្រទេសកម្ពុជា

ពុទ្ធសាសនាក្នុងនីតិកាលរបស់ ព្រះសមណគោតមបរមគ្រូបានមកប្រតិស្ឋាននៅប្រទេសកម្ពុជា ជាង២៣ សតវត្សរ៍ហើយគិតមកទល់ត្រឹម ព. ស២៥១៣ នេះ ។

ក្នុងរយៈកាលដ៏វែងយ៉ាងនេះ ពុទ្ធសាសនាមិនដែលសាបសូន្យចាកប្រទេសកម្ពុជាឡើយ គ្រាន់តែមានពេលខ្លះចំរើនរុងរឿង ពេលខ្លះមិន-

ស្ទូវចំរើនតាមសម័យទាំង ៥គឺ :

១- សម័យបុរេប្រវត្តិ

២- សម័យនគរភ្នំ

៣- សម័យចេនឡា

៤- សម័យមហានគរ

៥- សម័យបច្ចុប្បន្ន

## ១-សម័យបុរេប្រវត្តិ (សម័យមុនប្រវត្តិសាស្ត្រខ្មែរ)

បណ្តាប្រទេសដែលកាន់ពុទ្ធសាសនា នៅជិតគ្នាសព្វថ្ងៃ គឺប្រទេសខ្មែរ, សៀម លាវ និង ឃួន ទាំង៤ នេះមានតែប្រទេសខ្មែរមួយទេ ដែលបានទទួលគោរពពុទ្ធសាសនា មុនគេបំផុត តាំងពីមុនសម័យ នគរភ្នំ(ហ្វូណន) ជាច្រើនរយ ឆ្នាំ គឺតាំងពីព្រះអរហន្ត ព្រះនាមមោគ្គលីបុត្តតិស្សត្រេរបញ្ជូនសមណទូតមក ។ ព្រោះថានៅអាស៊ីភាគអាគ្នេយ៍ដែលហៅថាផែនដីសុវណ្ណភូមិនេះ ជាភូមិភាគនៅចន្លោះចិន និង ឥណ្ឌា ។ ក្នុងភូមិភាគជាចន្លោះទាំងមូលនេះ មានតែប្រជាជាតិ៣ទេ ដែលជាម្ចាស់ដើមរបស់សុវណ្ណភូមិគឺ ខ្មែរ មន ចាម និង ជ្វាម៉ាឡាយូ មួយទៀត ស្ថិតនៅលើទីប្រជុំកោះ ។

ឯភូមា, សៀម លាវ និង ឃួនជាដើមនោះ មិនទាន់កើតមានពូជជាតិក្នុងលោក នៅលើទឹកដីសុវណ្ណភូមិ អាស៊ីភាគអាគ្នេយ៍នៅឡើយ ។

ក្នុងគម្ពីរបឋមសាមន្តប្បាសាទិកា គម្ពីរមហាវង្សដែលផ្សាយចេញពីប្រភពកោះសីរីលង្កានោះ ប្រាប់ថាក្នុង ព. ស២៣៤ គឺក្នុងពុទ្ធសតវត្សរ៍ទី៣ (មុនគ. ស៣០៩ឆ្នាំ) ក្រោយពេល ធ្វើតតិយ សង្គាយនា ក្រោមព្រះ-

រាជ្យបត្តម្ភនៃព្រះបាទធម្មាសោកនាមតធរដ្ឋហើយ ព្រះអរហន្តព្រះនាម មោគ្គ-លីបុត្តតិស្សត្ថេរបានបញ្ជូនព្រះសោណត្ថេរ និងព្រះឧត្តរត្ថេរ មកកាន់សុវណ្ណភូមិ (អាស៊ីភាគអគ្នេយ៍ ) យើងនេះ ។ ប៉ុន្តែក្នុងគម្ពីរនេះ មិនបានប្រាប់ឱ្យច្បាស់ថា ក្នុងសម័យដែលពុទ្ធសាសនា ចូលមកប្រទេសខ្មែរជាដំបូងបំផុតនោះក្នុងរជ្ជកាលណា រាជធានីខ្មែរតាំងនៅកន្លែងណាទេ ព្រោះជាសម័យបុរេប្រវត្តិ មុនប្រវត្តិសាស្ត្រខ្មែរយើង ។

បើតាមការស្រាវជ្រាវ របស់អ្នកប្រាជ្ញប្រវត្តិសាស្ត្រ អ្នកប្រាជ្ញសិលាចារឹកទាំងឡាយ ដែលព្រះភិក្ខុ ប៉ាង-ខាត់ អ្នកប្រាជ្ញសិលាចារឹកខ្មែរ បាននាំមកបកប្រែផ្សាយនៅប្រទេសកម្ពុជា មានសរសេរផ្សាយតាមសៀវភៅ ពុទ្ធ-សាសនា ២៥០០ ជាដើមនោះថា «តាមសិលាចារឹកពុទ្ធសាសនាសំស្ក្រឹត នៅ-កាញ់ (ខេត្តញ៉ាត្រាង អតីតកម្ពុជា ) ដែលមានចំណាស់បរមបុរាណជាងគេបង្អស់ នៅលើទឹកដីអាស៊ីភាគអាគ្នេយ៍នោះ អាចឱ្យដឹងបានថា ពុទ្ធសាសនាមកដល់ប្រទេសនគរភ្នំ (ចិនហៅហ្វូណន) មុនជាងគេបង្អស់ក្នុងអាស៊ីភាគអាគ្នេយ៍យើងនេះ ។ តាមប្រភពឯកសារកោះសិរីលង្កា និង សិលាចារឹក តែពីរប៉ុណ្ណោះ យើងអាចសំរេចបានថា ពុទ្ធសាសនា បានចូលមកប្រទេសខ្មែរ មុនសម័យនគរភ្នំ គឺមុនរជ្ជកាល ព្រះបាទហ៊ុនទៀន ព្រះនាងលីវ-យី ជាង៣០០ ឆ្នាំ (មុនសម័យ ប្រវត្តិសាស្ត្រខ្មែរជាង ៣០០ឆ្នាំ ) ។

សូមបញ្ជាក់ថា ត្រង់គម្ពីរសមន្តប្បាសាទិការដែលថាព្រះ សោណត្ថេរនិងព្រះឧត្តរត្ថេរមកសុវណ្ណភូមិ, . . . ហើយត្រង់ពាហិរនិទាននៃគម្ពីរដដែលនេះថា លោកនិមន្តទៅកាន់កោះនោះគឺកោះគោកធ្លក របស់ខ្មែរក្នុង-

សម័យនោះឯង ។

## ២- សម័យនគរភ្នំ
## ពីពុទ្ធសតវត្សរ៍ទី៦
## ដល់ទី១១គឺគ្រីស្តសតវត្សរ៍ទី១ដល់ទី៦

( ព. ស ៥៤៣ ដល់ ១០៩៣, គ. ស ១ដល់ ៥៥០ )

ក្នុងសម័យនគរភ្នំ (ហ្វូណន) នេះព្រះពុទ្ធសាសនា ដែលជាប្រភព នៃមនុស្សធម៌ សីលធម៌ និងអារ្យធម៌នោះបានផ្សាយពាសពេញព្រះរាជាណាចក្រនគរភ្នំ យូរណាស់ហើយ ដរាបដល់មានសិលាចារឹក មានព្រះពុទ្ធរូប សំរាប់ពុទ្ធសាសនិក គោរពបូជាស្ទើរគ្រប់ទិសទី ដូចនៅមណ្ឌលកំពង់ផែបុរាណមួយរបស់ខ្មែរយើង ឈ្មោះកំពង់អុក- អែវ (អូ- កែវ ) នៅមាត់សមុទ្រនៃ ប្រទេសនគរភ្នំ ត្រង់ឈូងសមុទ្រសៀមសព្វថ្ងៃ ជាកំពង់សម្រាប់ទាក់ទងខាងពាណិជកម្មក្រៅប្រទេស រវាងអាស៊ីភាគអគ្នេយ៍និងប្រទេសឆ្ងាយៗគឺមានការទាក់ទងនឹងកំពង់ផែនៅមាត់ទន្លេគង្គាប្រទេសឥណ្ឌា កំពង់នៅប្រទេសអ៊ីរ៉ង់ និង កំពង់នៅមាត់ សមុទ្រមេឌីទែរ៉ាណេផង ។ នៅមណ្ឌលអុក- អែវ នេះ គេ បានរកឃើញបុរាណវត្ថុមានអាយុតាំងពីគ្រិស្តសតវត្សទី១ ម្ល៉េះដូចជា ព្រះពុទ្ធរូប រូបអ្នកស្រុក រូបិយវត្ថុជាតិរ៉ូមាំង ជាតិ ឥណ្ឌា និងតួអក្សរព្រាហ្មី ។

ឯសិលាចារឹកនៅវ៉ូ កាញ់ នោះ គេអាចប្រដូចតួអក្សរទៅនឹង-

សិលាចារឹករុទ្ទទាម័ុន នៅគិរនារឬសាតករណិវាសិស្ឋិបុត្រនៅកាន់ហើរក្បែរទន្លេគោទាវ៉ារី និងទន្លេក្រឹស្នានៃប្រទេសឥណ្ឌាទក្ខិណទិសបាន ។

សិលាចារឹកនេះ និយាយពីព្រះរាជាប្រទេសនគរភ្នំ ក្នុងគ្រិស្តសតវត្សរ៍ទី២ព្រះនាមស្រីមារ គឺព្រះបាទហ្វាន់-ម៉ុន ឬ ហ្វាន់-ចេ-ម៉ុន (តាមភាសាចិន) ជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៏ ដែលមានកិត្យានុភាពល្បីល្បាញអស្ចារ្យ ក្នុងអាស៊ីភាគអាគ្នេយ៍ជាមហារាជាធិរាជនៃប្រទេសនគរភ្នំ មានប្រទេសសមន្តរាជ ១០ ចំណុះព្រះអង្គ ។

សេចក្តីបំព្រួញក្នុងសិលាចារឹកនោះថា «ព្រះរាជវង្សស្រីមារបានត្រាស់បង្គាប់ឱ្យចារឹកទុក ដើម្បីជាអនុស្សាវរីយ៍ចំពោះព្រះបាទស្រីមារថារាជត្រកូលគឺបឋមវង្សជ្រះថ្លាចំពោះពុទ្ធសាសនា យល់ច្បាស់នូវគតាគតិដំណើរអន្ទោលស្លាប់កើតនៃសត្វលោកក្នុងវដ្តសង្សារ ទ្រង់ប្រកបដោយមេត្តាករុណាចំពោះសព្វសត្វ ហើយត្រាស់បង្គាប់ឱ្យបរិច្ចាគព្រះរាជទ្រព្យព្រះអង្គធ្វើទាន ទុកជាសាធារណប្រយោជន៍ ទីបំផុតទ្រង់ផ្តាំទុកថា សូមព្រះរាជាសោយរាជ្យជាតំណតទៅអានាគត ឱ្យប្រតិបត្តិតាមព្រះរាជប្រកាសនេះ ដើម្បីប្រយោជន៍ធំ ដល់សត្វលោក»(១) ។

តមកក្នុងពុទ្ធសតវត្សរ៍ទី ១១ គ្រិស្តសតវត្សរ៍ទី៥ ។ តាមពង្សាវតាចិនរាជវង្សត្សីខាងត្បូង ដំណាលថាមានព្រះរាជានគរភ្នំមួយព្រះអង្គព្រះនាម

---

[១] សូមមើលបាលីសិលាចារឹកនិងសេចក្តីប្រែរបស់ព្រះភិក្ខុបាំងខាត់ក្នុងសៀវភៅពុទ្ធសាសនា ២៥០០ ត្រង់ទំព័រ ៤៧

ការចិន -ជូ-ចូ-យេ៉-ប៉ា-ម៉ូ (តាមភាសាចិន) គឺកៅណ្ឌិន្យជ័យវរ័ន្ម (កោណ្ឌញ្ញជ័យវរ័ន្មន) ព្រះរាជាអង្គនេះ កាលដើមកាន់សាសនាព្រាហ្មណ៍ ក្រោយមកទ្រង់កាន់ពុទ្ធសាសនាវិញ ។ ព្រះអង្គបានបញ្ជូនភិក្ខុសាក្យនាគសេន ជាតិឥណ្ឌា ទៅកាន់សំណាក់ព្រះចៅក្រុងចិននាម វូ-ទី យកគ្រឿងដង្វាយទៅថ្វាយក្នុង ព.ស ១០២៧, គ.ស៤៨៤ ។ ភិក្ខុអង្គនេះបានថ្វាយព្រះពរព្រះចៅក្រុងចិន រៀបរាប់ពីស្ថានភាពប្រទេសនគរភ្នំ និងពីពុទ្ធ-សាសនាថា «ក្នុងប្រទេសនគរភ្នំ មានសេចក្ដីចំរើនរុងរឿង ប្រជាជាតិខ្មែរគោរពសាសនាព្រាហ្មណ៍ផង ពុទ្ធសាសនាផង, ឯពុទ្ធសាសនា ចំរើនរុងរឿងណាស់ មានភិក្ខុសាមណេរច្រើនក្រៃលែង ហើយប្រតិបត្តិតាមពុទ្ធវចនៈ ក៏រឹងរឹតតែប្រពៃណាស់ទៀត ។ កាលភិក្ខុសាក្យនាគសេនត្រឡប់មកវិញ ព្រះចៅក្រុងចិនបានសុំផ្ញើដង្វាយមកថ្វាយព្រះចៅនគរភ្នំវិញជាច្រើន ។

ក្នុង ព.ស ១០៤៦, គ.ស ៥០៣ ។ ព្រះបាទកៅណ្ឌិន្យជ័យវរ័ន្មដដែលនេះបានបញ្ជូនរាជទូត ឱ្យយកព្រះពុទ្ធរូបធ្វើពីផ្កាថ្មសមុទ្រ និងវត្ថុដទៃជាច្រើនទៅថ្វាយព្រះចៅក្រុងចិនទៀត នឹងបានបញ្ជូនភិក្ខុជាតិខ្មែរពីរអង្គ គឺភិក្ខុសង្ឃបាល ១ ភិក្ខុមន្ទ្រសេន១ ជាអ្នកប្រាជ្ញចេះព្រះត្រៃបិដក និងចេះបកប្រែភាសាបរទេសច្រើនភាសា ឱ្យទៅប្រែព្រះត្រៃបិដក តាមការសូមនិមន្តឱ្យជួយប្រែ ពីព្រះចៅក្រុងចិននាមវូ (រាជវង្សលាង) ។ ភិក្ខុទាំងពីរអង្គនេះបានទៅជួយប្រែអស់ការ១៦ឆ្នាំ ។ ឯទីដែលធ្វើការបកប្រែធម៌ ក្នុងប្រទេសចិននោះ ឈ្មោះថាការិយាល័យនគរភ្នំ ។

សេចក្ដីប្រែរបស់ព្រះថេរទាំងពីរអង្គនេះ នៅជាប់ព្រះនាមលោក-

ក្នុងព្រះត្រៃបិដកចិនរហូតសព្វថ្ងៃ ។ កាលសម្តេចព្រះនរោត្តមសីហនុយាងទៅប្រទេសចិន ក្នុង គ.ស១៩៥៦ អធិបតី សមាគមពុទ្ធសាសនាចិនបានយកគម្ពីរនោះថ្វាយសម្តេចទុកជាសក្ខីភាពនៃមិត្តភាពខ្មែរ-ចិន ដែលមានអាយុជាង១៥ សតវត្សរ៍មកហើយ ។

# យោបល់អ្នកនិពន្ធ

ដោយយោលទៅតាមឯកសារ- សិលាចារឹកនិងបុរាណវត្ថុទាំងឡាយនោះ ខ្ញុំសូមបញ្ជាក់ថា ប្រជាជាតិខ្មែរយើងកើតមាន ឡើងនៅលើទឹកដីសុវណ្ណភូមិ (អាស៊ីភាគអាគ្នេយ៍)នេះមុនពុទ្ធសតវត្សរ៍ជាច្រើនរយឆ្នាំ បាននាំគ្នាគោរពលោកធាតុគឺដី ទឹកភ្លើង ខ្យល់ ទេព្តា អារក្ខ អ្នកតា ខ្មោចព្រាយនិងឈើព្រៃ ភ្នំទន្លេ សមុទ្រ ។ ក្នុងពេលនេះមិនទាន់មានសំពត់អាវស្លៀកពាក់ត្រឹមត្រូវទេ ដូចជាបុព្វជនដទៃៗក្នុងលោកដែរ ។ កាលនោះខ្មែរប្រើវប្បធម៌ខ្មែរ អារ្យធម៌ខ្មែរ ភាសាខ្មែរសុទ្ធៗ តាមអម្បូរមនខ្មែរ ដែលមានផៅពង្សជាមួយគ្នា ឯវប្បធម៌អារ្យធម៌បរទេស មិនទាន់បានចូលមកលាយឡំឡើយ ដូចបុរាណវត្ថុ ដែលគេរកឃើញនៅសំរោងសែន អន្លង់ផ្តៅ និងម្លូព្រៃ ដែលជាភស្តុតាងនៃវប្បធម៌ខ្មែរ អារ្យធម៌ខ្មែរសុទ្ធៗនោះ ខ្លះធ្វើពីដែកស្ពាន់លង្ហិន ខ្លះធ្វើពីឥដ្ឋឆៅឬដុត ខ្លះធ្វើពីថ្មរលីង ខ្លះធ្វើពីឆ្អឹងសត្វ ដូចផ្លែព្វថៅពន្លាក ញញួរ ខ្មោស កាំបិត អង្រែ ត្រល់ ផ្លែសន្ទូច កណ្តៀវ និងគ្រឿងអលង្ការផ្សេងៗ ដែលមានខ្លះធ្វើខ្យងខ្មៅជាដើម ។ ឃើញថាទឹកដៃសិល្បករខ្មែរ សម័យនោះមានកំរិតខ្ពស់ដែរហើយ ។ បុរាណវត្ថុទាំងនេះអ្នកប្រវត្តិវិទូ

ខ្មែរ និង បរទេស ដែលបានឃើញស្នានថាមានចំណាស់ប្រហែល៣០០ ឬ ២០០ ឆ្នាំមុន គ. ស ប៉ុន្តែ បើតាមការប្រៀបធៀបទៅនឹងប្រវត្តិពុទ្ធសាសនាចូលមកប្រទេសខ្មែរជាដំបូងនោះ បុរាណវត្ថុទាំងនោះត្រូវមានអាយុជាង ៣០០ ឆ្នាំ មុន គ. ស ទើបត្រូវជាង ។ មន្ទាប់ពីនោះមកបានគោរពកាន់សាសនាព្រហ្មណ៍តាមពួកពាណិជ្ជករឥណ្ឌា ហើយបានផ្តើមពង្រីកវប្បធម៌អារ្យធម៌របស់ខ្លួន ឱ្យរីកដុះដាលឡើង ។

បន្ទាប់មកទៀតគឺមុនសម័យនគរភ្នំ៣០០ឆ្នាំ ទទួលគោរពកាន់ពុទ្ធសាសនា ដែលព្រះអរហន្តមោគ្គលីបុត្តតិស្សត្ថេរបញ្ជូនមក ។ ពេលនោះប្រជាជនខ្មែរបានទទួលសេចក្តីចំរើនខាងមនុស្សធម៌ សីលធម៌ និង អារ្យធម៌មានកំរិតកាន់តែខ្ពស់ហើយ ។

មកដល់សម័យនគរភ្នំ ដែលមានស្តេចហ៊ុន ទៀន ព្រះនាង លីវ-យី ជាបឋមក្សត្រ ក្នុងគ្រិស្តសតវត្សរ៍ទី១ នោះប្រជាជនខ្មែរបានទទួលសេចក្តីចំរើនណាស់ទៅហើយមិនមែននៅស្រាតខ្លួនទទេ មានឋានៈជាមនុស្សព្រៃភ្នំនោះឡើយ ព្រោះបានទទួលអារ្យធម៌ ពុទ្ធសាសនាមកច្រើនរយឆ្នាំហើយ មិនដូចក្នុងពង្សាវតារខ្លះដែលនិយាយថា ទាល់តែមកដល់គ្រិស្តសតវត្សរ៍ទី ៥ ទើបមានពុទ្ធសាសនាចូល មកប្រទេសខ្មែរនោះឡើយ ។ បើនិយាយយ៉ាងនេះ ឃើញថាខុសស្រឡះពីសិលាចារឹកនៅ វ៉ូ-កាញ់ និង បុរាណវត្ថុ ដែលគេរកឃើញ នៅមណ្ឌលកំពង់អុក-អែវ (អូ-កែវ) នោះអស់ទៅហើយ ។

ត្រង់ដែលថាក្នុងរជ្ជកាល ស្តេចហ៊ុន ទៀន ព្រះនាង លីវ-យី

ប្រជាជនខ្មែរ ទើបនឹងរៀនស្លៀកសំពត់នោះក៏ផ្ទុយនឹងឯកសារចិនផ្ទុយនឹង សិលាចារឹកដែរ ព្រោះឯកសារចិនដែលលោក ប៉-ប៉េល្លីយោ រកឃើញពីប្រភពចិន ហើយព្រះភិក្ខុ ប៉ាង ខាត់ ប្រែមកជាខ្មែរថា «ខ្មែរយើងបានសាងខ្លួនកើតជាប្រជាជាតិមួយក្នុងពិភពលោក តាំងពីគ្រិស្តសតវត្សរ៍ទី១ » មិនមែនក្នុងគ្រិស្តសតវត្សរ៍ទី១ នោះទើបនឹងរៀនស្លៀកសំពត់ទេ ។ លោកហ្វេរ៉ង់ថា នៅប្រទេសនគរភ្នំនេះមានជនជាតិឥណ្ឌាបាននាំយកវប្បធម៌ខ្លួនមកផ្សាយតាំងពីពុទ្ធសតវត្សរ៍ទី៣ មុនគ. ស ៣០០ឆ្នាំម្ល៉េះ» (គឺពុទ្ធសាសនានេះឯង ) ។ ប្រភពចិនមួយទៀតនិយាយថា «ខ្មែរនិងចិនមានការទាក់ទងគ្នា មុនគ. ស ជាច្រើនរយឆ្នាំ ។ ដល់មកសម័យ សាន់ គួ ចេ រដ្ឋកាលព្រះចៅក្រុងចិននាមវូ ក្នុង គ. ស២២០-២៨០ បានបញ្ជូនទូតកាំងថៃនិងជូ- យីងជាបឋមទូតឱ្យមកកាន់ប្រទេសនគរភ្នំជាផ្លូវការ » ។

ដូច្នេះក្នុងសម័យនគរភ្នំ (ហ្វូណន) នេះឃើញថា ពុទ្ធសាសនាខាងថេរវាទ (ហីនយាន) បានចំរើនរុងរឿង លើទឹកដីខ្មែរសម្បើមណាស់ ដរាបដល់មានបព្វជិតជាមហាអ្នកប្រាជចេះព្រះត្រៃបិដក ចេះបកប្រែភាសាបរទេស ល្បីល្បាញមានកិត្តិស័ព្ទរន្ទឺសុះសាយ ទាល់តែព្រះចៅក្រុងចិនជួយបកប្រែព្រះត្រៃបិដក ទុកស្នាព្រះហស្តនៅដល់សព្វថ្ងៃនេះ

## ៣-**សម័យចេនឡា**

ពីពុទ្ធសតវត្សរ៍ទី ១១ ដល់ទី ១៤ ពីគ្រីស្តសតវត្សរ៍ទី ៦ ដល់ទី ៩

(ព. ស-១០៩៣ ដល់ ១៣៤៥គ. ស ៥៥០ ដល់ ៨០២)

តាមពង្សាវតារចិន (រាជវង្សស្វ៊យ) ថាកាលនោះនៅប្រទេស-

ហុណាន (នគរភ្នំ) កើតការបះបោរ ហើយមានក្សត្រប្រទេសចេនឡានាម ចិត្រសេនា គឺស្តេចភវវរ្ម័នទី១ (ជាតិកម្ពុជា) **ដណ្តើមបានជ័យជំនះ** ឡើងសោយរាជ្យ ។ សម័យនោះអ្នកប្រាជ្ញពង្សាវតារឱ្យឈ្មោះថា សម័យចេនឡា។

ក្នុងសម័យនោះ ពុទ្ធសាសនា**ខាងថេរវាទ** ចំរើនរុងរឿងនៅឡើយ ដល់មកខាងដើមពុទ្ធសតវត្សរ៍ទី១២ **មានពុទ្ធសាសនា** លទ្ធិមហាយាន (អាចរិយវាទ) ចូលមកប្រទេសខ្មែរទៀត ហើយបានចំរើនរុងរឿង ជាងពុទ្ធសាសនាថេរវាទ ។ ទោះបីពុទ្ធសាសនាម**ហាយាន** ដែលជាសាសនាចំណូលថ្មី ជាដំបូងនេះបានចំរើនជាងគេក៏ដោយ ឯនាម៉ឺននឹងពលរដ្ឋជាច្រើននៅតែគោរព**ពុទ្ធសាស**នាថេរវាទ និងសាសនាព្រាហ្មណ៍ដែរ ។

## ៤-សម័យមហានគរ

ពីពុទ្ធសតវត្សរ៍ទី ១៤ ដល់ទី២០ ពីគ្រិស្តសតវត្សរ៍ទី៩ ដល់ទី១៥
(ព. ស ១៣៤៥ ដល់ ១៩៧៥, គ. ស ៨០២ ដល់ ១៤៣២)

សម័យមហានគរនេះ គិតពីត្រឹមរជ្ជកាល ស្តេចជ័យវរ្ម័នទី២ ដល់រជ្ជកាលស្តេចពញាយ៉ាត ដែលព្រះអង្គចាកចេញពីរាជធានីមហានគរទៅគង់នៅទួលបាសាន(ស្រីសន្ធរ) ហើយមកគង់នៅរាជធានីចតុមុខ ភ្នំពេញសព្វថ្ងៃនេះ។

ក្នុងរយៈកាលដ៏វែងនេះ ពុទ្ធសាសនាថេរវាទ (ហីន-យាន) ក្តី ពុទ្ធសាសនាអាចរិយវាទ (មហាយាន) ក្តី សាសនាព្រាហ្មណ៍ក្តី មាននិន្នាការ តាមរជ្ជកាល ដូចតទៅនេះ÷

ក្នុងរជ្ជកាលស្តេចជ័យវរ្ម័នទី២ (ព. ស១៣៤៥ គ. ស ៨០២ ) ព្រះរាជធានីនៅមហេន្ទ្របពិត (ភ្នំគូលែន ) ។ ព្រះរាជាអង្គនេះកាន់-

សាសនាព្រាហ្មណ៍ ឯនាម៉ឺននិងប្រជាពលរដ្ឋភាគច្រើន គោរពពុទ្ធ-សាសនា ។

-ក្នុងរជ្ជកាលស្តេចជ័យវរ្ម័នទី៤ (ព.ស ១៤១២ គ.ស ៨៦៩) ព្រះរាជធានីនៅហរិរាល័យ (ប្រាសាទបាគងតម្បន់រលួសស្រុកស្វូទ្រនិគម ខេត្តសៀមរាបសព្វថ្ងៃ ) ។ ព្រះរាជាអង្គនេះ កាន់សាសនាព្រាហ្មណ៍ ឯនាម៉ឺននិងប្រជាពលរដ្ឋគោរពកាន់ពុទ្ធសាសនា ។

-ក្នុងរជ្ជកាល ស្តេចឥន្ទ្រវរ្ម័នទី១ (ព.ស ១៣២០ គ.ស ៨៧៧ ) ព្រះរាជធានីនៅហរិហរាល័យដែរ។ ព្រះរាជាអង្គនេះ កាន់សាសនាព្រាហ្មណ៍ ឯនាម៉ឺននិងប្រជាពលរដ្ឋកាន់ពុទ្ធសាសនា ។

ក្នុងរជ្ជកាលស្តេចសោវរ្ម័នទី១ (ព.ស ១៤៣២ គ.ស ៨៨៩) ព្រះរាជធានីនៅយសោធរបុរៈ (អង្គរធំ) ។ ព្រះរាជាអង្គនេះ ជាពុទ្ធសាសនិកមួយអង្គដ៏ប្រសើរ ទ្រង់ទទួលស្គាល់ពុទ្ធសាសនាមហាយាន ជាផ្លូវការមុនដំបូងបំផុតក្នុងពង្សាវតារខ្មែរ ឯពុទ្ធសាសនាហីនយាន និងសាសនាព្រាហ្មណ៍មានសិទ្ធិដូចគ្នា ប្រជាពលរដ្ឋគោរពកាន់តាមស្ម័គ្រចិត្ត ។

-ក្នុងរជ្ជកាលស្តេចជ័យវរ្ម័នទី៤ (ព.ស ២៤៧១ គ.ស ៩២៨ ) ព្រះរាជធានីអង្គធំ ក្រោយមកលើកទៅនៅកោះកែ ។ ព្រះរាជាអង្គនេះកាន់សាសនាព្រាហ្មណ៍ ឯនាម៉ឺននិងប្រជាពលរដ្ឋ ភាគច្រើនកាន់ពុទ្ធសាសនា ។

-ក្នុងរជ្ជកាលស្តេចឥន្ទ្រវរ្ម័នទី២ (រាជេន្ទ្រវរ្ម័ន) (ព.ស ១៤៨៧ គ.ស ៩៤៤ ) ព្រះរាជធានីនៅកោះកែ បាន១ឆ្នាំ រើទៅអង្គរធំវិញ ។ ព្រះរាជាអង្គនេះកាន់សាសនាព្រាហ្មណ៍ តែទ្រង់ប្រោសប្រាណចំពោះពុទ្ធ-

សាសនាដែរបានសាងវត្តខាងពុទ្ធសាសនាកាន់តែច្រើនឡើងៗ មកជិតព្រះ-រាជធានី ។ ក្នុងរាជ្យនេះ សេរីភាពខាងសាសនា ទូលំទូលាយណាស់ បាននាំសាសនាព្រាហ្មណ៍ និងពុទ្ធសាសនា ឱ្យមានវិធីការរលាយចូលគ្នា ជាប់រហូតដល់សម័យនេះ ។

- ក្នុងរជ្ជកាល ស្តេចជយវរ្ម័នទី៥ (ព. ស ១៥១១ គ. ស ៩៦៨) ព្រះរាជធានីនៅអង្គរធំ ។ ព្រះរាជាអង្គនេះកាន់ពុទ្ធសាសនាមុតមាំណាស់ អ្នកមិនធ្លាប់ជ្រះថ្លាចំពោះពុទ្ធសាសនាក៏មានសទ្ធាជ្រះថ្លាតាមព្រះអង្គច្រើន។ ព្រះអង្គបានកសាងពុទ្ធរូប១អង្គធំ នៅជិតប្រាសាទបាយ័នគឺព្រះពុទ្ធរូបគោកធ្លក។

- ក្នុងរជ្ជកាល ស្តេចសូរ្យវរ្ម័នទី១ (ព. ស ១៥៤៥ គ. ស ១០០២) ព្រះរាជធានីនៅអង្គរធំ ។ ព្រះរាជាអង្គនេះជាពុទ្ធសាសនិកលទ្ធិមហាយាន តែព្រះអង្គគោរពពុទ្ធសាសនាថេរវាទ និងសាសនាព្រាហ្មណ៍ដែរ មិនឱ្យអ្នកកាន់សាសនាទាំងនេះថ្នាំងថ្នាក់គ្នាឡើយ ។

- ក្នុងរជ្ជកាលស្តេចឧទយាទិត្យាវរ្ម័ន(ព. ស១៥៩២ គ. ស ១០៤៩) ព្រះរាជធានីនៅអង្គរធំ ។ ព្រះរាជាអង្គនេះ មិនសូវយកព្រះទ័យទុកដាក់ខាងសាសនាទេ ព្រោះប្រទេសរវល់តែកើតសង្គ្រាមដល់៤លើក ព្រះអង្គគោរពសាសនាតាមតែព្រះរាជប្រពៃណីមុន ។

- ក្នុងរជ្ជកាល ស្តេចហស៌វរ្ម័ន (ព. ស ១៦២២ គ. ស ១០៧៩ ) ព្រះរាជធានីនៅអង្គរធំ ។ ក្នុងរាជព្រះអង្គនេះក៏មានការរីករវរខាងចម្បាំងតពីរាជ្យមុនមកមិនទាន់ចប់ ព្រឹត្តិការណ៍ខាងសាសនាដូចរាជ្យមុនដែរ ។

- ក្នុងរជ្ជកាល ស្តេចជយវរ្ម័នទី៦ (ព. ស ១៦៣៣ គ. ស ១០៩០)

ព្រះរាជធានីនៅអង្គរធំ ។ ព្រះរាជាអង្គនេះកាន់សាសនាព្រាហ្មណ៍ មុតមាំណាស់ ឯនាម៉ឺន និង ប្រជាពលរដ្ឋកាន់ពុទ្ធសាសនា ។

- ក្នុងរជ្ជកាល ស្ដេចធរណីន្ទ្រវរ្ម័នទី១ (ព. ស ១៦៥២ គ. ស១១០៩) ព្រះរាជធានីនៅអង្គរធំ ។ ព្រះរាជាអង្គនេះប្រកបដោយគតិបណ្ឌិតយុត្តិធម៌គ្រប់ព្រះរាជករណីយកិច្ចខាងសាសនា ព្រះអង្គគោរពគ្រប់សាសនាទាំងអស់ស្មើៗ តាមឋាន ជាព្រះមហាក្សត្រ ។

- ក្នុងរជ្ជកាល ស្ដេចសូរ្យវរ្ម័នទី២ (១៦៥៦ គ. ស ១១១៣ ) ព្រះរាជធានីនៅអង្គរធំ ។ ព្រះអង្គកាន់សាសនា ព្រាហ្មណ៍ផងពុទ្ធសាសនាផង ឯនាម៉ឺន និងប្រជាពលរដ្ឋភាគច្រើន កាន់ពុទ្ធសាសនា ។

- ក្នុងរជ្ជកាល ស្ដេចធរណីន្ទ្រវរ្ម័នទី២ (ព. ស ១៦៩៤ គ. ស១១៥១ ) ព្រះរាជធានីនៅអង្គរធំ ។ តាមសិលាចារឹកនៅប្រាសាទកាព្រហ្មថា ព្រះរាជាអង្គនេះកាន់ពុទ្ធសាសនាមុតមាំណាស់ អគ្គមហេសីរបស់ព្រះអង្គព្រះនាមស្រីជយរាជចូឌាមណី មានព្រះរាជបុត្រា១ព្រះអង្គប្រកបដោយគុណសម្បត្តិគ្រប់ប្រការ ជាមុដរាជកុមារទៅអនាគតគឺព្រះបាទជយវរ្ម័នទី៧

- ក្នុងរជ្ជកាល ស្ដេចជយវរ្ម័នទី៧ (ព. ស ១៧២៤ គ. ស ១១៨១) ព្រះរាជធានីនៅអង្គរធំ ។ ព្រះអង្គមាន កិត្តិនាមល្បីល្បាញបំផុត ក្នុងពង្សាវតារខ្មែរ ជាពុទ្ធសាសនិក ដ៏ឆ្នើម ពុទ្ធចក្រ និងអាណាចក្រ មានសេចក្ដីចំរើនរុងរឿងក្រៃលែង ។ ព្រះអង្គបានសាងប្រាសាទរាជដ្ឋានមាន កំពូលខ្ពស់ត្រដឹមត្រដួចស្ដឹមស្ដែ គឺប្រាសាទបន្ទាយក្ដី ព្រះខ័ន នាគព័ន្ធ បាយ័ន ,-

...ល័យ ហ៊ុន សែន ... HUN SEN LIBRARY

តាព្រហ្ម បន្ទាយឆ្មា និង ប្រាសាទវត្តនគរនៅកំពង់ចាមប្រាសាទតាព្រហ្ម នៅទន្លេបាទី ព្រមទាំងសាងមន្ទីរពេទ្យផ្លូវគមនាគមន៍ធំៗ ចាប់ពីមហានគរទៅប្រទេសសៀម ប្រទេសចម្ប៉ានៅតាមផ្លូវមានសាលាសំណាក់ទាំងអស់ ១២១ សាលា ។ បានសាងព្រះពុទ្ធរូបមាស ប្រាក់ សំរិត ថ្ម និងរូបព្រះយមព្រះកាលតម្កល់គ្រប់ទីកន្លែងក្នុងព្រះរាជាណាចក្រទាំងអស់ចំនួន ពីរម៉ឺនបួនពាន់អង្គ ព្រមទាំងបានបញ្ជូនព្រះរាជបុត្រព្រះនាមតាមលិន្ទះទៅសិក្សាវិជ្ជាពុទ្ធសាសនានៅកោះសីរលង្កា ព្រះរាជបុត្រនេះបានបួសជាភិក្ខុនៅវត្តមហាវិហារ លោកនិមន្តមកប្រទេសកម្ពុជាវិញក្នុង ព. ស ១៧៣៣ ។

ចំនែក ខាងសាសនាព្រហ្មណ៍ ក៏ព្រះអង្គគោរពដែរ មិនសាបសូន្យឡើយ ។ ក្នុងរជ្ជកាលព្រះអង្គ ផ្នែកការសិក្សាឡើងដល់កម្រិតខ្ពស់បំផុត មានសាកលវិទ្យាល័យ មានភូមិសិក្សាខ្ពស់ក្រៃលែង ជាងភូមិសិក្សានៅប្រទេសឥណ្ឌា ក្នុងសម័យនោះ ។ ព្រះនាងឥន្ទ្រទេវី អគ្គជាយាព្រះអង្គ ជាសាសលវិទ្យាធិការិនីនៃសាកលវិទ្យាល័យវត្តជ័យស្រី (ក្នុងមណ្ឌលប្រាសាទព្រះខ័ន) ។ មានព្រះមហាថេរថ្នាក់បណ្ឌិត ១៨អង្គនិងព្រះថេរៈជាសាស្ត្រចារ្យ ២. ៣៨០អង្គ បង្រៀននៅមហាវិទ្យាល័យវត្តរាជវិហារ (ក្នុងមណ្ឌលប្រាសាទតាព្រហ្ម )។

- ក្នុងរជ្ជកាលស្តេចស្រីន្ទ្រវរ្ម័ន (ព. ស ១៨៣៩ គ. ស ១១៩៦) ព្រះរាជធានីនៅអង្គរធំ ។ ព្រះរាជាអង្គនេះទ្រង់ព្រះថ្លាចំពោះពុទ្ធសាសនាណាស់ដែរ បានថ្វាយស្រុកមួយសម្រាប់សតវត្តអារាមឧទ្ទិសចំពោះពុទ្ធសាសនាក្រោយមកទ្រង់ដាក់រាជ្យថ្វាយរាជបុត្រហើយទ្រង់ព្រះផ្នួស ។ ក្នុងរាជ្យព្រះអង្គនេះឯង កើតមានសិលាចារឹកបាលីមុនគេបំផុតក្នុងប្រវត្តិពុទ្ធសាសនាថេរវាទ ។

តពីរជ្ជកាល ស្តេចស្រីន្ទ្រវរ្ម័ននេះមក ប្រទេសកម្ពុជាចុះថយឥទ្ធិពលបន្តិចម្តងៗ ដោយមានចម្បាំងញឹកញាប់មិនដាច់ ។ សិលាចារឹកក្បួនច្បាប់គម្ពីរដីកាទាំងប៉ុន្មាន ដែលមានមកហើយក៏អន្តរធានបាត់បង់ទៅបន្តិចម្តងៗ ដោយសារសង្គ្រាមរហូតមកដល់រជ្ជកាល ស្តេចពញាយ៉ាតពាក់កណ្តាលពុទ្ធសតវត្សរ៍ទី២០ (ព. ស ១៩៧៥ គ. ស ១៤៣១ ) ព្រះអង្គលះបង់រាជធានី មហានគរទៅគង់នៅទួលបាសាន (ស្រីសន្ធរ) ហើយមកតាំងរាជធានីនៅចតុមុខភ្នំពេញ ។

## ៥-សម័យបច្ចុប្បន្ន

ពីពុទ្ធសតវត្សរ៍ទី ២០ដល់២៦ ពិគ្រឹស្តសតវត្សរ៍ទី១៥ ដល់ទី២០
(ព. ស ១៩៧៥ ដល់ ២៥១២ គ. ស ១៤៣១ ដល់ ១៩៦៨)

ក្រោយសម័យមហានគរ ដល់បច្ចុប្បន្ននេះជាង៥សតវត្សរ៍ហើយ មានព្រះមហាក្សត្រសោយរាជ្យចំនួន៤៦ព្រះអង្គ ។ ខាងចុងរយៈកាលដ៏វែងនេះ ពុទ្ធសាសនាថេរវាទ (ហីនយាន) បានប្រតិស្ឋានលើទឹកដីខ្មែរ ស៊ប់មាំមួនឥតប្រែប្រួលឡើយ ។

ឯពុទ្ធសាសនាមហាយាន និង សាសនាព្រាហ្មណ៍ចេះតែសាបសូន្យដោយឯកឯង ដរាបដល់សព្វថ្ងៃនេះបាត់ឈ្មោះបោះសំឡេងសូន្យឈឹង បុរាណដ្ឋានជាទីវត្តអារាមទាំងនោះ ក៏ប្រែក្លាយមកជាទីវត្តអារាមព្រះពុទ្ធសាសនាថេរវាទនៅវិញដូចជាទីវត្តអង្គសិរី ក្រាំងយូវ រលាំងឈូក និង វត្តបាធាយជាដើម ។

ក្នុងបច្ចុប្បន្ននេះ ពុទ្ធសាសនាថេរវាទ ចំរើនរុងរឿងក្រៃលែងដាច់ខាតម្នាក់ឯងឥតមានសាសនាណាប្រណាំងប្រជែងឡើយ ។

ចាប់តាំងពីរជ្ជកាល សម្តេចព្រះហរិរក្សរាមាធិបតីព្រះអង្គឌួង ដែលជាពុទ្ធសាសនិកដ៏ឆ្នើមនោះ ដរាបមកដល់សព្វថ្ងៃ ពុទ្ធសាសនា ចេះតែចំរើនជាប់ជានិច្ច ។

ព្រះរាជាអង្គនេះទ្រង់សព្វព្រះហឫទ័យ ចំពោះការសិក្សាណាស់ ព្រះអង្គជាបណ្ឌិត ជាកវីនិពន្ធ ជាសាកលវិទ្យាធិការព្រះបរមរាជវាំង ឧដុង្គ របស់ព្រះអង្គកើតជាមហាវិទ្យាល័យ ទ្រង់ព្រះរាជទានឱ្យភិក្ខុសាមណេរ ឧបាសកឧបាសិកា យុវជនចូលទៅសិក្សាវិជ្ជាគ្រប់បែប មានវិជ្ជាអក្សរសាស្ត្រខ្មែរ កាព្យសាស្ត្រ និង ទស្សនវិជ្ជាពុទ្ធសាសនាជាដើម ទ្រង់បានបង្រៀនបរិយត្តិធម៌ចំពោះភិក្ខុសាមណេរផ្ទាល់ព្រះអង្គផង ផ្ទៃកុកវីនិពន្ធ បានទុកសាស្ត្រាកាកី ជាស្នាព្រះហស្តដល់សព្វថ្ងៃ ។

បន្ទាប់មកគឺរជ្ជកាល ស្តេចនរោត្តម ព្រះអង្គជាពុទ្ធសាសនិកដ៏ឆ្នើមទៀត បានសាងវិហារព្រះកែវមរកត នៅទិសខាងត្បូង ជាប់ព្រះបរមរាជវាំង ។

បន្ទាប់មកទៀតគឺរជ្ជកាលស្តេចស៊ីសុវត្ថិ ។ ព្រះអង្គជាពុទ្ធសាសនិកដ៏ឆ្នើមទៀត បានសាងព្រះរាជបណ្ណាល័យ មន្ទីរពុទ្ធសាសនបណ្ឌិត្យ និង សាលាបាលីជាន់ខ្ពស់ ។

បន្ទាប់មកទៀតគឺ រជ្ជកាលស្តេចស៊ីវសុវត្ថិ-មុនីវង្ស ។ ព្រះអង្គជាពុទ្ធសាសនិកដ៏ឆ្នើមទៀត ទ្រង់សព្វព្រះរាជហឫទ័យចំពោះព្រះសង្ឃ ឱ្យមានសណ្តាប់ធ្នាប់ត្រឹមត្រូវ តាមវិន័យសិក្ខាព្រះពុទ្ធសាសនា ។ ព្រះអង្គជាពុទ្ធសាសនានូបត្ថម្ភក៏នៃឧត្តមសង្ឃីតិ បង្កើតឱ្យមានក្រុមជុំនុំពិនិត្យផ្ទៀងផ្ទាត់ព្រះត្រៃបិដក ហើយប្រែពីបាលីមកភាសាជាតិឱ្យបោះពុម្ពទាំងបាលីទាំងភាសាជាតិផ្សាយក្នុងប្រទេសកម្ពុជា ។ ឧត្តមសង្ឃីតិនេះគឺចាប់ប្រែជាខ្មែរព្រមទាំងសរសេរចម្លងពីឆ្នាំ ១៩២៩ ដល់ឆ្នាំ ១៩៣៩ចំនួន១០ឆ្នាំ ទើបប្រែនិងសរសេរចំលងជាសំណៅពុម្ពចប់ ការបោះពុម្ពក៏ចេះតែបោះតៗមករហូតដល់ឆ្នាំ១៩៦៩ នេះទើបចប់សព្វគ្រប់បានជាសៀវភៅធំក្រាសៗ ចំនួន ១១០ សៀវភៅលុះបោះពុម្ពចប់សព្វគ្រប់ហើយ បានធ្វើបុណ្យសម្ភោធយ៉ាងធំគ្រប់វត្តអារាមទាំងអស់ ក្នុងព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃតែមួយដំណាលគ្នាក្នុងព.ស២៥១២ គ.ស១៩៦៩ ក្នុងរជ្ជកាលព្រះមហាក្សត្រិយានី ស៊ីសុវត្ថិកុសុមនារីរតន៍ សិរិវឌ្ឍនា ជានិមិត្តរូបនៃរាជបល្ល័ង្កខ្មែរ ដែលមានសម្តេចព្រះនរោត្តមសីហនុជាព្រះប្រមុខរដ្ឋ ។

បន្ទាប់មកទៀតគឺរជ្ជកាល ស្តេចនរោត្តមសីហនុវរ្ម័ន ព្រះអង្គជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភដ៏ឆ្នើមបំផុតបានទ្រង់ព្រះ ផ្នួសក្នុងពុទ្ធសាសនា ទ្រង់សាងប្រទេសកម្ពុជា កើតជាប្រទេសឯករាជ្យអព្យាក្រឹត កោះសន្តិភាពដើម្បីជាគ្រឹះទីតាំងនៅនៃព្រះពុទ្ធសាសនាយ៉ាងមាំ ទ្រង់ប្រទានរដ្ឋធម្មនុញ្ញចំពោះបជាពលរដ្ឋ ដែលក្នុងរដ្ឋធម្មនុញ្ញនោះ បានលើកស្ទួយព្រះពុទ្ធសាសនាទុកជាសាសនារបស់រដ្ឋកម្ពុជាទ្រង់បានដាក់រាជ្យថ្វាយសម្តេច-

ម្រះបរមរាជបិតា និងសម្តេចព្រះបរមរាជជននីនាថ ហើយបង្កើតអង្គការសង្គមរាស្ត្រនិយម ដើម្បីប្រមូលជាតិបម្រើមនោគមវិជ្ជា សង្គមនិយមព្រះពុទ្ធសាសនា ដែលបានស្ថាបនាឡើងដោយព្រះប្រាជ្ញា ញាណរបស់ព្រះអង្គ តាមលំនាំទ្រឹស្តី ពុទ្ធសាសនាទ្រង់បានបង្កើតពុទ្ធិក សាកលវិទ្យាល័យព្រះសីហនុរាជសម្រាប់ព្រះសង្ឃពុទ្ធសាសនិកក្នុងប្រទេស និងក្រៅបទេសសិក្សាវិជ្ជាជាន់ខ្ពស់ ។ ទ្រង់បានឱ្យរុះរើសង់ជាថ្មី តាមសម័យនិយមនូវសាលាបាលីជាន់ខ្ពស់ និងព្រះរាជបណ្ណាល័យ មន្ទីរពុទ្ធសាសនបណ្ឌិតដែលចាស់គ្រាំគ្រាហើយ ។

បន្ទាប់មកទៀត គឺរជ្ជកាលស្តេច នរោត្តមសុរាម្រឹត ព្រះអង្គជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភក៏គ្រប់វិស័យ ពុទ្ធសាសនា បានចំរើនរុងរឿងក្រៃលែងដូចក្នុងរជ្ជកាលស្តេចសីហនុវរ្ម័ន ជាព្រះរាជបុត្រដែរ ព្រះអង្គបានឧបត្ថម្ភលើកតម្កើងសាលាបាលីជាន់ខ្ពស់ ឱ្យមានឋានៈជាពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ។ ជាពិសេសព្រះអង្គសព្វព្រះរាជហឫទ័យធ្វើបុណ្យមួយយ៉ាងធំអស្ចារ្យជាផ្លូវរដ្ឋដែលប្រទេសកម្ពុជាតាំងពីតាំងពីសម័យនគរភ្នំមកមិនធ្លាប់បានធ្វើសោះគឺបុណ្យពុទ្ធសាសនា ២៥០០ និងបុណ្យសម្ពោធព្រះសក្យមុនីចេតិយបញ្ចុះព្រះបរមសារីរិកធាតុនៅមុខស្ថានីយរាជាយស្ម័យយានក្នុងក្រុងភ្នំពេញ

សម័យបច្ចុប្បន្ននេះ គឺរជ្ជកាលសម្តេចព្រះមហាក្សត្រយានីស៊ីសុវត្ថិកុសុមនារីរតន៍ សិរីវឌ្ឍនា ជានិមិត្តរូបនៃរាជបល្លង្កខ្មែរ ។ ព្រះអង្គជាព្រះអគ្គពុទ្ធសាសនូបត្ថម្ភិកាគោរពលើកតម្កើងព្រះពុទ្ធសាសនាគ្រប់វិស័យទាំងអស់ឱ្យបានចំរើនរុងរឿង ដូចក្នុងរជ្ជកាលព្រះរាជបុត្រដែរ ។ ព្រះអង្គបានឱ្យរុះរើ

រង់ជាថ្មី នូវព្រះវិហារព្រះកែវមរកត និងថែរក្សាវិញព្រះវិហារដែលចាស់គ្រាំគ្រាហើយនោះឡើងវិញ ។ ព្រះអង្គជាមហាឧបដ្ឋាយិកាគ្រប់វត្តអារាមទាំងអស់ ជាពិសេសវត្តលង្កាព្រះកុសុមរាមសង្កាត់លេខ៦ក្រុងភ្នំពេញ ដែលជាវត្តព្រះកេរ្តិ៍ពីលោកចៅឃុនប្រយូរវង្សប៉ាត់ជាព្រះរាជអយ្យិកាមក ។ ព្រះអង្គបានឧបត្ថម្ភទំនុកបំរុងមន្ទីរសង្ឃពេទ្យព្រះកុសុមៈ សម្រាប់ព្យាបាលព្រះសង្ឃអាពាធ ។

ឯនាម៉ឺនសព្វមុខមន្ត្រី កវីបណ្ឌិតព្រឹទ្ធាចារ្យប្រជាពលរដ្ឋទាំងអស់ក្នុងរជ្ជកាលព្រះអង្គ សុទ្ធតែជាពុទ្ធសាសនិកមានសទ្ធាជ្រះថ្លាចំពោះពុទ្ធសាសនា រក្សាសីលធ្វើទានចំរើនមេត្តាភាវនាដោយគោរពក្រៃលែង ។

## វគ្គទី៣

## ព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋខ្មែរ

ក្នុងជំពូក២ត្រង់មាត្រា៨ នៃរដ្ឋធម្មនុញ្ញប្រទេស កម្ពុជាបានចែងថា «ព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ» ។

ហេតុអ្វីបានជាក្នុងរដ្ឋធម្មនុញ្ញខ្មែរយើង លើកតម្កើង ពុទ្ធសាសនាទុកក្នុងច្បាប់រដ្ឋ ជាទីគោរពសក្ការៈដូច្នេះ ? តើព្រះពុទ្ធសាសនាមានគុណូបការៈ យ៉ាងណាខ្លះចំពោះប្រទេសកម្ពុជា ?

បញ្ហានេះយើងអាចឆ្លើយបានគ្រប់គ្នា តាមការគិតឃើញរៀងៗខ្លួនឥតទើសទាល់ឡើយ ។ ប៉ុន្តែត្រង់ចំណុចគុណូបការៈយ៉ាងសំខាន់របស់ពុទ្ធសាសនា ដែលមានពិតប្រាកដ ចំពោះប្រទេសកម្ពុជានោះប្រហែលឆ្លើយ-

មិនត្រូវសព្វគ្រប់ទេ ព្រោះត្រង់ចំណុចខ្លះ បើមិនបានគិតឱ្យដិតដល់ហាក់ដូចជាគ្មាន វិស័យពុទ្ធសាសនា ជួយទ្រទ្រង់ផងឡើយ ។

ឯចំណុចសំខាន់ នៃគុណូបការៈព្រះពុទ្ធសាសនា ចំពោះប្រទេសកម្ពុជានោះ បើបំព្រួញឱ្យខ្លីមាន៣គឺ :

១- ព្រះពុទ្ធសាសនា ជាមូលដ្ឋាន ( Base )នៃការចាប់ផ្តើមស្ថាបនជាតិខ្មែរតាំងពីមុនគ្រិស្តសតវត្សរ៍៣០០ឆ្នាំ ដរាបបានកើតជាអារ្យជាតិវិសេសមួយក្នុងលោក ។

២- ព្រះពុទ្ធសាសនា ជាប្រភព (Source ) នៃការរចនាភាសាខ្មែរឱ្យរីកដុះដាល កើតជាភាសាមួយក្នុងលោកប្រកបដោយអង្គ៣ ។

៣- ព្រះពុទ្ធសាសនា ជាធានី ( Capitale )ជាទីជម្រកធំនៃអក្សរសាស្ត្រខ្មែរ ។ ដោយគុណបំណាច់នេះ ទើបអក្សរសាស្ត្រខ្មែរ បានប្រកាសរំលឹកគុណពុទ្ធសាសនានៅខាងដើមក្បួនរបស់ខ្លួនថា«**នមោ ពុទ្ធាយ សិទ្ធំ**» វិសេសប្លែក ជាងអក្សរសាស្ត្រនានាក្នុងលោក ។

ឯអង្គ៣របស់ភាសាខ្មែរនោះគឺ :

១- សូរសាស្ត្រ ( Phonétique ) ក្បួនប្រើខ្យល់ សំឡេងឱ្យលាន់ឡើង មានន័យច្បាស់លាស់ធំទូលាយឥតទើសទាល់សូរសាស្ត្រភាសាខ្មែរមានឥទ្ធិពលជាងគេក្នុងលោកអាចថា ត្រាប់តាមភាសានានាក្នុងលោកបានដូចសុទ្ធៗ ។ ចំណែកខាងអក្សរសាស្ត្រខ្មែរវិញក៏អាចសរសេរតាមសូរស័ព្ទភាសានានាក្នុងលោកបានដូចពិតៗឥតទើសទាល់ដែរ ដូចជា ព្រង់ដឹហ្គោលអង់គ្លេសហៀនជាដើម ។

២- រូបសាស្ត្រ ( Morphologie ) ក្បួនចែកពីទម្រង់ពាក្យនិងការបញ្ចេញពាក្យឱ្យមានរូបតៗគ្នាទៀតបាន ។ ភាសាខ្មែរជាភាសាមានរូបរស់រវើកមិនស្លាប់គាំងនៅមួយកន្លែងឡើយដូចពាក្យថា កលចេញទៅជាកំណល់ជា ខ្នល់- កាន់- កំណាន់- ខ្នាន់, កើត- កំណើត- ខ្នើត ។ល។

៣- និយន្តសាស្ត្រ ( Sémantique ) ក្បួនវាក្យស័ព្ទនិយាយពីន័យរបស់ពាក្យនិងការប្រែប្រួលន័យ ។ និយន្តសាស្ត្រខ្មែរមានច្រើនបែបគឺ : ក- ពាក្យដូចគ្នាមានន័យផ្សេងគ្នាដូចជាសាប (នាម) គ្រឿងនេសាទុបករណ៍ម្យ៉ាង ពួកទ្រូ- លប- លាយ, សាប (គុណនាម) ដែលផ្ទុយពីប្រៃ សាប (កិរិយា) សាបព្រោះបណ្ដុះដាំ ។ល។ ម្យ៉ាងទៀតពាក្យនិយាយឮដូចគ្នាតែមានន័យ ផ្សេងគ្នា តាមអក្សរ តាមដំណើរសេចក្ដីដូចជាផ្សារ, ផ្សារចិត, ចិត្ត, គេ , គេហ៍, កល, កល់, ជប, ជប់, ដុះ, ដុស ។ល។ ខ- ពាក្យនិយាយឮផ្សេង គ្នាតែមានន័យ ដូចគ្នាសំរាប់ប្រើតាមដំណើរសេចក្ដីដូចជាវិនាស- អន្តរាយ- ក្ស័យ- អន្តរធាន មោឃៈ- សោះសូន្យ- បាត់បង់- ទទេ- ឃែត ។ ពាក្យទាំងអស់នេះ មានន័យតែមួយគឺមិនមានឬគ្មាន ។ គ- ការប្រែប្រួលន័យដោយ ភ្ជាប់ពាក្យដូចជា បង់ (កិរិយា) ដាក់, ទម្លាក់ចុះ, បត់ (កិរិយា ) ត្រឡប់ តាមទំនង , ត្រឡប់ជាផ្ទត់ ។ យកពាក្យពីរនេះមកតភ្ជាប់ទៅជាបង់បត់កើត ជា (នាម ) ប្រែន័យថាទេព្រក្សអារក្ស អ្នកតាទេវិញ ។ ឃ- ការប្រែន័យតាមសម័យដូចជា 'តាត្រន័យដើមថាក្រោលគោ ប្រែជាខ្សែស្រឡាយ ។ល។

ភាសាណាដែលប្រកបដោយអង្គទាំង៣នេះជាភាសាត្រឹមត្រូវមាន វេយ្យាករណ៍ហើយដែលថាអក្សរខ្មែរ មិនទាន់មានវេយ្យាករណ៍នោះគឺមនុស្ស ខ្មែរទេ ដែលមិនទាន់ប្រមូលវេយ្យាករណ៍មកសរសេរ, ឯភាសានិងអក្សរ សាស្ត្រខ្មែរនោះមានវេយ្យាករណ៍គ្រប់សព្វស្រេច តាំងពីសម័យមហានគរ មកម្ល៉េះប៉ុន្តែចោរបរទេស វាលួចក្បួនវេយ្យាករណ៍នោះបាត់ទៅក្នុងសម័យ កើតសង្គ្រាម ។

ដោយហេតុព្រះពុទ្ធសាសនាមានគុណូបការៈសំខាន់យ៉ាង នេះ ចំពោះប្រទេសកម្ពុជាហើយ ទើបក្នុងរដ្ឋធម្មនុញ្ញខ្មែរ បានចារឹកទុកព្រះពុទ្ធ សាសនាជាសាសនារបស់រដ្ឋ ។

ឯន័យរបស់គុណូបការៈនោះដូចនាំមកពណ៌នាខ្លីៗតទៅនេះ ក្នុង សម័យ ដែលប្រទេសខ្មែរមានគ្រោះថ្នាក់ ចុះដុនដាបខ្សោយឥទ្ធិពល ដោយ ហេតុប្រទេសជិតខាង បង្កើតសង្គ្រាមដណ្តើមទឹកដីទ្រព្យសម្បត្តិគម្ពីរក្បួន ច្បាប់ខ្មែរនោះ ព្រះសង្ឃក្នុងវត្តអារាមពុទ្ធសាសនាទាំងអស់ក្នុងប្រទេស បាន ថែរក្សាអង្គការរដ្ឋទុកមិនឱ្យបាត់បង់ឡើយ ដូចជា អង្គការអក្សរសាស្ត្រ អង្គការអប់រំជាតិ អង្គការសុខាភិបាល អង្គការសង្គមកិច្ច និងការងារ អង្គការ កសិកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម អង្គការវិចិត្រសិល្បៈនិងតូរ្យតន្ត្រី អង្គការ ការពារប្រទេស អង្គការឃោសនាការ និង អង្គការយុត្តិធម៌ជាដើម ។

## ក- វត្តនិងអង្គការអក្សរសាស្ត្រ

ក្នុងសម័យប្រទេសមានគ្រោះថ្នាក់ខ្សោយឥទ្ធិពល នៅតាមខេត្ត-

ភូមិស្រុកគ្មានសាលារៀនឡើយ មានតែវត្តអារាម ព្រះសង្ឃនេះឯង ជាសាលរៀននូវវិជ្ជាគ្រប់ជំពូក ជាវិទ្យាស្ថានរបស់ជាតិ ។

ប្រជាពលរដ្ឋខ្មែរទាំងអស់ បាននាំកូនចៅទៅផ្ញើនិងព្រះសង្ឃចៅអធិការតាមមណ្ឌល សង្កាត់ភូមិ ស្រុក រៀងៗខ្លួន មិនគ្រាន់តែផ្ញើឱ្យរៀនដល់ម៉ោង ហើយចេញមកផ្ទះទេ គឺឱ្យដេកនៅបាយទឹកក្នុងវត្តតែម្តង ម្ល៉ោះហើយវត្តអារាម ព្រះពុទ្ធសាសនា ត្រូវទទួលភារៈរបស់ជាតិមួយភាគធំ ព្រះសង្ឃជាចៅអធិការត្រូវរៀបចំឱ្យសិស្សទាំងអស់ មានកន្លែងដេកនៅចំណីអាហារបរិភោគកន្លែងរៀន គ្រឿងសិក្ខូបករណ៍សម្រាប់រៀន និងគ្រឿងប្រើប្រាស់គ្រប់ជំពូកដោយចិត្តសប្បុរសពិតៗ ឥតយកប្រាក់ថ្លៃឈ្នួលអ្វីឡើយ លាភដែលកើតឡើងក្នុងពុទ្ធសាសនានិកចែករំលែកកសាងវត្តអារាមផង ចិញ្ចឹមក្មេងជាសិស្សដែលនៅសិក្សានោះផង ។ ក្នុងសម័យនោះនៅវត្តព្រះសង្ឃគ្មានសាលា តុ កៅអី សំរាប់រៀនដូចសព្វថ្ងៃឡើយ មានតែកុដិចៅអធិការ សាលាឆាន់ជាកន្លែងរៀនគ្រូនិងសិស្សអង្គុយគង់ផ្ទាល់លើកន្ទេលសិស្សម្នាក់ៗ មានក្តារឈ្នួនមួយធ្វើពិធីដើមគបួដើមរកាលាបម្រ័ក្សណ៍ ឬខ្មុកពណ៌ខ្មៅ ឯដីសលោកគ្រូឱ្យយកដីពិសេសមកធ្វើតាមបច្ចេកទេសក្នុងសម័យនោះ ។

មុនដំបូង សរសេរអក្សរធ្វើលេខលើក្តារ បន្ទាប់មករៀនមើលសាស្ត្រាស្លឹករិតដូចសាស្ត្រាច្បាប់ក្រមជាដើម និងរៀនគិតលេខចំណោទនឹងគ្រាប់ក្បាច់ ។ ការរៀនមើលសាស្ត្រស្លឹករឹត ដើម្បីអោយមានបដិភាណក្នុងការមើលថាផង ឱ្យចេះដឹងច្បាប់ទម្លាប់ ពង្សាវតារ មនុស្សធមិ សីលធមិនិង

អារ្យធម៌របស់ជាតិផង ។

កាលបើរៀនបានចេះអក្សរហើយឱ្យរៀនធម៌បួសជាសាមណេរ ភិក្ខុទៀតដើម្បីសិក្សាភាសាបាលីសំស្ក្រឹតឱ្យបានចេះដឹងជ្រៅជ្រះ នូវទ្រឹស្តីពុទ្ធសាសនានិងឱ្យរៀនភាសារអក្សរបរទេសខ្លះទៀតផង ។ បើមិនបានសិក្សាបែបនេះទេ បំរុងលាចាកសិក្ខាបទត្រឡប់ទៅបំរើគ្រួសារវិញឆាប់ៗ លោកបង្រៀនអំពីវិជ្ជាជីវៈផ្សេងៗលែតាមនិស្ស័យរបស់ខ្លួនតើនរណាប៉ិនប្រសប់ខាងការជាងដែក ជាងឈើ ជាងគំនូរ ជាងចំលាក់ ឬតូរ្យតន្ត្រីជាដើមក៏ឱ្យសិក្សាខាងនោះល្មមប្រើការបាន ទើបអោយសឹកមកផ្ទះវិញ ។

ក្នុងពេលចូលទៅសិក្សាក្នុងវត្តនោះ លោកគ្រូមិនមែនបង្រៀនតែអក្សរសាស្ត្រនិងវិជ្ជាជីវៈនោះទេ លោកបានបង្រៀន អំពីសុជីវធម៌ ឱ្យចេះប្រើឥរិយាបថ ដើរ ឈរ អង្គុយ ដេក និយាយស្តីឱ្យមានបែបបទ ចេះគួរសមស្គាល់ខុសត្រូវ តាមប្រពៃណី អារ្យធម៌ជាតិទៀត ។

ចំពោះសិស្សណាដែលមាននិស្ស័យឈ្លាសវៃ ខាងអក្សរសាស្ត្រលោកគ្រូឱ្យរៀនធ្វើអ្នកនិពន្ធ កវីនិពន្ធ តែងសេចក្តី តែងកាព្យហើយចារលើស្លឹករឹត ឬសរសេរក្នុងក្រាំងទុកជាក្បួនច្បាប់សម្រាប់រៀនតៗមកទៀត ដើម្បីរក្សាអក្សរសាស្ត្រជាតិ ភាសាជាតិដែលជាលក្ខណៈសំខាន់បំផុតរបស់ជាតិទុកកុំឱ្យបាត់បង់ព្រោះថាបើអក្សរសាស្ត្ររលត់ ភាសាត្រូវរលំ ជាតិត្រូវរលាយ បាត់បង់ចាកពីពិភពលោកមិនខាន ។

អាស្រ័យហេតុនេះ ទើបព្រះសង្ឃគ្រប់វត្តអារាម ក្នុងពេលនោះខំរក្សាអក្សរសាស្ត្រជាតិទុក និងលើកតម្កើងកុំឱ្យចាញ់ប្រៀបប្រជាជាតិទាំង

ឡាយក្នុងពិភពលោក ដែលគេខំថែរក្សាលើកតម្កើងអក្សរសាស្ត្រ និងភាសាគេស្មើជីវិត ទោះបីគេទ័លក្រលំបាកតោកយ៉ាកយ៉ាងណា ឬអក្សររបស់គេនោះពិបាកសរសេរពិបាករៀនយ៉ាងណា ក៏គេមានសម្បជញ្ញៈ ដាស់តឿនទាញញាក់សរសៃវិញ្ញាណគេឱ្យមានស្មារតីភក្តិ ចំពោះអក្សរសាស្ត្រភាសាជាតិជានិច្ច ដូចពួកចិនអេតចាយរែកកញ្ឆេទិញសម្បកដបជាដើម ដែលក្រមានតែខោលើជង្គង់ រសាត់អណ្តែតសែតអញ្ចង់មកជ្រករស់នៅក្នុងស្រុកយើងនោះ គេមានសម្បជញ្ញៈចំពោះអក្សរសាស្ត្រគេស្មើជីវិត ដូចជានៅតាមសសរផ្ទះមាត់ទ្វារបង្អួចនិងចង្ក្រានបាយក៏មានបិទផ្ទាំងអក្សរចិន ដែលសរសេរដោយផ្ចិតផ្ចង់លើកតម្កើងឱ្យអក្សរជាតិគេមានតំលៃដែរ ។

ដោយព្រះសង្ឃគ្រប់វត្តអារាមមានសម្បជញ្ញៈបែបនោះខំបីបាច់រក្សាលើកតម្កើងអង្គការអក្សរសាស្ត្រនេះឱ្យមានវឌ្ឍនភាពជានិច្ច នោះក្នុងប្រទេសក្រខ្សាច់ខ្សោយ ក៏ដូចនៅក្នុងគ្រាចំរើនរុងរឿងដែរ ។

លុះដល់មកសម័យចំរើនរុងរឿង អង្គការអក្សរសាស្ត្រជាតិបានចេញពីវត្តអារាមទៅនៅក្នុងស្រុកភូមិ កើតជាក្រសួងសិក្សាធិការជាតិឡើងដោយមានវិជ្ជាអក្សរសាស្ត្រអន្តរជាតិ តាមសម័យនិយមផ្សំជាមួយផង ។

ឯក្បួនច្បាប់អក្សរសាស្ត្រខ្មែរខ្លះ ដូចជាច្បាប់ក្រម ច្បាប់ហែមហាជន ច្បាប់ប្រុស-ស្រី រឿងកាកី ទុំទាវ និង ហង្សយន្តជាដើម ដែលក្នុងសម័យមុនជ្រកនៅក្នុងវត្តអារាមមានតែកូនសិស្សលោករៀននោះ ឥឡូវបានទៅនៅក្នុងសាលាជាតិឯស្រុក ភូមិ អស់ហើយ ។

ផ្នែកអង្គការអក្សរសាស្ត្រនេះ ទោះបីបានចេញដំណើរមកពីវត្ត -

អារាមទៅទទួលវឌ្ឍនធម៌ពីរដ្ឋផ្ទាល់ហើយក៏ព្រះសង្ឃគ្រប់វត្តទាំងអស់ នៅតែតាមជួយទ្រទ្រង់ បង្កើតវឌ្ឍនធម៌ខាងអក្សរសាស្ត្រពេញទំហឹង ដូចជាជួយបង្កើតពាក្យវប្បធម៌អក្ខរាវិរុទ្ធ និងជួយសង់សាលាបឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យមហាវិទ្យាល័យ នឹងជួយទំនុកបំរុងពួកសិស្សឱ្យសំណាក់ដេកនៅបាយទឹកក្នុងវត្តអារាមជាច្រើនម៉ឺននាក់ក្នុងមួយឆ្នាំៗគ្រប់វត្តអារាមដែលនៅជិតសាលារៀនក្នុងព្រះរាជអាណាចក្រទាំងមូល ។

នេះជាសក្ខីភាពមួយ បញ្ជាក់ឱ្យឃើញច្បាស់ថា ព្រះពុទ្ធសាសនាពិតជាសាសនារបស់រដ្ឋកម្ពុជាមែន ។

## ខ - វត្តនិងអប់រំជាតិ

ក្នុងសម័យប្រទេសមានគ្រោះថ្នាក់ខ្សោយឥទ្ធិពល នៅក្នុងភូមិស្រុកគ្មានមូលដ្ឋានអប់រំពិតប្រាកដឡើយ ភារៈអប់រំពលរដ្ឋឱ្យចេះស្រឡាញ់ជាតិសាសនាព្រះមហាក្សត្ររបស់ខ្លួន ឱ្យចេះរក្សាប្រពៃណី ទំនៀមទំលាប់សិល្បៈពិធីការជាតិ ឱ្យស្គាល់ខុសត្រូវ លះបង់អំពើអាក្រក់ ធ្វើតែអំពើល្អ នឹងឱ្យបានសាមគ្គីធម៌ចេះជួយសង្គ្រោះគ្នាទៅវិញទៅមកក្នុងសង្គមជាតិជាដើមនៅជាភារៈពុទ្ធសាសនាទាំងស្រុង មានតែពុទ្ធសាសនាទេដែលមានប្រសិទ្ធភាពក្នុងការអប់រំនេះព្រោះប្រជាពលរដ្ឋភាគច្រើនជឿទុកចិត្តពុទ្ធសាសនារួចមកហើយ។

អាស្រ័យហេតុនេះ ទើបព្រះសង្ឃគ្រប់វត្តអារាមទាំងអស់ក្នុងប្រទេស តែងអប់រំប្រជាពលរដ្ឋក្នុង ស្រុកភូមិដោយទ្រឹស្ដីផង ដោយការពិសោធន៍ផង ។

ផ្នែកទ្រឹស្តី=គ្រប់តែវិធីបុណ្យទាំងអស់ ដូចបុណ្យសពជាដើមព្រះសង្ឃតែងពន្យល់អំពីទ្រឹស្តី នៃការកើតចាស់ ឈឺស្លាប់តាមច្បាប់ទស្សនៈវិជ្ជាដែលធ្លាប់នាំគ្នានិយមហៅថាលោកសូត្រធម៌ឬទេសនា ដើម្បីឱ្យពលរដ្ឋស្គាល់ច្បាស់នូវបញ្ហាជីវិតនិងបន្ទូរបន្ថយនូវមរណទុក្ខ អំពីចិត្តគំនិតគ្រួសារសពផង ឱ្យយល់ហេតុផលអានិសង្សនៃការជួយសង្គ្រោះ ដោយសម្ភារចំពោះអ្នកកំពុងទទួលមរណទុក្ខផង ដើម្បីឱ្យមានសាមគ្គីធម៌ជួយទុក្ខធុរៈគ្នាក្នុងស្រុកភូមិផង ។

ផ្នែកការពិសោធន៍ = ព្រះសង្ឃមិនគ្រាន់តែសូត្រធម៌ ទេសនាពន្យល់ត្រឹមទ្រឹស្តីប៉ុណ្ណោះទេ បើមានបុគ្គលណាមួយក្នុងស្រុកភូមិស្លាប់លោកតែនិមន្តទៅជួយឧបត្ថម្ភខាងផ្លូវចិត្ត និងប្រកាសប្រាប់ដំណឹងមរណៈ នោះដល់អ្នកស្រុកភូមិទាំងអស់ដោយលិខិតឬដោយវាចា និង ដោយសូរស័ព្ទគងដើម្បីឱ្យអ្នកស្រុកភូមិទាំងអស់នៅជួយគ្នា ដោយកំលាំងកាយនិង សម្ភារៈដូចជាលុយកាក់ អង្ករ ទៀន ធូប ជាដើម ។

ការអប់រំនេះបានផលល្អបំផុត កើតជាប្រពៃណីចាំបាច់មួយក្នុងស្រុក ភូមិនាសម័យនោះ ។ កាលបើមានបុគ្គលណាមួយស្លាប់ហើយគេវាយគងភ្លាមមិនរើសឋានៈបុគ្គលឡើយ ដើម្បីផ្តល់ដំនឹងដល់អ្នកស្រុកភូមិ ។ ឯអ្នកស្រុកភូមិកាលបើបានឮសូរគងនៅទិសណាហើយ តែលះបង់ការងារយកសម្ភារៈមានអង្ករលុយកាក់ ទៀនធូបជាដើម នាំគ្នាទៅជួយភ្លាមមិនបាច់គ្រួសារសពអញ្ជើញឡើយ មានលក្ខណៈល្អសមជាមនុស្សពិតមែន ។ គ្រប់កិច្ចការទាំងអស់ក្នុងស្រុកភូមិ ទោះក្នុងវត្តក្តី ក្រៅវត្តក្តី ដូចជាការសាងសង់

វិហារ- កុដិ- សាលា- ផ្លូវ- ស្ពាន- ជីកស្រះ- អណ្តូង ការធ្វើពិធីក្នុងវត្ត ភ្ជុំបិណ្ឌ- កឋិន- ចូលឆ្នាំ ជាដើមសុទ្ធតែជាសម័យអប់រំប្រជាពលរដ្ឋ ឱ្យយល់ចេះដឹងនូវមនុស្សធម៌សីលធម៌និងអារ្យធម៌ទាំងអស់ ប៉ុន្តែដោយការអប់រំនោះប្រកបដោយគតិបណ្ឌិតទាំងទ្រឹស្តីនិង ការពិសោធន៍ ជាទីពេញចិត្ត នៃប្រជាពលរដ្ឋ គេមិននាំគ្នានិយាយថាទៅអប់រំទេ គេបែរជានាំគ្នានិយាយថាទៅធ្វើបុណ្យវិញ ។

ក្នុងសម័យអប់រំ គឺក្នុងពិធីបុណ្យនោះៗ ព្រះសង្ឃតែងប្រកាសផ្សាយនូវទ្រឹស្តី គឺសូត្រធម៌ទេសនា ពន្យល់ហេតុផលតាមលក្ខណៈកិច្ចការនឹងជួយដឹកនាំធ្វើទៀត ដើម្បីឱ្យពលរដ្ឋចេះស្រឡាញ់ការងារ ចេះស្រឡាញ់ប្រយោជន៍រួមនឹងឱ្យមានសាមគ្គីធម៌ ជួយផ្តល់ប្រយោជន៍ដល់គ្នានិង គ្នាក្នុងស្រុកភូមិ ។

លុះមកដល់សម័យចំរើនលូតលាស់ អង្គការអប់រំជាតិបានចេញពីវត្តអារាម ទៅនៅក្នុងស្រុកភូមិ កើតជាក្រសួងអប់រំជាតិឡើង ដោយមានពិធីអប់រំអន្តរជាតិតាមសម័យនិយមផ្សំជាមួយផង ។

ផ្នែកអង្គការអប់រំជាតិនេះ ទោះបីបានធ្វើដំណើរទៅនៅក្នុងស្រុកភូមិបានទទួលវឌ្ឍនធម៌ផ្ទាល់ពីរដ្ឋហើយក៏ព្រះសង្ឃគ្រប់វត្តអារាមទាំងអស់នៅតែមានការជួយអប់រំពលរដ្ឋគ្រប់មធ្យោបាយតាមលទ្ធភាពដែលព្រះសង្ឃអាចធ្វើបាន តាមធម៌វិន័យពុទ្ធសាសនា ។

នេះជាសក្ខីភាពមួយទៀត បញ្ជាក់ឱ្យឃើញច្បាស់ថាព្រះពុទ្ធសាសនា ពិតជាសាសនារបស់រដ្ឋកម្ពុជាមែន ។

# គ- វត្តនិងអង្គការសុខាភិបាល

ក្នុងសម័យប្រទេសមានគ្រោះថ្នាក់ខ្សោយឥទ្ធិពល នៅតាមស្រុកភូមិគ្មានមន្ទីរពេទ្យឡើយ ។ ប្រជាពលរដ្ឋដែលមាន ជម្ងឺរោគាទាំងឡាយមាន គ្រុនក្តៅ របួស ថ្លស់គ្រេច បាក់ឆ្អឹង ពស់ចិក និងជម្ងឺអាសន្នរោគជាដើម តែងរត់ទៅរកថ្នាំឯវត្តរកលោកគ្រូចៅអធិការឱ្យជួយមើលជម្ងឺនោះ ។ ឬទៅរកឧបាសកដែលបានចេះវិជ្ជាពេទ្យពីវត្តមក ។

អាស្រ័យហេតុនេះ ទើបក្នុងវត្តអារាមនាសម័យនោះច្រើនតែមានព្រះសង្ឃចេះវិជ្ជាពេទ្យមានក្បួនផ្សំថ្នាំ មានវត្ថុធាតុថ្នាំ គ្រប់មុខក្នុងវត្ត ដោយលោកគ្រូបាននិមន្តទៅរកដើមឈើនិងវត្ថុធាតុថ្នាំ ពីទីផ្សេងៗមានព្រៃភ្នំជាដើមយកមកដាំក្នុងវត្តទុកក្នុងកុដិសម្រាប់សេចក្តីត្រូវការរបស់ប្រជាជន និងចេះព្យាបាលរោគដោយវិធីប្រើកំលាំងដួងចិត្ត ផ្លុំស្តោះ ដៅ ស្ទាបស្រោចទឹក ចងខ្សែគាថា ចងអំបោះដែលជាសាខារបស់មនោមយិទ្ធិវិជ្ជា ( Volonté ) នោះថែមទៀត ។ លោកព្យាបាលអ្នកជម្ងឺដោយចិត្តមេត្តាករុណាពិតៗ ឥតយកប្រាក់ខែពីរដ្ឋ ឬរង្វាន់ ពីអ្នកជម្ងឺឡើយ ។

វត្តអារាមក្នុងសម័យនោះ មិនមែនគ្រាន់តែជាកន្លែងអប់រំធ្វើបុណ្យទានចំរើនមេត្តាភាវនាទេគឺជាមន្ទីរពេទ្យនិងជាសាលារៀនវិជ្ជាពេទ្យទៀតផង ដោយមានភក្កុសាមណេរឧបាសកដែលមាននិស្ស័យខាងវិជ្ជាពេទ្យនេះ ទៅសុំរៀនតាមក្បួនតម្រាដែលមានក្នុងវត្ត ហើយពិសោធមើលអ្នកជម្ងឺដរាបបានចេះដឹងកើតជាគ្រូពេទ្យតៗមក ។ ព្រោះសុខភាពប្រជាពលរដ្ឋបានពឹង

ពាក់លើវត្តអារាមទាំងស្រុង ។

លុះដល់មកសម័យចំរើនលូតលាស់ អង្គការសុខាភិបាលបានចេញពីវត្តអារាមទៅនៅក្នុងស្រុកភូមិ កើតជាក្រសួងសាធារណសុខាភិបាលឡើង ដោយមានក្បួនសុខាភិបាលអន្តរជាតិ តាមសម័យនិយម និងឱសថ បរទេស ផ្សំជាមួយផងដែរ ។

ផ្នែកអង្គការសុខាភិបាលនេះ ទោះបីបានធ្វើដំណើរចេញវត្តអារាមទៅនៅក្នុងស្រុកភូមិ បានទទួលវឌ្ឍនធម៌ផ្ទាល់ពីរដ្ឋហើយក៏ព្រះសង្ឃគ្រប់វត្តទាំងអស់នៅតែជួយទំនុកបំរុងមានជួយសង់មន្ទីរពេទ្យ ជួយផ្ដល់ឱសថឱ្យមន្ទីរពេទ្យនោះៗ ថែមទៀតដូចគិលាននិងប្រសូតិគ្រឹះរបស់សម្ដេចព្រះមហាសុមេធា ធិបតី ជួនណាត ព្រះសង្ឃរាជ នៅសង្កាត់រការកោះ ស្រុកគងពិសី និងមណ្ឌលសុខភាព សម្ដេចព្រះពោធិវង្ស ហួត- តាត នៅសង្កាត់វាំងចាស់ ស្រុកឧដុង្គខេត្តកំពង់ស្ពឺ ជាដើម ។

នេះជាសក្ខីភាពមួយទៀត បញ្ជាក់ឱ្យឃើញថាព្រះពុទ្ធសាសនា ពិតជាសាសនារបស់រដ្ឋកម្ពុជាមែន ។

## ឃ - វត្តនិងអង្គការសង្គមកិច្ច - ការងារ

ក្នុងសម័យប្រទេសមានគ្រោះថ្នាក់ខ្សោយឥទ្ធិពល- វត្តអារាមទាំងអស់ នាសម័យនោះជាទីចាត់ការនៃសង្គមកិច្ច និងការងាររបស់ប្រជាពលរដ្ឋ

វត្តមួយៗបានផ្ដល់កិច្ចការ ដែលសង្គមជាតិត្រូវការគ្រប់យ៉ាង ខាងផ្លូវចិត្ត បានផ្ដល់នូវមនុស្សធម៌ សីលធម៌ និងអារ្យធម៌ខាងសម្ភារៈ បានផ្ដល់

ការងារវិជ្ជាជីវៈឱ្យពលរដ្ឋ ដើម្បីប្រកបអាជីវកម្មតាមសមត្ថភាពរៀងៗខ្លួន ។

ពួកកុមារនិងយុវជន ដែលមាតាបិតានាំឱ្យទៅនៅក្នុវត្តនាសម័យនោះមិនមែនឱ្យសិក្សាតែអក្សរសាស្ត្រ និងបួសរៀនធម៌ចេះដឹងតាមទ្រឹស្តីហើយ វិលត្រឡប់មកស្រុកភូមិវិញ ដើររកការងារគេធ្វើទេ ។ ព្រះសង្ឃជាគ្រូអាចារ្យ បានដឹកនាំកុមារ និង យុវជនឱ្យរៀនពិសោធន៍ធ្វើមុខរបរវិជ្ជាជីវៈគ្រប់យ៉ាង ដូចជារៀនធ្វើការងារខាងជាងឈើ ជាងដែក ជាងចំលាក់ ជាងគំនូរ ជាងស្មិត ឱ្យរៀនធ្វើឡដុតឥដ្ឋក្បឿង ដុតកំបោរ រៀបឥដ្ឋ បូកលាយបាយអ ឱ្យរៀនធ្វើជាលល្អី ស្មុគ កញ្ជើ ឱ្យរៀនក្រឡឹងធ្វើថាស ក្បាក់ ។ល។ ជួយទំនុកបំរុងឱ្យរៀនភ្លេងតូរ្យតន្ត្រីរបាំច្រៀងរាំ និងឱ្យរៀនធ្វើកសិកម្មស្រែចំការច្បារ ដំណាំជាដើមទៀត ។

ផ្នែកកសិកម្ម- វត្តមួយៗក្នុងជំនាន់នោះ មានគោរទេះមានស្រែចំការច្បារដំណាំនង្គ័លរនាស់ សំរាប់ពួកកុមារ និង យុវជនដែលទៅរៀនអក្សរ ឬរៀនធម៌ភ្ជួររាស់ ដាំ សាប ស្ទូង ដក ច្រូតកាត់ បញ្ជាន់បោកបែនយកផលប្រើការក្នុងវត្តដោយមានគ្រហស្ថជើងវត្តឆ្លៀតពេលជួយធ្វើផងជួនកាលពេលយប់មានភិក្ខុសាមណេរជួយធ្វើផងដែរ ។

អាស្រ័យហេតុនេះ ទើបយុវជនសម័យនោះ មានបច្ចេកទេសខាងកសិកម្ម ដល់ត្រឡប់មកផ្ទះវិញ ចេះធ្វើកសិកម្មខ្លួនឯងតែម្តង មិនបាច់ដើររកសុំការងារគេរៀនធ្វើទៀតឡើយ ។

ផ្នែកការជាង = វត្តមួយៗក្នុងសម័យនោះ លោកគ្រូចៅអធិការតែងនាំសិស្សគណពលក្រើកពីរិហារ សាលានិងប្រដាប់ប្រើប្រាស់ដូច តុ ទូតាំង ទូក

រទេះជាដើមដោយខ្លួនឯង ឥតទិញដូរឬជួលគេមកធ្វើឡើយ ។ ឯគ្រឿងសម្ភារៈសំរាប់ស្ថាបនាសុទ្ធតែនាំសិស្សគណធ្វើផ្ទាល់ខ្លួន ចាប់តាំងពីទៅកាប់ឈើ យកមក អារ ច្រៀក ឈូស ដាប់ វាស់ កាត់ វាយឥត ធ្វើជាដុតឥដ្ឋដុតក្បឿង ទៅរកថ្ម ឬសម្បកលៀស មកដុតធ្វើកំបោរលាយគ្រួសខ្សាច់ធ្វើបាយអរ រៀបបូកធ្វើគ្រិះជញ្ជាំង គូសវាសក្បាច់រចនា ឆ្លាក់ដាប់ចោះធ្វើប្រដាប់ក្រឡឹងចម្រឹងទ្វារបង្អួច ។ល។ ទម្រាំតែធ្វើ កុដិសាលាវិហារមួយៗរួច ពួកសិស្សគណទាំង គ្រហស្ថ បព្វជិត ចេះការងារស្ទាត់ជំនាញស្មើរគ្រប់មុខ ។

ហេតុដែលវត្តអារាមសម័យនោះ បង្កើតឱ្យមានការងារ ធ្វើគ្រប់សព្វយ៉ាងនេះ ដើម្បីដឹកនាំសង្គមជាតិឱ្យមានការចេះដឹង ខាងមុខរបរជីវៈផង ឱ្យបានកើតមានជាកុដិ វិហារ ទូ តុតាំង ។ល។ តម្កល់ទុកជាសម្បត្តិរួមក្នុងសាសនាផង ។ ដល់ពួកសិស្សគណ ទាំងនោះទៅផ្ទះស្រុកភូមិវិញខ្លះក៏ប្រកបមុខរបរជាជាងឈើ ជាងគំនូរ ។ល។ តាមសមត្ថភាពរៀងខ្លួនឥតតែលតោល ដើររកការងារធ្វើឡើយ ។

ចំណែកខាងចរិយាធម៌របស់សង្គមវិញ ក៏មានបែបបទល្អ ណាស់ដែរ ពួកអ្នកលេងកាប់ចាក់លួចឆក់ មានចំនួនតិចស្មើរតែគ្មានសោះ ព្រោះបានហ្វឹកហាត់ខាងមនុស្សធម៌ សីលធម៌ និងអារ្យធម៌តាមទ្រឹស្តីពុទ្ធសាសនាព្រមជាមួយ ការរៀនពិសោធន៍ធ្វើមុខរបរជីវៈនោះដែរ ។

លុះមកដល់សម័យចំរើនល្អតលាស់ អង្គការសង្គមកិច្ច និងការងារបានធ្វើដំណើរចេញពីវត្តអារាមទៅស្រុកភូមិ កើតជាក្រសួងសង្គកិច្ច និង -

ការងារឡើង ដោយមានក្បួន សង្គមកិច្ចនិងការងារ អន្តរជាតិ តាមសម័យនិយមផ្សំជាមួយផង ។

ទោះបីអង្គការនេះ បានចេញពីវត្តអារាម ទៅនៅក្នុងស្រុកភូមិ បានទទួលវឌ្ឍនធមិផ្ទាល់ពីរដ្ឋហើយ ក៏ព្រះសង្ឃគ្រប់វត្តនៅតែជួយទំនុកបំរុងជានិច្ច មានឱ្យទីដេកនៅបាយទឹកចំពោះយុវជនដែលរកការងារធ្វើមិនទាន់បានឬបានការងារធ្វើហើយ តែមិនមានផ្ទះនៅ មិនទាន់មានគ្រួសារនោះជាច្រើនឆ្នាំក្នុងម្នាក់ៗទៀតមានព្រះសង្ឃខ្លះ ដែលមានសមត្ថភាព បានជួយរកការងារ ឱ្យយុវជន ធ្វើផងដែរ ។

នេះជាសក្ខីភាពមួយទៀត បញ្ជាក់ឱ្យឃើញច្បាស់ថាព្រះពុទ្ធសាសនា ពិតជាសាសនារបស់រដ្ឋកម្ពុជាមែន ។

## ខ - វត្តនិងអង្គការកសិកម្ម

ក្នុងសម័យប្រទេសមានគ្រោះថ្នាក់ខ្សោយឥទ្ធិពល នៅក្នុងស្រុកភូមិគ្មានមូលដ្ឋានទ្រទ្រង់ អង្គការកសិកម្មនេះឡើយ មានតែក្នុងវត្តអារាមព្រះពុទ្ធសាសនា ។ ព្រះសង្ឃនិងឧបាសកអ្នកជំនាញការក្នុងវត្តបានបង្រៀនពលរដ្ឋតាមទ្រឹស្តីផង ដឹកនាំពិសោធធ្វើផង ដោយមានគ្រឿងឧបករណ៍សព្វគ្រប់នៅ ក្នុងវត្តដូចបាននិយាយហើយ ក្នុងអង្គការសង្គមកិច្ច និងការងារត្រង់ជំពូក **ឃ** ។

លុះដល់សម័យចំរើនលូតលាស់អង្គការកសិកម្ម បានចេញពីវត្តអារាមទៅនៅក្នុងស្រុកភូមិ កើតជាក្រសួងកសិកម្មឡើង ដោយមានវិជ្ជា-

កសិកម្មអន្តរជាតិ តាមសម័យនិយមផ្សំជាមួយ ។

ទោះបីអង្គការនេះទៅនៅក្នុងស្រុកភូមិ បានទទួលវឌ្ឍនធម៌ផ្ទាល់ពីរដ្ឋហើយ ក៏ព្រះសង្ឃនិងពុទ្ធបរិស័ទ គ្រប់វត្តអារាមទាំងអស់ នៅតែជួយទ្រទ្រង់ពេញទំហឹង មានជួយធ្វើមធ្យោបាយទឹក ជីកព្រែក ជីកស្រះ លើកទំនប់ជាដើម ។

នេះជាសក្ខីភាពមួយទៀត បញ្ជាក់ឱ្យឃើញច្បាស់ថាព្រះពុទ្ធសាសនាពិតជាសាសនារបស់រដ្ឋកម្ពុជាមែន ។

## ច-វត្តនិងអង្គការឧស្សាហកម្ម

ក្នុងសម័យប្រទេសមានគ្រោះថ្នាក់ខ្សោយឥទ្ធិពល អង្គការឧស្សាហកម្មនេះ ជាអង្គការកំសត់កម្រជាងគេ, ព្រោះនៅក្នុងស្រុកភូមិ គ្មានមូលដ្ឋានទ្រទ្រង់សោះ ។ ពលរដ្ឋទាំងឡាយតែងបានទទួលការចេះដឹង និងទទួលផលិតផលឧស្សាហកម្ម យកទៅប្រើប្រាស់ តែអំពីវត្តអារាមដូចជាឆ្នាំង ផ្តិល កាំបិទ ប៉ូវថៅ ឥដ្ឋ ក្បឿង កំបោរជាដើម សូម្បីតែគ្រឿងវាយនភណ្ឌសំរាប់ត្បាញសំពត់មានកី រហាត់ជាដើម ក៏ទៅរកព្រះសង្ឃ ឬឧបាសកអ្នកជំនាញការក្នុងវត្តធ្វើឱ្យដែរ, ព្រោះនៅក្នុងវត្តមានព្រះសង្ឃ-គ្រហស្ថជាអ្នកបច្ចេកទេសសាកល ចេះធ្វើពុម្ពវាយ ឥដ្ឋស្គាល់ដីធ្វើឥដ្ឋក្បឿង ចេះធ្វើឡដុតក្បឿង ឡដុតកំបោរ ចេះធ្វើឡធ្វើបាវ ដុតរំលាយដែក ស្ពាន់ លិង្ហូន សំរិត សិតធ្វើឆ្នាំង ផ្តិល ប្រអប់ តុ ពាន ធ្វើគ្រឿងភ្លេងតឹងឃ្មោះ សិត ព្រះពុទ្ធរូប ។ល។ និងមានគ្រឿងស្នប់សប់ដុតជីដែក ធ្វើប្រដាប់ប្រើប្រាស់គ្រប់ជំពូក-

ដូចកាំបិត ពូថៅ ពន្លាក ដែកឈូសជាដើម ។ ជាពិសេសមានព្រះសង្ឃខ្លះចេះធ្វើគ្រឿងចក្រ ដូចប្រដាប់បូមទឹក រហាត់ទឹក គ្រឿងថ្លឹងទឹក ម៉ាស៊ីនកាណូតប្រើចំហាយទឹក ម៉ាស៊ីនច្រៀង និងចេះយកស្នែងមកកោសស្លផ្សំវត្ថុធាតុ ពិសេសធ្វើថាសម៉ាស៊ីនច្រៀងផង ។

ចំណែកខាងគ្រឿងវិសេវ គ្រឿងផ្ទះវិញ ក៏មានបច្ចេកទេសជំនាញណាស់ដែរ បានយកវត្ថុធាតុដែលកើតក្នុងទឹកដីខ្មែរ ដូចជាអាចម៍ប្រចៀវជាដើម មកធ្វើប្រដាប់ត្រងច្រោះឱ្យកើតជាក្រាមហើយយកទៅបុកផ្សំជាមួយធ្យូងដើមសង្កែ ដើមថ្កូវ ស្ពាន់ធ័រលាយនឹងកម្ទេចដែក ប្រាក់ ស្ពាន់ធ្វើកាំជ្រួចរន្ទា ភ្លីទៀនជាដើមសំរាប់ដុតបញ្ចេញសូរស័ព្ទនិងពន្លឺគ្រប់ពណ៌ ក្នុងពិធីបុណ្យព្រមទាំងចេះធ្វើគោមហោះ មនុស្សហោះ ទៅក្នុងអាកាសទៀត ។

វត្តអារាមមិនគ្រាន់តែផ្តល់ផលិតផល ឧស្សាហកម្មឱ្យពលរដ្ឋប្រើប្រាស់ប៉ុណ្ណោះទេ គឺជាសាកលវិទ្យាស្ថានជាតិទៀតផង ព្រោះពលរដ្ឋគ្រប់ទិសទី ទាំងអស់ក្នុងប្រទេស បាននាំកូនចៅឱ្យទៅនៅវត្ត ឱ្យបួសរៀនធម៌ រៀនធ្វើការទាំងអស់ដែលមានក្នុងវត្តដល់ត្រឡប់មកផ្ទះស្រុកភូមិវិញបានយកវិជ្ជាដែលខ្លួនចេះដឹងក្នុងវត្តនោះ មកប្រកបអាជីវកម្មរៀងៗខ្លួនខ្លះជាជាងដែក ជាងឈើ ជាងកំបោរ ។ល ។

លុះដល់មកសម័យចំរើនលូតលាស់ អង្គការឧស្សាហកម្ម បានចេញពីវត្តអារាមទៅនៅក្នុងស្រុកភូមិកើតជាក្រសួងឧស្សាហកម្មឡើង ដោយមានវិជ្ជាឧស្សាហកម្មអន្តរជាតិ តាមសម័យនិយមផ្សំជាមួយផង ។

ទោះបីអង្គការនេះ ទៅនៅក្នុងស្រុកភូមិ បានទទួលវឌ្ឍនធម៌ផ្ទាល់

ពីរដ្ឋហើយ ក៏ព្រះសង្ឃនៅតែផ្តល់មធ្យោបាយ ជួយទ្រទ្រង់ពេញសមត្ថភាព បានជួយដឹកនាំពលរដ្ឋឱ្យធ្វើឡដុតឥដ្ឋ ក្បឿង និងឱ្យទីដីវត្តអារាមខ្លះដែលទំនេរ ធ្វើរោងឧស្សាហកម្មជាដើម ។

នេះជាសក្ខីភាពមួយទៀតបញ្ជាក់ឱ្យឃើញច្បាស់ថា ព្រះពុទ្ធសាសនាពិតជាសាសនារបស់រដ្ឋកម្ពុជាមែន ។

## ឆ- វត្តនិងអង្គការពាណិជ្ជកម្ម

ក្នុងសម័យប្រទេសមានគ្រោះថ្នាក់ខ្សោយឥទ្ធិពល អង្គការពាណិជ្ជកម្មនេះពឹងផ្អែកលើវត្តអារាមដែរ ព្រោះវត្តអារាមជាប្រភព នៃផលិតផលឧស្សាហកម្មជាដើម ។

ពួកឈ្មួញទាំងឡាយ ទោះឈ្មួញគោកក្តី ទឹកក្តី ច្រើនតែលក់ដូរផលិតផល ដែលធ្វើកើតក្នុងទីវត្ត ឬដែលគ្រហស្ថបានចេះដឹងពីវត្តយកទៅធ្វើក្នុងស្រុកភូមិ ដូចជាឆ្នាំង ផ្តិល ថ្នាំ កែរោគ និង គ្រឿងស្លៀកពាក់ ហូលសារុង ស្រូវអង្ករ ជាដើម ។

ឯពួកឈ្មួញសម័យនោះ តែងដឹកនាំឥវ៉ាន់ពីភូមិមួយទៅភូមិមួយដើរលក់ដូរដេកផ្លូវ ដល់វេលាថ្ងៃក្តៅ ឬយប់តែងចូលទៅសំរាក់បាយទឹកដេកនៅក្នុងវត្តអារាម ។ ព្រះសង្ឃតែងជួយសង្គ្រោះឱ្យបាយទឹក ទីដេកនៅ ជួយប្រាប់អ្នកស្រុកភូមិឱ្យជួយទិញជួយលក់ដូរទៅវិញទៅមក តាមសេចក្តីត្រូវការរៀងខ្លួន ។ បើអ្នកស្រុកភូមិមានរបស់អ្វីដែលត្រូវលក់ លោកជួយប្រាប់ ឱ្យឈ្មួញជួយទិញ បើឈ្មួញមានរបស់អ្វីត្រូវលក់ លោកប្រាប់អ្នកស្រុកភូមិឱ្យ

ជួយទិញ ដើម្បីជួយឃិតឃោងជីវភាពគ្នាក្នុងសង្គមជាតិ តាមលទ្ធភាព ដែលលោកត្រូវធ្វើបាន ។

លុះដល់មកសម័យចំរើនលូតលាស់ អង្គការពាណិជ្ជកម្មបានចេញពីវត្តអារាម ទៅនៅក្នុងស្រុកភូមិ កើតជាក្រសួងពាណិជ្ជកម្មឡើង ដោយមានវិជ្ជាពាណិជ្ជកម្មអន្តរជាតិ តាមសម័យនិយម និងផលិតផលបរទេសផ្សំជាមួយផង ។

ទោះបីអង្គការនេះ នៅក្នុងស្រុកភូមិបានទទួលវឌ្ឍនធម៌ផ្ទាល់ពីរដ្ឋហើយ ក៏ព្រះសង្ឃនៅតែទ្រទ្រង់ តាមលទ្ធភាព ដែលអាចជួយបាន ដូចជាជួយដឹកនាំអ្នកស្រុកភូមិឱ្យប្រួបរួមគ្នាធ្វើសហករណ៍ និងឱ្យទីដីវត្តខ្លះដែលទំនេរធ្វើឃ្លាំង ឬមន្ទីរសហករណ៍ជាដើម ។

នេះជាសក្ខីភាពមួយទៀត បញ្ជាក់ឱ្យឃើញច្បាស់ថាព្រះពុទ្ធសាសនា ពិតជាសាសនារដ្ឋកម្មជាមែន ។

## ៩- វត្តនិងអង្គការវិចិត្រសិល្បៈតូរ្យតន្ត្រី

ក្នុងសម័យប្រទេសមានគ្រោះថ្នាក់ប្រោយឥទ្ធិពល អង្គការវិចិត្រសិល្បៈ និងតូរ្យតន្ត្រីនេះក៏បានពឹងពាក់លើវត្តអារាមដែរ ។

ផ្នែកវិចិត្រសិល្បៈ = ក្នុងវត្តអារាមមួយៗមានព្រះសង្ឃចេះគូររូបភាព លើក្រដាស់ សំពត់ និងលើជញ្ជាំង ដូចគូរពុទ្ធប្រវត្តិភ្ជាប់នឹងជញ្ជាំងកុដិវិហារ, គូរភ្ជាប់លើផ្ទាំងធំៗ ធ្វើព្រះបដ គូររឿងព្រះវេស្សន្តរលើផ្ទាំងសំពត់តូចៗធ្វើទង់ទៀវ និងចេះគូរឆ្លាក់ក្បាច់ភ្ញីគ្រប់បែបលើផ្ទាំងសិលា ផ្ទាំង

លោហៈនិង លើផ្ទៃឈើធ្វើរងស្បូវ ជហ្វា ដងក្ដារ មេទ្វារ បង្អួច និងឆ្លាក់រូបនាគ គ្រុឌ កិន្នរ រាជសីហ៍ជាដើមព្រមទាំងចេះកាត់តផ្សារលោហធាតុដោយទឹកបន្សារផង ។ ខាងសិល្បៈសូនរូបវិញក៏ព្រះសង្ឃចេះធ្វើពុម្ពព្រះពុទ្ធរូប និងពុម្ពផ្សេងៗទៀតតាមត្រូវការ ហើយបោះដោយខ្មុកក៏មាន ដោយលោហធាតុក៏មាន សំណ ស្ពាន់ លង្ហិន សំរិតក៏មានស្និតជារូបភាពមនុស្សសត្វ និងគ្រឿងប្រើប្រាស់យ៉ាងល្អត្រកាល ព្រមទាំងចេះវិធីលាបជ្រលក់ទឹកមាស ប្រាក់ ដែលហៅថា ក្រូមេទៀត ។ សម័យនោះមានតែក្នុងវត្តអារាមទេ ដែលមានអ្នកបច្ចេកទេសខាងវិចិត្រសិល្បៈ និងមានសម្ភារៈគ្រប់សព្វខាងសិល្បកម្មនេះ ។

ផ្នែកតូរ្យតន្ត្រី = ពិតមែនតែព្រះសង្ឃមិនត្រូវការ ខាងភ្លេងតូរ្យតន្ត្រី របាំរាំច្រៀង ក៏លោកនៅតែជួយឧបត្ថម្ភផ្នែកដែរព្រោះនៅក្នុងស្រុកភូមិសម័យនោះគ្មានមូលដ្ឋានទ្រទ្រង់ឡើយ ។

អាស្រ័យហេតុនេះ ទើបគ្រប់វត្តអារាមទាំងអស់ សុទ្ធតែមានវង់ភ្លេងប្រចាំវត្ត ដូចជាភ្លេងពិណពាទ្យ ឆៃយ៉ាំ ជាដើម ។ ក្រុមពុទ្ធបរិស័ទជើងវត្ត ដែលជំនាញខាងតូរ្យតន្ត្រី លោកគ្រូចៅអធិការតែងហៅយកមកទំនុកបំរុងឱ្យធ្វើគ្រូបង្ហាត់គ្នីគ្នាក្នុងវត្តៗមក ។ ឯគ្រឿងសម្ភារៈតូរ្យតន្ត្រីទាំងអស់ដូចជាស្គរសម្ភោរ រនាត គង ស្រឡៃ ជាដើម សុទ្ធតែលោកគ្រូផ្ដលមធ្យោបាយឱ្យធ្វើក្នុងវត្តទុកដាក់នៅក្នុងវត្ត គ្រាន់តែប្រគល់សិទ្ធឱ្យគ្រហស្ថជាគ្រូភ្លេងនោះកាន់កាប់ថែរក្សា បើមានគេជួលទៅប្រគំនៅទីណា, ពួកតន្ត្រីករនោះអាចយកកម្រៃផ្ទាល់ខ្លួនបាន ចំពោះវត្តអារាមមិនត្រូវការអ្វីឡើយ ។

វត្តអារាមសម័យនោះមិនគ្រាន់តែជួយឧបត្ថម្ភខាងភ្លេងតូរ្យតន្ត្រីប៉ុណ្ណោះទេ បានជួយពួកតន្ត្រីករ ឱ្យបង្កើតជារបាំប្រជាប្រិយទៀតដូចជា ល្ខោន យីកេ អាយ៉ៃគ្រុជិ អាយ៉ៃ និង ចំរៀងចាប៉ីជាដើម ។ កាលបើបានហាត់រៀន ចេះដឹង ហើយគេយកនាមវត្តអារាមរបស់គេមកឱ្យឈ្មោះវង់ភ្លេង វង់របាំគេថាវង់ភ្លេង វត្តនេះវត្តនោះ វង់ល្ខោន យីកេ វត្តនេះវត្តនោះ តាមទំលាប់ក្នុងសម័យនេះ ។

លុះដល់មកសម័យចំរើនលូតលាស់ អង្គការវិចិត្រសិល្បៈ និងតូរ្យតន្ត្រី បានចេញពីវត្តអារាម ទៅនៅក្នុងស្រុកភូមិ រដ្ឋបានទំនុកបំរុងរួមបញ្ចូលទៅក្នុងក្រសួងអប់រំជាតិ ដោយមានវិជ្ជាវិចិត្រសិល្បៈ និងតូរ្យតន្ត្រីអន្តរជាតិតាមសម័យនិយមផ្សំជាមួយផង ។

ទោះបីអង្គការនោះ បានទទួលវឌ្ឍនធមិរដ្ឋហើយ ក៏ព្រះសង្ឃគ្រប់វត្តអារាមនៅតែជួយឧបត្ថម្ភមិនលះបង់ឡើយ ថែមទាំងជួយពួកសិស្សដែលនៅរៀនវិជ្ជាផ្នែកនេះ ក្នុងសាលារដ្ឋឱ្យសំណាក់ដេកនៅបាយទឹកក្នុងវត្តជាច្រើនរយនាក់ក្នុងមួយឆ្នាំ ។

នេះជាសក្ខីភាពមួយទៀត បញ្ជាក់ឱ្យឃើញច្បាស់ថាព្រះពុទ្ធសាសនា ពិតជាសាសនារបស់រដ្ឋកម្ពុជាមែន ។

## ឈ- វត្តនិងអង្គការ ការពារប្រទេស

ក្នុងសតវត្សរ៍មុន ដែលប្រទេសកំពុងរីកវរ កើតសង្គ្រាមប្រជពលរដ្ឋ និងយោធាជាតិ តែងនាំគ្នាទៅហាត់រៀនវិជ្ជាយុទ្ធសាស្ត្រក្នុងទីវត្ត-

អារាម ដែលមានព្រះសង្ឃចាស់ទុំធ្លាប់ធ្វើមេទ័ពឬធ្លាប់ចេះយុទ្ធវិធី និងមន្ត អាគមផ្សេងៗដូចជាវិជ្ជាគុណ ដំបង គុនដាវលំពែង បោកចំបាប់ ហក់លោត និងរៀនមន្តអាគម ការពារខ្លួន រៀនវិធីប្រក់ពល នាំទ័ព កលឧបាយសង្គ្រាម ជាដើម ។

ម្យ៉ាងទៀត ដោយវត្តអារាមមានសម្ភារៈខាងជាងដែកស្រាប់ និង មានព្រះសង្ឃចេះក្បួនតំរា ធ្វើដាវលំពែងផង គេតែងនាំគ្នាទៅធ្វើគ្រឿង អាវុធក្នុងទីជិតវត្ត និងសុំអាវយ័ន្ត កន្សែងយ័ន្ត ខ្សែគាថាពីព្រះសង្ឃ ដែលធ្លាប់មានបច្ចេកទេសក្នុងរឿងនេះ ។

លុះដល់មកសម័យចំរើនលូតលាស់ អង្គការ ការពារប្រទេស បាន ឃ្លាតពីវត្តអារាមទៅនៅក្នុងស្រុកភូមិ កើតជាក្រសួងការពារប្រទេសឡើង ដោយមានវិជ្ជា យុទ្ធសាស្ត្រអន្តរជាតិតាមសម័យនិយម និងគ្រឿងសស្ត្រាវុធ ទំនើបផ្សំជាមួយផង ។

ទោះបីអង្គការនេះបានទទួលវឌ្ឍនធមិ ផ្ទាល់ពីរដ្ឋហើយក៏ព្រះសង្ឃ នៅតែជួយគាំទ្រគ្រប់មធ្យោបាយ តាមលទ្ធភាពដែល អាចជួយបាន ។

នេះជាសក្ខីភាពមួយទៀត បញ្ជាក់ឱ្យឃើញច្បាស់ថា ព្រះពុទ្ធ សាសនា ពិតជាសាសនារបស់រដ្ឋកម្ពុជាមែន ។

## ៣ - វត្តនិងអង្គការឃោសនាការ

ក្នុងសម័យប្រទេសមានគ្រោះថ្នាក់ខ្សោយឥទ្ធិពល អ្នកស្រុកភូមិ ទាំងឡាយ កាលបើចង់ដឹងដំណឹងអ្វីមួយឱ្យបានច្បាស់លាស់ គេតែងនាំគ្នា

ទៅវត្តអារាម សាកសួរលោកគ្រូចៅអធិការនិងព្រះសង្ឃក្នុងវត្ត ព្រោះវត្តអារាមជាសភាជាតិ ឬជាមន្ទីរឃោសនាការរបស់អ្នកស្រុកភូមិ ។ អ្នកណាមានរឿងហេតុអ្វីមានដំណឹងអ្វីប្លែក តែងទៅវត្តពិគ្រោះជាមួយលោកគ្រូចៅអធិការម្ល៉ោះហើយ លោកគ្រូចៅអធិការវត្តមួយៗ តែងដឹងដំណឹងសុខទុក្ខក្នុងភូមិស្រុកគ្រប់សព្វមិនសូវចន្លោះ ដូចជាដំណឹងខាងកសិកម្ម ពាណិជ្ជកម្ម ឧស្សាហកម្ម ដំណឹងបុណ្យទាននិងដំណឹងកើតស្លាប់របស់អ្នកស្រុកភូមិជាដើម ។ ឯដំណឹងនោះច្រើនតែពិតទៀតផង ព្រោះលោកសង្ឃតមមិននិយាយកុហកមិនផ្សាយដំណឹងអកុសល ។ នេះជាការឃោសនាម្យ៉ាង ។

ម្យ៉ាងទៀត ដើម្បីផ្សាយដំណឹងឱ្យដឹងឮ សុះសាយពេញ ស្រុកភូមិព្រះសង្ឃគ្រប់វត្តអារាម បានសន្មតប្រើស្គរជួង គងជាសញ្ញា ។ គ្រាន់តែពេលលោកចូលវិហារសូត្រធម៌ព្រឹកល្ងាចក៏វាយស្គរជួងគង ផ្សាយដំណឹងពេលវេលា ទៀងទាត់ឱ្យអ្នកស្រុកភូមិដឹងឮដែរ ដើម្បីក្រោកទៅប្រកបកិច្ចការឬឈប់សំរាកធ្វើការងារជាដើម ។

បើមានដំណឹងសំខាន់ ដូចជាដំណឹងមហាសន្និបាតប្រជុំគ្នាធ្វើបុណ្យទានធំៗ ដើម្បីស្ថាបនាសមិទ្ធិអ្វីមួយក្នុវត្ត ឬក្រៅវត្ត តែងផ្សាយ ដំណឹងនោះដោយសិល្បនាដកម្មនិងតូរ្យតន្ត្រីមានរបាំត្រុដិ ឆៃយ៉ាំ យីកេជាដើមមានចាត់ជាក្បួនឱ្យអាចារ្យឬចាស់ព្រឹទ្ធាចារ្យដើរមុខ នាំរបាំ ទាំងនោះដើររាំច្រៀង ប្រគំភ្លេង ឃោសនាគគ្រឹកគគ្រេងនៅស្រុកភូមិ ផ្តល់ដំណឹងលើកទឹកចិត្ត បង្កើតសាមគ្គីធម៌ ឱ្យអ្នកភូមិមករួមប្រជុំគ្នានៅទីវត្តអារាម ឬទីណាមួយដើម្បីពួតកំលាំងគ្នាជួយក្នុងកិច្ចការស្ថាបនាសមិទ្ធិនោះៗឱ្យបានសំរេចឆាប់។

ការឃោសនា ដោយសិល្បនាដកម្ម និងតូរ្យតន្ត្រីនេះ មានភស្តុតាងនៅក្នុងចម្រៀងរបាំត្រុដិ និងចំរៀងឆៃយ៉ាំ ពីបុរាណកាលស្រាប់ ។

ការផ្សាយដំណឹងដោយសិល្បៈបែបនេះឯង ដែលជាប់ជាទំនៀមទំលាប់មកដល់សព្វថ្ងៃ នាំគ្នានិយាយថា «ហែ» ដូចជាហែផ្កា ហែព្រះ ហែកឋិននិងហែនាគជាដើម ។ «ការហែ» នេះបានសេចក្តីថា ការឃោសនាផ្សាយដំណឹងហូហែទៅតាមស្រុកភូមិ ឱ្យអ្នកស្រុកភូមិបានដឹងហើយជួយហែហមគឺជួយចោមរោមអបអរដោយកំលាំងកាយ និងសម្ភារៈដើម្បីញ៉ាំងកិច្ចការឱ្យបានសំរេចឆាប់ ។

លុះដល់មកសម័យចំរើនលូតលាស់ អង្គការឃោសនា បានចេញពីវត្តអារាមទៅនៅក្នុងស្រុកភូមិ កើតជាក្រសួងឃោសនាការជាតិឡើងដោយមានវិធីឃោសនាអន្តរជាតិ តាមសម័យនិយម និងមានសម្ភារៈឃោសនាទំនើប ដូចវិទ្យុ ផ្សាយសំលេងឧគ្ឃោសនស័ព្ទផ្សំជាមួយផង ។

ទោះបីអង្គការនេះបានទទួលវឌ្ឍនធម៌ផ្ទាល់ពីរដ្ឋហើយក៏ព្រះសង្ឃគ្រប់វត្តអារាមនៅតែជួយឧបត្ថម្ភពេញទំហឹង មានជួយឃោសនាដោយទេសនាដោយសន្និសីទ ទស្សនាវដ្ដីនិងសៀវភៅក្បួនច្បាប់ជាដើម ដឹកនាំប្រជាពលរដ្ឋឱ្យដំណឹង ពិតតាមទស្សនវិជ្ជា ដើម្បីបណ្ដុះចិត្ត អ្នកជាតិនិយមឱ្យចេះស្រលាញ់ជាតិសាសនា ព្រះរាជបល្ល័ង្ក និង ជួយបង្កើតឱ្យមានមន្ទីរឃោសនាការជាតិ នៅតាមស្រុកភូមិជាដើម ។

នេះជាសក្ខីភាពមួយទៀត បញ្ជាក់ឱ្យឃើញច្បាស់ថាព្រះពុទ្ធសាសនា ពិតជាសាសនារបស់រដ្ឋកម្ពុជាមែន ។

# ៨- វត្តនិងអង្គការយុត្តិធម៌

អង្គការនេះទោះបីក្នុងសម័យទន់ខ្សោយក្តី សម័យចំរើនល្អតលាស់ក្តី វត្តអារាមទាំងអស់ក្នុងប្រទេសកម្ពុជា មានការចាំបាច់ខាងការផ្សាយនិងពង្រីកវឌ្ឍនភាពនៃយុត្តិធម៌ ទៅក្នុងសង្គមខ្មែរតាមទ្រឹស្តីពុទ្ធសាសនា ដើម្បីដឹកនាំពលរដ្ឋឱ្យមានចិត្តគំនិតស្លូតត្រង់ប្រកបដោយគតិបណ្ឌិត ស្គាល់គុណទោសខុសត្រូវបំបាត់ចិត្តកាចសាហាវឃោរឃៅបំពារបំពានលើសិទ្ធិអ្នកដទៃ បង្កើតចិត្តមេត្តាករុណា អាណិតអាសូរមនុស្សសត្វដែលជាចិត្តប្រកបដោយមនុស្សធម៌ សីលធម៌និងអារ្យធម៌គឺ បណ្តុះបណ្តាលយុត្តិធម៌សង្គម ( Justice sociale )ឱ្យរីកដុះដាលក្នុងសង្គមជាតិខ្មែរ ។

អាស្រ័យហេតុនេះ ទើបពលរដ្ឋខ្មែរស្អប់ខ្ពើមអយុត្តិធម៌ការឈ្លោះទាស់គ្នា ។ កាលបើមានរឿងហេតុឈ្លោះទាស់ខ្វែងគំនិតគ្នាកើតឡើងតែងទៅវត្តអារាម ដំណាលរឿងរ៉ាវរបស់ខ្លួនប្រគេនលោកគ្រូចៅអធិការស្តាប់ដោយផ្ទាល់ខ្លួន ឬអ្នកផ្ទះជិតខាងជួយយកអាសា នាំរឿងរ៉ាវទាស់ទៅប្រគេនដំណឹងឱ្យលោកគ្រូជ្រាប សុំឱ្យហៅគូវិវាទទៅវត្ត ដើម្បីផ្សះផ្សាសម្រុះសម្រួលកុំឱ្យកើតក្តីក្តាំនិងគ្នាដល់តុលាការនាំឱ្យខូចខាតពេលវេលាធ្វើការរកស៊ី ។

លោកគ្រូចៅអធិការតែងយកព្រះទ័យទុកដាក់ជួយសម្រួល រឿងទាស់នោះ ឱ្យបានស្រុះស្រួលគ្នាវិញ តាមលទ្ធភាពដែលលោកអាចធ្វើបានតាមវិន័យសិក្ខា ។ ចំណែកខាងគូវិវាទ កាលបើលោកគ្រូរបស់ខ្លួនបានហៅទៅវត្តអារាម ដើម្បីសុំបិណ្ឌបាតរឿងទាស់នោះចោល ហើយក៏មានចិត្តទោរ

ទន់ទាំងពីរខាងខុសត្រូវលើសខ្វះបន្តិចបន្តួចសុខចិត្ត ជាគ្នាវិញដោយរីករាយ នេះជាសក្ខីភាពមួយទៀត បញ្ជាក់ឱ្យឃើញច្បាស់ថាព្រះពុទ្ធសាសនា ពិតជាសាសនារបស់រដ្ឋកម្ពុជាមែន ។

ព្រះពុទ្ធសាសនាមានសក្ខីភាព **ដូចនាំមករ៉ាយរ៉ាប់** យ៉ាងសង្ខេបខាងលើនេះ ឃើញថាមានឧបការគុណ យ៉ាងធំក្រៃលែង ចំពោះប្រទេសកម្ពុជា ចាប់តាំងពីមុនគ្រិស្តសតវត្សរ៍៣០០ឆ្នាំ ដែលប្រជាជនខ្មែរ បានចាប់ផ្តើមសាងខ្លួន ឱ្យកើតជាប្រជាជាតិមួយក្នុងលោក ដរាបមកដល់ប្រទេសកម្ពុជាបានកើតជាកោះសន្តិភាពក្នុងពិភពលោក នាសម័យសង្គមរាស្ត្រនិយម ដែលមានសម្តេចព្រះនរោត្តមសីហនុព្រះប្រមុខរដ្ឋ ជាអគ្គពុទ្ធសាសនូបត្ថម្ភក៏។

ដូច្នេះប្រជាជាតិខ្មែរទាំងអស់ ត្រូវតែដឹងគុណ តបគុណគោរពលើកតម្កើង ថែរក្សាការពារព្រះពុទ្ធសាសនា ដែលជាសាសនារបស់ខ្លួនស្មើជីវិត មិនត្រូវវង្វេងសាសនា មានគំនិតរាក់ត្រចៀកស្រាល ឆាប់ចុះញ៉មចាញ់អារ្យធម៌បរទេសថ្វាយខ្លួនបំរើ មនោគមវិជ្ជាបរទេសឡើយ ។

# វគ្គទី៤

# អំពីវិទ្យាសាស្ត្រ

វិទ្យាសាស្ត្រ ជាវិជ្ជាវិសេសមួយ មានឥទ្ធិពលសម្បើមក្នុងសម័យនេះ។ មនុស្សលោកគ្រប់ប្រទេសជាតិទាំងអស់ កំពុងចាប់អារម្មណ៍ខំស្រូតរូតធ្វើដំណើរតាមវិទ្យាសាស្ត្រនេះ គ្រប់ៗគ្នា ព្រោះបានឃើញឥទ្ធិពល-វិទ្យាសាស្ត្រ ដូចរថយន្ត និងអាកាសយានជាដើម ។

ចំណែកអ្នកវិទ្យាសាស្ត្រវិញ កាលបើដឹងថាមនុស្សលោក បាក់ចិត្តគំនិតតាមឥទ្ធិពលរបស់ខ្លួនហើយ ក៏ខំប្រមូលសកម្មភាព របស់មនុស្សដែលមានក្នុងលោកទាំងប៉ុន្មាន យកមកឱ្យឈ្មោះ ថាវិទ្យាសាស្ត្រទាំងអស់ ហើយតាំងខ្លួនជាអ្នកគ្រប់គ្រងធម្មជាតិចាំទទួលយកផលពីធម្មជាតិគ្រប់មុខ មកបិទផ្លាកថាវិទ្យាសាស្ត្រទាំងអស់ ។ សូម្បីតែមនុស្សធម៌ សីលធម៌ និងអារ្យធម៌ជាដើម ក៏បិទផ្លាកថាវិទ្យាសាស្ត្រដែរ ដរាបដល់ព្រះពុទ្ធសាសនាក៏គេឱ្យឈ្មោះថាវិទ្យាសាស្ត្រទៀត រាប់បញ្ចូលទៅក្នុងសង្គមវិទ្យា (Sociologie) ដែលជាផ្នែកតូចមួយរបស់វិទ្យាសាស្ត្រ ទៅវិញ ។

រួមសេចក្ដីថា គ្រឿងឧបភោគបរិភោគ និងក្បួនច្បាប់ទាំងអស់ណាដែលល្អ ប្រសើរ ថ្លៃថ្លា ត្រឹមត្រូវ ជាទីនិយមរាប់អាន់នៃមនុស្សលោក វត្ថុធាតុទាំងនោះ គេឱ្យឈ្មោះថា ជារបស់វិទ្យាសាស្ត្រទាំងអស់ ។

ដូច្នេះ ពាក្យថាវិទ្យាសាស្ត្រក្នុងសម័យនេះ ត្រឡប់ កើតជាប្រភពនៃចំណេះវិទ្យាក្បួនច្បាប់ និងជាប្រភពនៃសេចក្ដីល្អថ្លៃថ្នូរ ទាំងអស់ក្នុងលោកទៅវិញ ។

តើពាក្យថាវិទ្យាសាស្ត្រនេះគឺអ្វី ? វិទ្យាសាស្ត្រកើតឡើងដោយខ្លួនឯង ឬកើតឡើងដោយសារគេ ?

ដើម្បីដោះស្រាយបញ្ហានេះត្រូវ សិក្សាស្រាវជ្រាវរកឫសគល់ដើមកំណើតវិទ្យាសាស្ត្រនោះ ឱ្យបានឃើញច្បាស់កុំឱ្យភាន់ច្រឡំ គឺរកឱ្យឃើញថាវិទ្យាសាស្ត្រកើតពីណាមក ។

ជាបឋមត្រូវសិក្សាឱ្យស្គាល់ន័យរបស់ពាក្យថាវិទ្យាសាស្ត្រនេះសិន។

តាមសេចក្តីសំរេចរបស់គណៈកម្មការវប្បធម៌ខ្មែរ និងអង្គការខេមរយានកម្ម ដែលជាអង្គការធំមួយ ផ្នែកការសិក្សាភាសា និងអក្សរសាស្ត្រខ្មែរ បានប្រដូចពាក្យថាវិទ្យាសាស្ត្រនេះទៅនឹងពាក្យបារាំងថា ( Science ) មានន័យថា «ចំណេះពិតហើយផ្អែកទៅលើវិចារណញ្ញាណ ចំណេះអ្វីៗជាកំណត់សារព័ន[1] នៃវិជ្ជាផ្អែកទៅលើការសិក្សា ឬសារព័ននៃវិជ្ជាមាននិយាមកា[2] ដែលទាក់ទងចំពោះវត្ថុណាមួយជាកំណត់ » ។

រួមសេចក្តីថា គ្រប់មុខវិជ្ជា ដែលផ្អែកទៅលើវត្ថុធាតុជាគ្រឿងផ្សំឱ្យកើតជាអ្វីមួយហើយ កត់ត្រាជាក្បួនខ្នាតឡើងហៅថាវិទ្យាសាស្ត្រ ។ និយាយឱ្យងាយស្តាប់ថា ក្បួនបង្កើតសម្ភារៈ ឬ ក្បួនសំភីធ្វើការងារដោយយកចិត្តទុកដាក់ពិនិត្យពិច័យ តាមហេតុផល ។ របៀបការងារនោះឈ្មោះថា «វិទ្យាសាស្ត្រ អ្នកធ្វើការងារដោយអាការៈបែបនោះឈ្មោះថា «អ្នកវិទ្យាសាស្ត្រ» ផលិតផល ដែលកើតឡើងពីស្នាដៃអ្នកនោះឈ្មោះថា «ផលិតផលវិទ្យាសាស្ត្រ ឬផលិតផលទំនើប » ។

អាស្រ័យហេតុនេះ ទើបអ្នកប្រាជ្ញវិទ្យាសាស្ត្រ គេប្រមូលកិច្ចការទាំងអស់ដែលគេធ្វើដោយយកចិត្តទុកដាក់ ពិនិត្យហេតុផលនោះដាក់ទៅក្នុងព្រំដែនវិទ្យាសាស្ត្រទាំងអស់ ដូចជាវិជ្ជាដែលកើតឡើង ដោយការពិនិត្យសង្កេត ឱ្យដឹងស្គាល់មេឃផ្កាយ ឈ្មោះថា តារាវិទ្យា ( Astronomie) ។

---

[1] សារព័ន ( Générale ) ទូទៅ គ្រប់សព្វ សារពើ ។

[2] និយាមកា ( Coordonnées ) វត្ថុធាតុជាគ្រឿងផ្សំឱ្យកើតជាចំនុចមួយ

វិជ្ជាដែលកើតឡើង ដោយការពិនិត្យរាវរក ឱ្យចេះដឹងខាងវត្ថុ បុរាណ ឈ្មោះថា បុរាណវត្ថុវិទ្យា ( Archeologie ) ។

វិជ្ជាស្ថានដែលកើតឡើង ដោយការពិនិត្យ សង្កេតខាងទឹក ឈ្មោះថាជលវិទ្យា ( Hydrologie ) ។

-វិជ្ជាដែលកើតឡើង ដោយការពិនិត្យសង្កេតខាងដីឈ្មោះថា ភូគព្ភវិទ្យា ( Géologie ) ។

-វិជ្ជាដែលកើតឡើងដោយការពិនិត្យរាវរក ឱ្យចេះដឹងខាងសមុទ្ទសាគរ ឈ្មោះសាគរវិទ្យា ( Océanographie ) ។

-វិជ្ជាដែលកើតឡើងដោយការពិនិត្យសង្កេត ឱ្យចេះដឹងខាងពិធីការ ឈ្មោះថាវិធីវិទ្យា ( Méthodologie ) ។ល។

ឈ្មោះវិជ្ជាបែបនេះមានច្រើនណាស់គ្មានទីបញ្ចប់ទេ ព្រោះចេះតែកើតមានថែមឡើង តាមល្បឿននៃការពិនិត្យសង្កេតរាវរកឃើញ ។

# ដើមកំណើតវិទ្យាសាស្ត្រ

វិទ្យាសាស្ត្រ ( Science ) កើតចេញមកពីទស្សនវិជ្ជា ( Philosophie ) មានទស្សនវិជ្ជា ជាបិតារបស់ខ្លួន ( La philosophie est le père de la science ) បើទស្សនវិជ្ជាមិនបានកើតមាន ក្នុងលោកទេ វិទ្យាសាស្ត្រក៏គ្មានដែរ ។

ប៉ុន្តែអ្នកប្រាជ្ញវិទ្យាសាស្ត្រសម័យនេះគេបិទឈ្មោះ ទស្សនវិជ្ជាជាបិតារបស់ខ្លួនចោល គេបែរជានិយាយថាវិទ្យាសាស្ត្រ កើតឡើងដោយ

មូលហេតុដូចខាងក្រោមនេះ ÷

១- សង្កេតកម្ម ការពិនិត្យសង្កេតជាកិច្ចសិក្សា ឬការកត់សម្គាល់នូវអ្វីមួយ ( Observation ) ។

២- សម្មតិកម្ម ការសន្មតិស្មាន **ទៅលើអ្វីមួយ** ដែលកំណត់ថា និងមាន ( Hypothèse ) ។

៣- វិសោធនកម្ម ការសាកល្បង ពិសោធរកការពិត តាមគំនិត ( Expérience ) ។

៤- ទ្រឹស្តី ចំណេះពិត ដែលកើតមានក្នុងគំនិតហើយ ចងក្រងជាក្បួនខ្នាតឡើង ( Théorie ) ។

៥- អនុវត្តនាការ ការប្រតិបត្តិមានវិធាន ឬការសំភីធ្វើការងាតាមលំនាំទ្រឹស្តី ( Application ou la pratique ) ។

ឯអ្នកដែលមានសមត្ថភាព អាចប្រតិបត្តិតាមវិធាន តាមលំនាំទ្រឹស្តីនោះ ឈ្មោះអ្នកបច្ចេកទេស ( Technicien ) និងវិស្វករ ( Ingénieur) ។ កាលបើអ្នកទាំងពីរនេះប្រតិបត្តិទៅហើយ មិនបានសំរេចផលល្អតាមលំនាំទ្រឹស្តីដោយមានឧបស័គ្គណាមួយនោះ ត្រូវពិគ្រោះជាមួយម្ចាស់ទ្រឹស្តីនោះទៀត ដើម្បីស្តាប់សេចក្តីពន្យល់ កែសំរួលឱ្យបានសំរេចជារូបរាងមួយឡើង តាមចំណុចទ្រឹស្តី ។ លុះធ្វើបានសំរេចហើយចងក្រងជាក្បួនឡើងឈ្មោះថា វិទ្យាសាស្ត្រ ។

នេះជាមតិរបស់អ្នកវិទ្យាសាស្ត្រក្នុងសម័យនេះឃើញថា បាត់ឈ្មោះទស្សនវិជ្ជាពិតមែន ។

នោះបីអ្នកវិទ្យាសាស្ត្រ គេបំបាត់ឈ្មោះយ៉ាងនេះហើយ ក៏គេនៅមិនទាន់ហ៊ានកែពាក្យថា ទស្សនវិជ្ជា ជាបិតារបស់វិទ្យាសាស្ត្រនោះដែរ ។

ដូច្នេះ ត្រូវវែកញែករកន័យពិតប្រាកដរបស់ពាក្យនេះ តាមគតិយុត្តិធម៌ឱ្យឃើញ ។

## យោបល់អ្នកនិពន្ធ

ជាបឋមសូមលើកយកពាក្យបីម៉ាត់ គឺទស្សនវិជ្ជា តក្កវិជ្ជា និងវិទ្យាសាស្ត្រ មកវែកញែកដូចខាងក្រោមនេះ ។

-វិជ្ជា ឬចំណេះដែលកើតឡើងដោយទស្សនៈ គឺការពិនិត្យសង្កេតរាវរកឃើញនូវវត្ថុធាតុណាមួយហើយបាន ចេះដឹងច្បាស់នូវហេតុបច្ច័យ នៃវត្ថុធាតុនោះ ។

អ្នកមានទស្សនៈបែបនេះ ឈ្មោះថាទស្សនវិទូ ( Philosphe ) ។ ទស្សនវិទូនេះឯងជាអ្នកមានសមត្ថភាពអាចរាវរកនូវហេតុបច្ច័យ នៃវត្ថុធាតុគ្រប់ជំពូក ដែលកប់បិទបាំងនៅក្នុងចិត្តគំនិតជីវិតរូបកាយមនុស្សសត្វនិងក្នុងដី ទឹក ភ្លើង ខ្យល់ អាកាស ព្រៃភ្នំ , ទន្លេ សមុទ្រ លុះឃើញច្បាស់តាមសភាវៈពិតហើយ ចងក្រងបង្កើតជាក្បួនខ្នាតឡើងឈ្មោះទស្សនវិជ្ជា (Philosophie ) ។

- អ្នកត្រិះរិះផ្សំផ្សំហេតុបច្ច័យដែលទស្សនវិទូរកឃើញ នោះបង្កើតឱ្យលេចជារូបរាងពិតប្រាកដឡើងតាមគំនិតប៉ិនប្រសប់របស់ខ្លួនឈ្មោះថា តក្កវិទូ ( Inventeur ឬ logicien ) តក្កវិទូនេះឯងជាអ្នកមានបច្ចេកទេស មាន

ទេពកោសល្យ បង្កើតរបស់ប្លែកៗក្នុងលោកមុនគេ ដូចជាអគ្គិសនី វិទ្យុ រថយន្ត ជាដើម ។ ចំណេះដែលតក្កវិទូបានចេះដឹងត្រិះរិះរកឃើញធ្វើអ្វីៗកើតនោះឯងឈ្មោះតក្កវិជ្ជា ( Logique ) ។ ក្បួនខ្នាតចែងពីវិជ្ជាគ្រប់យ៉ាងដែលទស្សនវិទូនិងតក្កវិទូបានត្រិះរិះរកឃើញបង្កើតឡើងបាននោះឈ្មោះថា ក្បួនវិជ្ជាដែលហៅថា វិទ្យាសាស្ត្រ ( Science ) ។

-វិទ្យាសាស្ត្រនេះ គ្រាន់តែជាឈ្មោះក្បួនវិជ្ជាផ្សេងៗ ដែលទស្សនវិទូ និង តក្កវិទូ បានរាវរកឃើញ និងបានត្រិះរិះផ្សែផ្សំបង្កើតឡើងនោះឯង។

ឯអ្នកដែលគ្រាន់តែរៀនក្បួនខ្នាតធ្វើកិច្ចការតាមក្បួននោះៗ ដូចពួកសិក្ខាកាមទាំងឡាយដែលរៀននូវវិជ្ជាផ្សេងៗ ក្នុងវិទ្យាល័យមហាវិទ្យាល័យ និង សាកលវិទ្យាល័យនានាក្នុងលោក ហើយបានចេះដឹងធ្វើកើតតាមក្បួនវិជ្ជានោះៗឈ្មោះថា អ្នកវិទ្យាសាស្ត្រ, ក្នុងនាមអ្នកវិទ្យាសាស្ត្រនេះមានអ្នកបច្ចេកទេស និង វិស្វករនៅក្នុងនោះផង តាមផ្នែកវិជ្ជាដែលខ្លួនបានរៀនចេះដឹង ។ សូមបញ្ជាក់ថា អ្នកវិទ្យាសាស្ត្រ គឺ អ្នកដែលគ្រាន់តែចេះដឹងធ្វើកើតតាមក្បួនដែលគេបង្កើតហើយស្រាប់ប៉ុណ្ណោះ ។

បើអ្នកវិទ្យាសាស្ត្រនោះឯង មានទស្សនពិសេស អាចរាវឃើញ អ្វីថ្មីផ្សេងដោយឡែកពីក្បួនចាស់ ឈ្មោះថា ទស្សនវិទូទៅវិញ មិនឈ្មោះថា អ្នកវិទ្យាសាស្ត្រទៀតឡើយ ព្រោះជាអ្នកមានទស្សនៈ ។

ម្យ៉ាងទៀត បើអ្នកវិទ្យាសាស្ត្រនោះឯងមានការត្រិះរិះមានបច្ចេកទេសពិសេសអាចផ្សែផ្សំអ្វីៗ តាមគំនិតប្រាជ្ញាប៉ិនប្រសប់របស់ខ្លួន បង្កើតអ្វីៗដែលមិនទាន់មានក្នុងក្បួនចាស់ដូចពួក អ្នកជំនាងខាងអាវកាសសព្វថ្ងៃ

ដែល កំពុងត្រិះរិះបង្កើតយានអវកាសខ្លួនបានទៅដល់ព្រះចន្ទនោះឈ្មោះថា តក្កវិទូទេវិញ ព្រោះជាអ្នកមានតក្កវិជ្ជា ។

សរុបសេចក្តីទៅឃើញថា វិទ្យាសាស្រ្តគ្មានន័យអ្វីជ្រៅឆ្ងាយជាប់ទាក់ទងដល់មុខវិជ្ជាឡើយ គ្រាន់តែឈ្មោះថាក្បួនវិជ្ជាៗទទេប៉ុណ្ណោះ ។

ឯពាក្យថាអ្នកវិទ្យាសាស្រ្តនោះ ក៏មានន័យត្រឹមតែជាអ្នករៀនចេះតាមក្បួនធ្វើកើតតាមក្បួន ដែលមានស្រាប់ហើយប៉ុណ្ណោះ មិនមែនជាអ្នកមានសមត្ថភាពចេះដឹងឯង រកឃើញអ្វីៗខ្លួនឯងនិងធ្វើអ្វីៗ កើតតាមគំនិតខ្លួនឡើយ។

ត្រង់ចំណុចនេះគួរជ្រាបជាពិសេសចំពោះពាក្យ Seience ដែលឈ្មោះខ្មែរយើងឱ្យថាវិទ្យាសាស្រ្តនោះ មិនបាច់ពង្រីកន័យឱ្យវែងឆ្ងាយឡើយ គ្រាន់តែមានន័យខ្លីតាមរូបស័ព្ទថា «ក្បួនវិជ្ជា» នោះត្រឹមត្រូវតាមគតិយុត្តិធម៌ណាស់ ។ ចំពោះពាក្យ Science ដែលអ្នកវិទ្យាសាស្រ្តសម័យនេះពង្រីកន័យឱ្យវែងឆ្ងាយស្រូបយកមុខវិជ្ជាទាំងអស់នោះមិនត្រឹមត្រូវឡើយ ព្រោះរំលោភទៅលើសិទ្ធិរបស់ទស្សនវិជ្ជា និងតក្កវិជ្ជាពេញទី ។

ឯមូលហេតុទាំង ៥ ដែលបាននិយាយហើយខាងដើមគឺ :

១- សង្កេតកម្ម ( Observation )

២- សក្ខិកម្ម ( Hypothèse )

៣- វិសោធនកម្ម ( Expérience )

៤- ទ្រឹស្តី ( Théorie )

៥- អនុវត្តនាការ ( Application ou la pratique )

ដែលអ្នកវិទ្យាសាស្រ្តសម័យនេះថា ជាមូលហេតុនៃវិទ្យាសាស្រ្តនោះ មិនសមហេតុផលឡើយ គឺជាមូលហេតុរបស់ទស្សនវិជ្ជា និងតក្កវិជ្ជា នោះឯង។

ចំពោះពាក្យដែលមនុស្សលោកបច្ចុប្បន្ន នាំគ្នានិយាយបាត់ម៉ាត់ថា «ឥឡូវនេះ អ្នកវិទ្យាសាស្ត្រចេះតែរាវរកឃើញបង្កើតរបស់ប្លែកៗ» នោះជាពាក្យខុស មិនសមហេតុផលឡើយ គួរនាំគ្នានិយាយថា «ទស្សនវិទូ និងតក្កវិទូចេះតែរាវរកឃើញបង្កើតរបស់ប្លែកៗ» ដូច្នេះវិញទើបសមជាង ។ តាមធម្មតា នៃច្បាប់សុជីវធម៌ គេមិនដែលយកឈ្មោះកូនជាងឬឈ្មោះកម្មករមកនិយាយជាត្រីមុខទេ គេតែងយកឈ្មោះមេជាង ឬមេការមកនិយាយ ។ ឯអ្នកវិទ្យាសាស្ត្រនោះគ្រាន់តែជាកូនជាង កូនសម្ពាយ ឬជាកម្មកររបស់ទស្សនវិទូ និងតក្កវិទូប៉ុណ្ណោះ ។

ដោយហេតុមនុស្សលោក នាំគ្នានិយាយខុស យ៉ាងនេះហើយ ទើបអ្នកវិទ្យាសាស្ត្របានចិត្ត នាំគ្នាកែប្រែន័យរបស់ទស្សនវិជ្ជា និងតក្កវិជ្ជាថាគ្រាន់តែជាសាខាផ្នែកមួយរបស់វិទ្យាសាស្ត្រប៉ុណ្ណោះ ដើម្បីបន្ថយអានុភាពវិជ្ជា ទាំងពីរនេះឱ្យតូចទាបជាងខ្លួនទៅវិញ ។

អ្នកវិទ្យាសាស្ត្រថា ទស្សនវិជ្ជា ( Philosophie ) នេះមានន័យត្រឹមតែជាវិទ្យាសាស្ត្របរិយាយពីសត្វមានជីវិត ពីគោលការណ៍ និងពីប្រព័ន្ធដោយឡែក របស់ទស្សនវិទូ ដែលមានល្បីឈ្មោះក្នុងសម័យណាមួយប៉ុណ្ណោះ គឺគេចាត់ទុកទស្សនវិជ្ជា ជា ផ្នែកតូចមួយ របស់វិទ្យាសាស្ត្រទៅវិញដែលមិនសូវជាមានសារៈសំខាន់ប៉ុន្មានក្នុងលោក ។

ចំណែកតក្កវិជ្ជា ( Logigue ) ថាមានន័យត្រឹមតែជាវិទ្យាសាស្ត្រខាងវិចារណកិច្ច ខាងការត្រិះរិះពិចារណាប៉ុណ្ណោះ គ្មាន សកម្មភាពធំដុំឡើយ គឺគេចាត់ទុក ជាសាខាតូចមួយរបស់វិទ្យាសាស្ត្រដែរ ។

ការដែលគេកែប្រែន័យដូច្នេះ គឺដើម្បីដណ្តើមយកចំណេះវិជ្ជា កិច្ចការអំពីទស្សនវិទូនិងតក្កវិទូ ហើយបំបិទឈ្មោះម្ចាស់ដើមចោលប៉ុណ្ណោះឯង។ នេះជាមតិផ្ទាល់របស់ខ្ញុំ ។

មតិនេះគ្រាន់តែជាបទពិចារណាពិសេស របស់ខ្ញុំប៉ុណ្ណោះ ចំពោះមតិទូទៅ គេមិនដែលនឹកភ្នកដល់រឿងនេះសោះឡើយ គេតែងផ្ញើជំនឿទាំងស្រុងតាមតួអក្សរ ដែលហូរចេញពីប៉ាកការបស់អ្នកវិទ្យាសាស្ត្រ គ្រប់វគ្គឃ្លាទាំងអស់ ឥតហ៊ានប្រើគំនិតពិចារណា ឬហើបមាត់និយាយឱ្យខុសពីតួអក្សរគេឡើយ ។

ដើម្បីពិចារណាសាកល្បង រកការពិត តាមមតិខ្ញុំឱ្យបានជ្រៅ ឆ្ងាយបន្តិចទៅទៀត សូមពិនិត្យមើលដំណើរវិវត្តន៍ចំរើនកកើតឡើង និងអានុភាពនៃទស្សនវិជ្ជា និងតក្កវិជ្ជាដូចខាងក្រោមនេះ ។

## វគ្គទី៥

## អំពីទស្សនវិជ្ជា និង តក្កវិជ្ជា

វិជ្ជានេះកើតមានក្នុងលោក ជាយូរអង្វែងហើយ រកទីដើមកំណើតមិនឃើញ ។ សង្គមមនុស្សកើតមានក្នុងលោក ពេលណា ទស្សនវិជ្ជា ក៏កើតមានឡើងពេលនោះដែរ ព្រោះមនុស្សនេះហើយ ដែលមានសតិបញ្ញាមានទស្សនៈអាចចេះស្គាល់នូវហេតុផលបាន ។ ការចេះដឹងស្គាល់រាវរកឃើញនូវហេតុផលក្នុងលោកតាមសច្ចភាពនោះឯង ឈ្មោះទស្សនវិជ្ជា ។

ធម្មតារបស់ពិភពលោក កាលបើមានការកើតចំរើនឡើងហើយ

ត្រូវវិនាសបាត់បង់ទៅវិញជាចាំបាច់ ។ ឯទស្សនវិជ្ជាក៏ដូច្នោះដែរ កាលបើកើតមានចំរើនឡើងហើយតែងតែវិនាសបាត់បង់ទៅវិញ ។

ត្រង់ចំណុចនេះ យើងមិនអាចដឹងបានថា កាលពីមួយម៉ឺន ឬមួយសែនសតវត្សរ៍មុន ទស្សនវិជ្ជា មានលក្ខណៈបែបណា ? ចំរើនរុងរឿងនៅកន្លែងណា ? អ្នកប្រាជ្ញឈ្មោះអ្វី ដែលជាទស្សនវិទូ ល្បីល្បាញក្នុងសម័យនោះបានឡើយ ។

ចំពោះសម័យនេះ យើងអាចដឹងបានត្រឹមសតវត្សរ៍ទី៧ មុនគ.ស ប៉ុណ្ណោះ គឺទស្សនវិជ្ជានៅបស្ចិមប្រទេសកើតមាននៅតាមឆ្នេរសមុទ្រមេឌីទែរ៉ាណេ (Méditerranée) ជាពិសេសនៅប្រទេសក្រិក, ព្រោះក្នុងសតវត្សទី៧ មុនគ.ស នោះជាសម័យពិសេសមួយនៃការលូតលាស់នូវវិជ្ជាសំខាន់ៗនាំអោយកើតមានអ្នកប្រាជ្ញច្រើន ។ មិនត្រឹមតែនៅប្រទេសក្រិកទេ ប្រទេសឥណ្ឌា និងចិន ក៏ចំរើនលូតលាស់ដែរ, ជាពិសេសព្រះអរហន្តសម្មាសម្ពុទ្ធ ជាអគ្គទស្សនវិទូ ជាលោកវិទូក៏ព្រះអង្គឧប្បត្តិកើតក្នុងសម័យនោះដែរ ។

អាស្រ័យអ្នកប្រាជ្ញប្រកបដោយវប្បធម៌ និងអារ្យធម៌តាមប្រពៃណីមានកំរិតខ្ពស់នេះឯង ទើបមានទស្សនៈ អាចរាវរកឃើញទស្សនវិជ្ជា, បានសេចក្តីថា ទស្សនវិជ្ជាបានចាប់ភពកើតឡើងក្នុងពេលណាដែលវប្បធម៌អារ្យធម៌មានកំរិតខ្ពស់ ដោយបានបង្កើតអ្នកប្រាជ្ញសំខាន់ៗឱ្យមានវិចារណញ្ញាណ ភ្ញាក់រលឹកចំពោះខ្លួន ចំពោះបញ្ហាមនុស្ស ។

ម្យ៉ាងទៀតអ្នកប្រាជ្ញដែលបានចេះនូវវិជ្ជាសព្វគ្រប់ ក្នុងជំនាន់អារ្យធម៌របស់ខ្លួន មានទំហំប៉ុណ្ណា, ទស្សនវិជ្ជា ក៏មានទំហំប៉ុណ្ណោះដែរ,

ព្រោះទស្សនវិជ្ជាជាសំយោគវិជ្ជាមានន័យថាវិជ្ជាអំពីវិជ្ជា ឬថាអញ្ញមញ្ញវិជ្ជា គឺវិជ្ជាជាជំនួយវិជ្ជាទៅវិញទៅមក ។ ដូចគណិតវិទ្យា និងតារាវិទ្យា សម័យសតវត្សរ៍ទី៧ មុនគ.ស នោះមិនសូវមានរបៀបស្រួលងាយដូចសម័យនេះទេ ឯទស្សនវិជ្ជានិងតក្កវិជ្ជាសម័យនោះ ក៏នៅទន់ខ្សោយដែររកសច្ចភាពមិនទាន់ឃើញពិតប្រាកដ នៅមានការភាន់ច្រឡំច្រើន ។ ដល់មកសម័យនេះទស្សនវិជ្ជានិងតក្កវិជ្ជាមានកំរិតខ្ពស់ប្រកបដោយសច្ចភាពច្រើន ដារាប ដល់មានទស្សនៈចេះរិះរក មធ្យោបាយធ្វើយាន អវកាសទៅព្រះចន្ទបាន ដោយហេតុទស្សនវិទូ និងតក្កវិទូសម័យនេះបានសិក្សា និងបានដកស្រង់យកទស្សនៈ យកបច្ចេកវិទ្យាសំខាន់ៗរបស់ទស្សនវិទូ តក្កវិទូជំនាន់ដើមមកសម្រិតសសម្រាំងនិងរាវរកបន្ថែមឱ្យមានគុណភាពកាន់តែខ្ពស់ឡើង ។

ឯដើមហេតុ ដែលបណ្ដាលឱ្យទស្សនវិជ្ជា ចាប់កើតមានក្នុងលោកនៅតាមឆ្នេរសមុទ្រមេឌីទែរ៉ាណេ ជាពិសេសនៅប្រទេសហ្វ្រិកនោះ ព្រោះប្រទេសហ្វ្រិកជំនាន់នោះសម្បូរកំពង់ផែ និងអ្នកទេសចរ ជាទីប្រជុំអារ្យធម៌និងវប្បធម៌នានា ។ ពេលក្រោយមកដោយសារចំបាំងនិងការជិះជាន់សង្កត់សង្កិនរបស់ពួករ៉ូម៉ាំងផង ពួកទួរកផងទស្សនវិជ្ជាក៏អនថយពីប្រទេសហ្វ្រិក ។

ក្នុងសតវត្សរ៍ទី ១៣-១៤នៃគ.ស ទស្សនវិជ្ជាបានផ្សាយទៅដល់ប្រទេសបារាំង អង់គ្លេស អាល្លឺម៉ង់ ។ល។ ជនជាតិទាំងនោះបានភ្ញាក់ខ្លួនដោយពន្លឺអ្នកជាតិនិយម ដែលផ្សាយចេញពីទស្សនវិជ្ជាហ្វ្រិក ក៏ខំរើបម្រះចេញពីការសង្កត់សង្កិនរបស់ពួករ៉ូម៉ាំងដែរ ។

ស្មារតីអ្នកជាតិនិយមនេះឯង ជាហេតុមួយនាំឱ្យជនជាតិអឺរ៉ុបខាង

ជើង ភ្ញាក់ពីដេក បើកភ្នែកឈានជើងដើរចេញពីអវិជ្ជា ពីលទ្ធិសាសនាត្រឹស្ដ ហើយខំបង្កើតអារ្យធម៌ វប្បធម៌ជាតិ របស់ខ្លួនជាហេតុនាំឱ្យទស្សនវិជ្ជាល្អួត លាស់ជាលំដាប់តមកដល់សព្វថ្ងៃនេះ ។

## ប្រភេទនៃទស្សនវិជ្ជាក្នុងលោកមាន ២ គឺ :

១- លោកិយ ទស្សនវិជ្ជា ចំណេះដែលកើតឡើងដោយលោកិយបញ្ញា គឺការរាវរកឃើញនូវហេតុបច្ច័យនៃវត្ថុធាតុក្នុងលោក ខុសខ្លះត្រូវខ្លះតាមនិស្ស័យមនុស្សបុថុជ្ជន ។

២- លោកុត្តរទស្សនវិជ្ជា ចំណេះដែលកើតឡើងដោយលោកុត្តបញ្ញា គឺការរាវរកឃើញ នូវហេតុផលនៃវត្ថុធាតុក្នុងលោក ជាបច្ច័យឱ្យរកឃើញនូវអាទិមគ្គ (សោតាបត្តិមគ្គ) តាមនិស្ស័យអរិយបុគ្គល ។

## អំពីលោកិយទស្សនវិជ្ជា

ទស្សនវិជ្ជានេះ គ្មានឯកភាពទេ នៅក្នុងការផ្សងព្រេងនៅឡើយ ព្រោះមិនទាន់មានអ្នកប្រាជ្ញណា អាចចេះដឹងសព្វគ្រប់បាន ចេះតែមានមតិផ្សេងៗគ្នា ប៉ុន្តែកាន់តែចំរើនឡើងជាលំដាប់ដែរ បានរាវរកសច្ចភាពឃើញកាន់តែប្រសើរឡើង ។ ឯមតិផ្សេងៗគ្នានោះដូចខាងក្រោម÷

ខាងចុងសតវត្សរ៍ទី៧មុនគ.ស, នៅប្រទេសក្រិកចាប់ផ្ដើមមានទស្សនវិទូមួយរូបឈ្មោះ Thalès (តាលែះ) ដែលមនុស្សលោកបានចាត់ទុកគាត់ ជាបិតាលោកិយទស្សនវិជ្ជានោះ, គាត់បានផ្ដើមចោទបញ្ហាមួយយ៉ាងសំខាន់ គឺបញ្ហារកមូលធាតុពិភពលោក ។ ចំលើយរបស់គាត់មិនសំអាងទៅ

លើមនោគមវិជ្ជា ក្នុងជំនាន់នោះដែលនិយម អាទិទេពឡើយបែរជាដោះស្រាយតាមទស្សនៈថ្មីរបស់គាត់ថា «ធាតុទឹក ជាមូលធាតុពិភពលោកដោយសំអាងថាគ្រឿងអាហារនិងគ្រាប់ពូជធម្មជាតិនានាដែរ ជាការចាំបាច់សំរាប់ជីវិតនោះ សុទ្ធតែជាវត្ថុមានជាតិសើមជានិច្ច គឺទឹកនោះឯង ។ល។

ចំពោះបញ្ហាដដែលនោះ ទស្សនវិទូ Anaximandre (អណាក់ស៊ីម៉ង់ដ្រឺ) ជាសិស្សរបស់តាលែះ ដែលចូលចិត្តសិក្សាខាងតារាវិទ្យា (Astronomie) ភូមិវិទ្យា (Géographie) និងលោកធាតុវិទ្យា (Cosmologie) ហើយបានផ្តើមគូរបង្កើតមុនគេនូវផែនទីពិភពលោក និងបានបង្កើតឆាយាមាត្រ វាស់ពេលវេលា តាមស្រមោលព្រះអាទិត្យនោះ មានទស្សនៈផ្សេងពីគ្រូរបស់ខ្លួនទៅវិញ «អ្វីៗទាំងអស់ក្នុងពិភពលោក កើតមកពីអនន្តធាតុហើយនៅទីបំផុត ក៏វិលត្រឡប់ទៅរកអនន្តធាតុវិញ ។ល។

អនន្តធាតុនេះ មានទស្សនវិទូជំនាន់ក្រោយ បន្ទាប់ពីរូបគឺលោក Thilly (ទីល្លី) និងលោក Burnet (ប៊ួកណេត៍) បានគាំទ្រ និងអធិប្បាយថា «អនន្តធាតុ គឺជាគំនរធាតុដែលមានជីវិតនៅពាសពេញអាកាសរកទីបំផុតគ្មាន ជារូបធាតុមួយបែបពុំមានលក្ខណៈអាចឱ្យស្គាល់បានដោយឡែកៗពីគ្នាទេ ព្រមទាំងមានវិសាលភាពធំទូលាយគ្មានទីបំផុត» ។ល។

បន្ទាប់ពីទស្សនវិទូអាណាក់ស៊ីម៉ង់ដ្រឺ មានទស្សនវិទូមួយរូបទៀតឈ្មោះ Pythagore (ពីត្តាហ្គរ) និងសហការីរបស់គាត់មិនសូវចាប់អារម្មណ៍ចំពោះបញ្ហាមូលធាតុទេ, គាត់ខំត្រិះរិះដោះស្រាយអំពីបញ្ហារូប និងសម្ពន្ធភាពទៅវិញ ។ល។

- បន្ទាប់មកទៀតទស្សនវិទូឈ្មោះ Anaximène (អាណេហ្សក់ស៊ីម៉ែន) បានយល់ថា មូលធាតុពិភពលោក គឺអាកាសធាតុគាត់ពន្យល់ថាអាកាស មានលក្ខណៈទាំងក្ដៅទាំងត្រជាក់ គឺស្ថិតនៅពាក់កណ្ដាលរវាងធាតុភ្លើងនិង ធាតុទឹក ព្រមទាំងធាតុស្ងួតនិងធាតុសើម ។ ទស្សនៈនេះ គាត់បានរៀបរៀង ជាវិទ្យាវិធីមានរបៀប បែបផែនល្អ ។ល។

បន្ទាប់មកទៀត ទស្សនវិទូឈ្មោះ Héraclite (**អេរ៉ាក្លីត**) បានយល់ ថា «មូលធាតុពិភពលោក គឺធាតុភ្លើង, អ្វីៗទាំងអស់កើតមកពីភ្លើងហើយ វិលត្រឡប់ទៅជាភ្លើងវិញ ។ ភ្លើងជាធាតុមួយដែលអាចផ្លាស់ប្ដូរ ប្រែប្រួល ឆាប់រហ័សជាងធាតុទាំងអស់មិនអាចស្ថិតនៅដដែល អំពីខណៈមួយទៅ ខណៈមួយបានទេ តែងតែឆេះនូវវត្ថុផ្សេងៗ ហើយផ្លាស់ទៅជាផ្សេងជា ចំហាយជាអាកាស ជាទឹក ជាដី នឹងត្រឡប់ផ្លាស់ពីដីច្រាសជាលំដាប់ទៅជា ភ្លើងវិញ» ។ល។

បន្ទាប់មកទៀត ទស្សនវិទូមួយរូបឈ្មោះ Empédocle (អំប៉េដូក) បានយល់ថា «មូលធាតុពិភពលោក គឺធាតុ ៤ គឺទឹក ភ្លើង ខ្យល់ ធាតុទាំង ៤ នេះស្ថិតនៅលាយឡំ គ្នាមិនដាច់ស្រឡះពីគ្នាឡើយ អាកាសមានចំនួន ប៉ុណ្ណា បរិមាណនៃធាតុទាំង៤ ក៏មានប៉ុណ្ណោះដែរ» ។ល។

ដល់មកឆ្នាំ ៤៧០មុនគ.ស ទស្សនវិទូឈ្មោះ Socrate (សូក្រាត) មិនសូវចាប់អារម្មណ៍ចំពោះបញ្ហាចរិយាធម៌ (Ethique) ទៅវិញ ព្រោះគាត់ យល់ថា ទស្សនវិជ្ជាខាងមូលធាតុពិភពលោក ជាវិជ្ជាគ្មានតម្លៃ ឯចរិយាវិទ្យា ខាងវិជ្ជាមនុស្សទើបមានតម្លៃជាង» ។ល។

- បន្ទាប់មកទៀតទស្សនវិទូឈ្មោះ Anaximène (អាណេហ្គស៊ីម៉ែន) បានយល់ថា មូលធាតុពិភពលោក គឺអាកាសធាតុគាត់ពន្យល់ថាអាកាស មានលក្ខណៈទាំងក្តៅទាំងត្រជាក់ គឺស្ថិតនៅពាក់កណ្តាលរវាងធាតុភ្លើងនិង ធាតុទឹក ព្រមទាំងធាតុស្ងួតនិងធាតុសើម ។ ទស្សនៈនេះ គាត់បានរៀបរៀង ជាវិទ្យាវិធីមានរបៀប បែបផែនល្អ ។ល។

បន្ទាប់មកទៀត ទស្សនវិទូឈ្មោះ Héraclite (អេរ៉ាក្លីត) បានយល់ ថា «មូលធាតុពិភពលោក គឺធាតុភ្លើង, អ្វីៗទាំងអស់កើតមកពីភ្លើងហើយ វិលត្រឡប់ទៅជាភ្លើងវិញ ។ ភ្លើងជាធាតុមួយដែលអាចផ្លាស់ប្តូរ ប្រែប្រួល ឆាប់រហ័សជាងធាតុទាំងអស់មិនអាចស្ថិតនៅដដែល អំពីខណៈមួយទៅ ខណៈមួយបានទេ តែងតែឆេះនូវវត្ថុផ្សេងៗ ហើយផ្លាស់ទៅជាផ្សែងជា ចំហាយជាអាកាស ជាទឹក ជាដី នឹងត្រឡប់ផ្លាស់ពីដីច្រាសជាលំដាប់ទៅជា ភ្លើងវិញ» ។ល។

បន្ទាប់មកទៀត ទស្សនវិទូមួយរូបឈ្មោះ Empédocle (អំប៉េដូក) បានយល់ថា «មូលធាតុពិភពលោក គឺធាតុ ៤ គឺទឹក ភ្លើង ខ្យល់ ធាតុទាំង ៤ នេះស្ថិតនៅលាយឡំ គ្នាមិនដាច់ស្រឡះពីគ្នាឡើយ អាកាសមានចំនួន ប៉ុណ្ណា បរិមាណនៃធាតុទាំង៤ ក៏មានប៉ុណ្ណោះដែរ» ។ល។

ដល់មកឆ្នាំ ៤៧០មុនគ.ស ទស្សនវិទូឈ្មោះ Socrate (សូក្រាត) មិនសូវចាប់អារម្មណ៍ចំពោះបញ្ហាចរិយាធម៌ (Ethique) ទៅវិញ ព្រោះគាត់ យល់ថា ទស្សនវិជ្ជាខាងមូលធាតុពិភពលោក ជាវិជ្ជាគ្មានតម្លៃ ឯចរិយាវិទ្យា ខាងវិជ្ជាមនុស្សទើបមានតម្លៃជាង» ។ល។

ដែលនាំយកទស្សនៈខ្លីៗ របស់ទស្សនវិទូក្រិកប៉ុន្មានរូបមកនិយាយនេះ គ្រាន់តែបញ្ជាក់ឱ្យឃើញថា លោកិយទស្សនវិជ្ជា ដែលជាបិតាវិទ្យាសាស្ត្រនោះ គ្មានឯកភាពឡើយ សុទ្ធតែស្ថិតនៅក្នុងការរាវរកដោយស្មានទាំងអស់ មានការត្រូវតិចមានកំហុសច្រើន ។

ទោះជាយ៉ាងនេះក៏ដោយ ទស្សនវិជ្ជារបស់ទស្សនវិទូជំនាន់មុនអាចញ៉ាំងទស្សនវិទូជំនាន់ក្រោយៗរហូតដល់សព្វថ្ងៃនេះ ឱ្យរាវរកសច្ចភាពកាន់តែឃើញច្រើន កាន់តែបង្កើតវិទ្យាសាស្ត្របានច្រើន ដើម្បីប្រយោជន៍ដល់មនុស្សលោក ។

តាមការសង្កេត = ទស្សនវិទូទាំងអស់ តាំងពីសតវត្សរ៍ទី ៧ មុន គ. ស ដរាបមកដល់សតវត្សរ៍ទី ២០ នៃគ. សនេះឃើញមានទស្សនៈសំខាន់មួយផ្នែកៗម្នាក់ក្នុងការរាវរកសច្ច ភាវ សុខៈ ឱ្យមនុស្សលោកគឺ :

- ពួកខ្លះមានទស្សនៈខាង មូលធាតុវិធី ដូចទស្សនវិទូ Thalès (តាលែះ) ជាដើម ។

- ពួកខ្លះមានទស្សនៈខាងសម្ពន្ធភាពវិធី ដូចទស្សនវិទូ Pythagore (ពិក្តាហ្គរ) ជាដើម ។

- ពួកខ្លះមានទស្សនខាងចរិយាវិធីដូចទស្សនវិទូSocrate( សូក្រាត) ជាដើម ។

- ពួកខ្លះមានទស្សនៈខាងបរមណូវិធី ដូចទស្សនវិទូ Démocrite (ដេម៉ូគ្រីត) ជាដើម ។

- ពួកខ្លះ មានទស្សនៈខាង វិទ្យាវិធី ដូចទស្សនវិទូ Descartes

(ដេស្កាត) ជាដើម ។

- ពួកខ្លះមានទស្សនៈខាង សង្គមវិធី ដូចទស្សនវិទូ Lénine (លេនីន) និង Mao tsé toung (ម៉ៅ សេទុង) ជាដើម ។ល។

ចំពោះទស្សនៈខាងវិទ្យាវិធី របស់ទស្សនវិទូ ដេស្កាតនោះជាប្រភពធំនៃវិទ្យាសាស្ត្រ បានបង្កើតនិងពង្រីកវឌ្ឍនភាពខាងវិទ្យាវិធីដែលធ្លាប់មានពីបុរាណកាលខ្លះបង្កើតថ្មីខ្លះឱ្យកើតមានរីកដុះដាលជាលំដាប់ ដរាបដល់សព្វថ្ងៃនេះ ។

ទស្សនវិទូ ដេស្កាត ជាជនជាតិបារាំងដ៏ល្បីល្បាញមួយរូបក្នុងគ្រិស្តសតវត្សទី ១៧ កើតក្នុង គ. ស ១៥៩៦ គាត់បានបង្កើតទស្សនវិជ្ជាទំនើបមួយ មានទំរង់ជាវិធីសាស្ត្រ (Métho dologies) ហើយបានបង្កើតតក្កវិជ្ជាទំនើប (Logigae moderne) ដែលមានឈ្មោះថា តក្កវិជ្ជាបដិយោគនិយម (Logique dialectique) សំរាប់បង្កើតវិធីសិក្សា ការពន្យល់ឱ្យបានច្បាស់លាស់ និងតក្កវិទ្យានិយម (Logique scientifique) ដែលមានការត្រិះរិះពិសោធន៍ អនុវត្តន៍ មានសកម្មភាពទូទៅ និងមានការប្រើសម្ភារៈជាមធ្យោបាយស្វែងរកសច្ចៈភាវៈ សុខឱ្យមនុស្សលោក ហើយនិងតក្កវិជ្ជាមួយបែបទៀតឈ្មោះ Logistique ដែលយក គណិតវិទ្យាមកប្រើជាគ្រឿងឧបករណ៍។

ឯគោលសំខាន់ៗក្នុងតក្កវិជ្ជាទំនើបនេះ លោកដេស្កាតបានអធិប្បាយក្នុងអត្ថបទសំខាន់របស់លោក ដែលមានឈ្មោះថា Discours de la méthode និពន្ធក្នុងគ. ស១៦៣៧ ។ អត្ថបទនោះមាន ៤ វិធី បើបំប្រួញឱ្យខ្លីមកគឺ :

១- សត្រូវឱ្យកំចាត់ចោល នូវជំនឿខុះហេតុផល

២- តំរូវឱ្យធ្វើវិភាគ ដើម្បីឱ្យបានស្គាល់ច្បាស់លាស់នូវវត្ថុធាតុផ្សេងៗ

៣- តំរូវឱ្យចេះសិក្សា ពិចារណា ពន្យល់ចាប់តាំងពីការងារស្រួលដល់ការពិបាក

៤- តំរូវឱ្យចេះវែកញែក ធ្វើប្រភេទគ្រប់វត្ថុធាតុទាំងអស់កុំចន្លោះ ។

តក្កវិជ្ជាទំនើបនេះផ្ទុយនឹងតក្កវិជ្ជារាងនិយម (Logique for helle) របស់ទស្សនវិទូ Aristote (អារិស្តុក) ពីបុរាណសម័យដែលគ្រាន់តែអធិប្បាយផ្សាយរាងរៅខាងក្រៅនៃគំនិតមតិឱ្យមានបែបបទល្អ តាមលំនាំបនៅគមវិជ្ជាចាស់ដែលនិយមអនុភាពក្រៅខ្លួន មានអានុភាព អាទិទេពជាដើម ។

ទោះបីទស្សនះរបស់លោកដេស្កាត៍ ប្រឆាំងនឹងមនោគមវិជ្ជចាស់ដែលនាំឱ្យអ្នកកាន់កាប់អំណាចរជ្ជសម័យនោះ បៀបបៀនឃាត់ឃាំងមិនឱ្យជនជាតិបារាំងជឿតាមទស្សនវិជ្ជាលោកក៏ដោយ មានជនជាតិបារាំងជាច្រើន បានភ្ញាក់រលឹកខំធ្វើពាណិជ្ជកម្ម ទាក់ទង នឹងបរទេស តាមផ្លូវសមុទ្រឆ្ងាយៗកាន់តែច្រើន, ម៉ាស៊ីនបោះពុម្ពក៏បានចំរើនឡើង បណ្តាលឱ្យវប្បធមិជាតិបារាំងចំរើនយ៉ាងខ្លាំង ។

ចំណែកគណិតវិទ្យាលោក ដេស្កាត៍ បានសរសេរ Algèbre និង Géométrie ឱ្យមានរូបរាង ជារបៀបវិទ្យាវិធីច្បាស់លាស់ឡើង ហើយលោកបានសរសេរ Algèbre ភ្ជាប់ទៅនឹង Géométrie ថែមទៀត ដែលមានឈ្មោះថា Géométrie analytique ។ល។

ឃើញថាទស្សនវិជ្ជារបស់លោក ដេស្កាត៍ ដែលប្រកបដោយ តក្កវិជ្ជាទំនើបនេះ បានបង្កើតនិងពង្រីកវិទ្យាសាស្ត្រ (Science) បង្កើត និង បង្កើនអ្នកបច្ចេកទេស (Technicien) និងវិស្វករ (Ingénieur) ឱ្យកើតកាន់តែ ច្រើនឡើង សំរាប់ជាមធ្យោបាយកែប្រែធម្មជាតិ ចិត្តគំនិត ជំនឿ និងជីវភាព មនុស្សឱ្យបានងាយស្រួលចំរើនរុងរឿងជាងសម័យមុន និងបើកផ្លូវឱ្យចំរើន ជាលំដាប់មកដល់សព្វថ្ងៃនេះ ។

ការបង្កើតបង្កើនវិទ្យាសាស្ត្រ មិនមែនទើបនឹងមានត្រឹមពួកទស្សន វិទូដេស្កាត៍នេះឡើយ ពួកទស្សនវិទូទាំងឡាយពីបុរាណកាល ក៏បានផ្តើម បង្កើតវិទ្យាវិធីផ្សេងៗ តាមសមត្ថភាព តាមកាលៈទេសៈដែរ ដូចមាន សមត្ថភាព និងឈ្មោះខាងក្រោមនេះ÷

ក- ទស្សនវិទូក្រិកឈ្មោះ Thalès (តាលែះ) កើតក្នុងឆ្នាំ ៦២៤មុន គ.ស ជាអ្នកប្រាជ្ញខាងគណិតវិទ្យា (Mathématicien) និងខាងតារាវិទ្យា (Astronome) ។ ផ្នែកតារាវិទ្យាគាត់បានផ្តើមទាយថា និងមានចន្ទគ្រាសក្នុង ថ្ងៃ ២ ឧសភា ឆ្នាំ ៥៨៥ គ.ស ដល់ថ្ងៃនោះមានចន្ទគ្រាសដូចទំនាយមែន គួរតែគាត់ទាយខុស ព្រោះគាត់យល់ថា ផែនសំប៉ែតហើយនៅនឹងមួយ កន្លែង ។ បន្ទាប់មកគាត់បានផ្តើមគំនិតបង្កើតទស្សនវិជ្ជាដែលជាបិតានៃ វិទ្យាសាស្ត្រ ដោយបានចោទបញ្ហាមូលធាតុពិភពលោក បើកផ្លូវឱ្យអ្នកប្រាជ្ញ ជំនាន់ក្រោយឱ្យមកដល់សព្វថ្ងៃនេះ មានគំនិតភ្ញាក់រំលឹកចេះគិតគូរពីធម្ម ជាតិគឺ សារនៃធម្មជាតិ និងពីមូលធមិ ដែលអាចបញ្ជាក់បង្ហាញនូវធាតុភូត ទាំងអស់នៃធម្មជាតិ ដើម្បីបង្កើតវត្ថុសិក្សា បង្កើតអខវិទ្យា គឺវិទ្យាសាស្ត្រ ជា

ឃើញថាទស្សនវិជ្ជារបស់លោក ដេស្កាត ដែលប្រកបដោយ តក្កវិជ្ជាទំនើបនេះ បានបង្កើតនិងពង្រីកវិទ្យាសាស្ត្រ (Science) បង្កើត និង បង្កើនអ្នកបច្ចេកទេស (Technicien) និងវិស្វករ (Ingénieur) ឱ្យកើតកាន់តែច្រើនឡើង សំរាប់ជាមធ្យោបាយតែប្រែធម្មជាតិ ចិត្តគំនិត ជំនឿ និងជីវភាព មនុស្សឱ្យបានងាយស្រួលចំរើនរុងរឿងជាងសម័យមុន និងបើកផ្លូវឱ្យចំរើន ជាលំដាប់មកដល់សព្វថ្ងៃនេះ ។

ការបង្កើតបង្កើនវិទ្យាសាស្ត្រ មិនមែនទើបនឹងមានត្រឹមពួកទស្សនវិទូដេស្កាតនេះឡើយ ពួកទស្សនវិទូទាំងឡាយពីបុរាណកាល ក៏បានផ្តើមបង្កើតវិទ្យាវិធីផ្សេងៗ តាមសមត្ថភាព តាមកាលៈទេសៈដែរ ដូចមានសមត្ថភាព និងឈ្មោះខាងក្រោមនេះ ÷

ក- ទស្សនវិទូក្រិកឈ្មោះ Thalès (តាលេះ) កើតក្នុងឆ្នាំ ៦២៤មុន គ.ស ជាអ្នកប្រាជ្ញខាងគណិតវិទ្យា (Mathématicien) និងខាងតារាវិទ្យា (Astronome) ។ ផ្នែកតារាវិទ្យាគាត់បានផ្តើមទាយថា និងមានចន្ទគ្រាសក្នុងថ្ងៃ ២ ឧសភា ឆ្នាំ ៥៨៥ គ.ស ដល់ថ្ងៃនោះមានចន្ទគ្រាសដូចទំនាយមែន គួរតែគាត់ទាយខុស ព្រោះគាត់យល់ថា ផែនសំប៉ែតហើយនៅនឹងមួយកន្លែង ។ បន្ទាប់មកគាត់បានផ្តើមគំនិតបង្កើតទស្សនវិជ្ជាដែលជាបិតានៃវិទ្យាសាស្ត្រ ដោយបានចោទបញ្ហាមូលធាតុពិភពលោក បើកផ្លូវឱ្យអ្នកប្រាជ្ញជំនាន់ក្រោយឱ្យមកដល់សព្វថ្ងៃនេះ មានគំនិតភ្ញាក់រំលឹកចេះគិតគូរពីធម្មជាតិគឺ សារនៃធម្មជាតិ និងពីមូលធមិ ដែលអាចបញ្ជាក់បង្ហាញនូវធាតុភូតទាំងអសនៃធម្មជាតិ ដើម្បីបង្កើតវត្ថុសិក្សា បង្កើតអខវិទ្យា គឺវិទ្យាសាស្ត្រ ជា

ប្រយោជន៍ដល់សេដ្ឋកិច្ច សង្គមកិច្ច និងនយោបាយក្នុងពិភពលោក ។

ខ- ទស្សនវិទូក្រិកឈ្មោះ Anaximandre (អាណាក់ស៊ីម៉ង់ដ្រឺ) កើតក្នុងឆ្នាំ ៦១០មុនគ.ស គាត់បានផ្ដើមគំនិតសិក្សាស្រាវជ្រាវបង្កើតឱ្យបានច្បាស់លាស់ខាងវិស័យតារាវិទ្យា (Astronomie) ភូមិវិទ្យា(Géographie) និងលោកធាតុវិទ្យា (Cosmologie) ដោយបានអធិប្បាយអំពីការវិវត្តន៍នៃពិភពលោក និងសត្វលោកតាមចលនាអនន្តធាតុ ទោះបីទស្សនរបស់គាត់មិនសូវច្បាស់លាស់ ក៏បានផ្ដើមជាមេគំនិតយ៉ាងសំខាន់ទុកអ្នកប្រាជ្ញក្រោយៗមានគំនិតចំពោះវិទ្យាទាំងនេះ ។

គ. ទស្សនវិទូក្រិកឈ្មោះ Pythagore (ពីតាហ្គរ) កើតក្នុងឆ្នាំ ៦៨០ មុនគ.ស ជាអ្នកប្រាជ្ញខាងគណិតវិទ្យា (Mathématician) ខាងរេភាគគណិតវិទ្យា (Géométre) និងខាងតារាវិទ្យា (Astronome) គាត់បានត្រិះរិះបង្កើតប្រភពវិទ្យាសាស្ត្រមួយយ៉ាងសំខាន់ ដោយបានរកឃើញថា ច្បាប់ធម្មជាតិ គេអាចគិតរកឃើញហើយ អធិប្បាយបានដោយគណិតវិទ្យាទស្សនៈនេះជាមូលធមិសំខាន់បំផុត ក្នុងការផ្តួចផ្តើមបង្កើតគីមីវិទ្យា (Chimie) ព្រោះគាត់បានត្រិះរិះរក សម្ពន្ធភាព បរិមាណ (Quanlitative) សំរាប់ធ្វើវិភាគឱ្យដឹងពីខ្នាតមាត្រា នៃវត្ថុធាតុដែលផ្សំបង្កើតជាអង្គណាមួយ និងត្រិះរិះរកសម្ពន្ធភាពលក្ខណៈ (Qualitative) សំរាប់ធ្វើវិភាគឱ្យដឹងគុណសម្បត្តិជាតិនៃវត្ថុដែលផ្សំបង្កើតជាតួអង្គ ។ វិទ្យាគីមីនេះទោះបីទស្សនវិទូពីតាហ្គរ មិនបានរៀបចំជាវិទ្យាវិធីច្បាស់លាស់ក៏បាន ជាគេគំនិតបើកផ្លូវឱ្យអ្នកប្រាជ្ញជំនាន់ក្រោយៗរាវរកបន្ថែមទាល់តែបានឃើញ សព្វគ្រប់ដូចសព្វថ្ងៃនេះ ។

ឃ- ទស្សនវិទូក្រិកឈ្មោះ Anaximène (អាណាក់ស៊ីម៉ែន) កើត ក្នុងឆ្នាំ ៥៥០មុនគ.ស ជាសិស្សអាណាកស៊ីម៉ង់ដ្រ៏ បានបន្តការត្រិះរិះស្រាវជ្រាវខាងលោកធាតុវិទ្យា (Cosmologie) ពីគ្រូគាត់ដោយបានអធិប្បាយអំពីការវិវត្តន៍ នៃពិភពលោក និងសត្វលោកតាមចលនាអាកាសធាតុមានរបៀបទំនើបជាបែបវិទ្យាវិធី បាននិយាយអំពីឃនីករណ៍ (Condensation) គឺដំណើរវិវត្តន៍ចេញពីអាកាសទៅធម្មជាតិផ្សេងៗដែលមានលក្ខណៈធ្ងន់ជាង ឬរឹងជាងអាកាស ដូចជាធាតុខ្យល់ ពពក ទឹកដី ហើយនិងថ្ម អំពី សុក្ខិករណ៍ (Rarefaction) គឺសកម្មភាពបែកខ្ញែក ធ្វើឱ្យស្ងួតស្រាល ញាំងអាកាស ធាតុវិទ្យា (Climatologie) មុនគេបង្អស់ ។

ង- ទស្សនវិទូក្រិកឈ្មោះ Héraclite (អេរ៉ាគ្លីត) កើតក្នុងឆ្នាំ៥៤០ មុនគ.ស ក្នុងអត្ថបទរបស់គាត់ឈ្មោះ On nature ឃើញថា គាត់បានផ្តើមបង្កើតវិទ្យាបីផ្នែកគឺ ខាងរូបសាស្ត្រ (Physique) ខាងចរិយាធម៌ (Ethique) និងខាងនយោបាយ (Polique) ។ ទោះបីគាត់មិនទាន់រៀបជា បែបវិទ្យា វិធីត្រឹមត្រូវក៏បានជាមេគំនិត បើកផ្លូវឱ្យអ្នកប្រាជ្ញជំនាន់ក្រោយមានពន្លឺ ក្នុងវិទ្យាទាំងនេះយ៉ាងច្រើន ។

ច- ទស្សនវិទូក្រិកឈ្មោះ Hérodote (អេរ៉ូដូត) កើតក្នុងឆ្នាំ៤៨៤ មុនគ.ស គាត់បានផ្តើមបង្កើតខាងប្រវត្តិវិទ្យា (Histoireti) មុនគេ ដោយបានធ្វើទេសចរទៅពិនិត្យមើលទេសភាពទឹកដី វិមានប្រាសាទ ជីវភាពមនុស្ស និងឯកសារគ្រប់ទិសទីក្នុងសាកលលោក តាមលទ្ធភាពដែលអាចទៅបាននាសម័យនោះ ។

ឆ- ទស្សនវិទូក្រិកឈ្មោះ Socrate (សូក្រាត) កើតក្នុងឆ្នាំ ៤៧០ មុនគ.ស ក្នុងទស្សនរបស់គាត់ បានបង្ហាញឱ្យឃើញច្បាស់នូវវិធីផ្សេងៗ ដែលគេអាចប្រើ ដើម្បីរកឃើញនូវសច្ចៈ គឺវិធីប្រើតក្កវិជ្ជា (Logique) និងបានរៀបចំបង្កើតនូវចរិយាវិទ្យា (Ethique) មានរបៀបប្រសើរជាងសម័យមុន ។

ជ- ទស្សនវិទូក្រិកពីររូប ឈ្មោះ Platon (ប្លាតុង) កើតក្នុងឆ្នាំ ៤២៨មុនគ.ស និងឈ្មោះ Aristote (អារិស្តុត) កើតក្នុងឆ្នាំ៣៨៤មុនគ.ស ទស្សនវិជ្ជារបស់ទស្សនវិទូទាំងពីររូបនេះ មានលក្ខណៈនិងវិសាលភាពធំទូលាយ បានចោទនិងដោះស្រាយស្ទើរតែគ្រប់បញ្ហាទាំងអស់ នៃទស្សនៈវិជ្ជា ដូចជាបញ្ហាបរមត្ថវិជ្ជា (Métaphysique) ដែលទាក់ទងទៅនឹងសច្ចៈនិងបញ្ហាមនុស្សដែលទាក់ទងទៅនឹងពុទ្ធិ (Connaissance) របស់មនុស្ស យើងនិងវាទៈ (Doctrine) របស់មនុស្សក្នុងពិភពលោក ។ ទស្សនវិទូទាំងពីររូបនេះបានត្រិះរិះបង្កើតនិងរៀបចំឱ្យកើតមានជាទ្រឹស្តី ខាងផ្នែកតក្កវិជ្ជាខាងចរិយាវិទ្យា និងខាងនយោបាយវិទ្យា ទុកជាគំរូបើកផ្លូវគំនិតយ៉ាងសំខាន់ឱ្យអ្នកប្រាជ្ញជំនាន់ក្រោយ ។ល។

ការនាំយកប្រវត្តិខ្លីៗ របស់ទស្សនវិទូជំនាន់ចាស់ប៉ុន្មានរូបខាងលើនេះមកបង្ហាញដើម្បីឱ្យឃើញថា ពួកទស្សនៈវិទូសម័យបុរាណតាំងពីមុនគ.សរាប់រយឆ្នាំនេះ សុទ្ធតែជាអ្នកត្រិះរិះរាវរកបង្កើតវិទ្យាសាស្ត្រគ្រប់ៗគ្នា ខំសន្សំប្រមូលវិទ្យាទុកជាមតិកឱ្យអ្នកប្រាជ្ញជំនាន់ក្រោយ មានគំនិតប្រាជ្ញចេះត្រិះរិះរាវរកតៗមកទៀត ។

ឯអ្នកប្រាជ្ញជំនាន់ក្រោយ គឺអ្នកប្រាជ្ញដែលកើតមានក្នុងគ. សតវត្ស ពីសតវត្សរ៍ទី១ នៃគ. សមកដល់សព្វថ្ងៃនេះ ក៏ចេះតែខំត្រិះរិះរាវរក បន្ថែមនូវវិទ្យាថ្មីៗខ្លះ កែទម្រង់វិទ្យាចាស់ខ្លះដើម្បីបង្កើតវឌ្ឍនភាពខាងវិទ្យាសាស្ត្រ ឱ្យកាន់តែរីកចំរើនឡើងជាលំដាប់ដូចជា ÷

ក- លោក Christophe colomb (គ្រិស្តុហ្វកូឡុម) ជាតិអ៊ីតាលី កើតក្នុងគ. ស១៤៥១ បានស្វះស្វែងរាវរកឃើញនូវផែនដីមានរាងមូល និងជាអ្នករាវរកឃើញនូវទ្វីបប្រទេសកោះមនុស្សជាតិសាសន៍នានា ដែលមានក្នុងពិភពលោកមុនគេជាពិសេសបានរកឃើញ នូវទ្វីបអាមេរិកដោយការធ្វើដំណើរផ្សងព្រេងតាមនាវា ឆ្លងមហាសមុទ្របានមួយជុំផែនដី ។ លោកជាតក្កវិទូ (Inventeur) មួយរូបក្នុងផ្នែកភូមិវិទ្យា (Géographie) នេះ ទោះបីគាត់រាវរកមិនទាន់ បានឃើញសព្វគ្រប់ ក៏បានជាពូជគំនិត កើតមានជាប់រហូតមកដល់សព្វថ្ងៃនេះ ។

ខ- លោក Copernic (កូពែកនិក) ជាតិប៉ូឡូញ កើតក្នុងគ. ស ១៤៤៧ ជាតារាវិទូ (Astronome) បានត្រិះរិះរកឃើញនូវចលនានៃផ្កាយព្រះគ្រោះទាំងឡាយ (Plonêtes) ដែលវិលជុំវិញព្រះអាទិត្យ ដោយបានសិក្សាស្រាវជ្រាវតាមទ្រឹស្តី ទស្សនវិជ្ជារបស់លោក Aritarque (អារិស្តាក) ជាតិក្រិក កើតក្នុងឆ្នាំ ៣១០ មុនគ. ស ។ ក្នុងទ្រឹស្តីនោះនិយាយ ព្រះអាទិត្យស្ថិតនៅនឹង, ឯផែនដី ព្រះចន្ទនិងផ្កាយទាំងឡាយវិលជុំវិញព្រះអាទិត្យ ។ លោកកូពែកនិក ជាតក្កវិទូមួយរូប ក្នុងផ្នែកវិទ្យានេះ ។

គ- លោក Galilée (ហ្គាលីឡេ) ជាតិអ៊ីតាលី កើតក្នុង គ. ស

១៥៦៤ ជាគណិតវិទូ (Mathématicien) ជារូបសាស្ត្រវិទូ (Physicien) និងជាតារាវិទូ (Astronome) លោកបានត្រិះរិះឃើញធ្វើនូវរង្វាស់សីតុណ្ហភាព (Thermometre) រកឃើញនូវជញ្ជីងយន្តថ្លឹងថាមពលនៃទម្ងន់ (Balance hydrostaiique) និងបានបង្កើតកែវយិតមើលឆ្ងាយ (Télescope) តាមប្រព័ន្ធ (Système) របស់លោកកូពែកិនីក ។ លោកហ្គាលីឡេជាតក្កវិទូមួយរូបខាងវិទ្យាទាំង៤មុខនេះ ។

ឃ- លោក Kalilao (កាលីលោ) ជាតិអ៊ីតាលី កើតក្នុងគ. ស ១៥៦៥ ជាគណិតវិទូ, និងតារាវិទូ បានត្រិះរិះធ្វើកែវអតិសុខុមទស្សន៍ (Microscope) និងកែវយិតមើលឆ្ងាយ (Télescope) មានប្រសិទ្ធិភាពយ៉ាងសំខាន់ អាចមើលបានឆ្ងាយហើយច្បាស់ មិនឃើញរូបដាំក្បាលចុះក្រោមដូចកែវយិតដែលជនជាតិហូល្លង់ដេប្រឌិតធ្វើពីសម័យមុន និងកែវយិតរបស់លោកហ្គាលីឡេនោះឡើយ ។ លោកកាលិលោ បានមើលទៅព្រះចន្ទតាមកែវយិតរបស់ខ្លួន ឃើញផ្ទៃដួងច័ន្ទរដិបរដុបមានភ្នំខ្ពស់ៗមិនរាបស្មើ ឯតារាទាំងឡាយក៏ឃើញមានច្រើនជាង មើលដោយភ្នែកធម្មតា ។ លោកជាតក្កវិទូមួយរូបបានបើកសករាជថ្មីនៃតារាវិទ្យាយ៉ាងច្បាស់លាស់ជាហេតុឱ្យអ្នកព្រាជ្ញជំនាន់ក្រោយមានមធ្យោបាយត្រិះរិះធ្វើកាំជ្រួចហោះទៅព្រះចន្ទបាន ។

ង- លោក Pascal (ប៉ាស្កាល់) ជាតិបារាំង កើតក្នុងគ. ស ១៦៤៦ ជាទស្សនវិទូ ជារូបសាស្ត្រវិទូ និងជារេខាគណិតវិទូ លោកបានត្រិះរិះរកឃើញ ហើយបង្កើតនូវ ម៉ាស៊ីនគិតលេខ ( Macoine á calculer) និងបានបង្កើតក្បួនខ្នាតជាច្រើន មានក្បួននិយាយអំពីសម្ពាធជាបច្ច័យដល់បរិយាកាស

ផែនដី ( Pression atmosphèriqne ) អំពីសម្ពាធនៃជលគតិវិទ្យា (Pression hydraulique) អំពីសមតានៃលិនធាតុ (L'équilibre des liquides) អំពីត្រីកោណនៃលេខគណិត (Triangle arithmétique) និងទ្រឹស្តីនៃចលនាវិល (Théorie de la roulette) ។ល។

ច- លោក Stephenson (ស្ទិបហ្វិនសុន) ជនជាតិអង់គ្លេសកើតក្នុងគ. ស ១៧៨១ ជាវិស្វករ (Ingénieur) បានត្រិះរិះបង្កើតអយស្ម័យយានមុនគេក្នុងប្រទេសអង់គ្លេស ។ លោកជាតក្កវិទូមួយរូប ខាងការបង្កើតអយស្ម័យយាននេះ ។

ឆ- លោក Ohm (អូម) ជាតិអាល្លឺម៉ង់ កើតក្នុងគ. ស១៧៨៩ ជារូបសាស្ត្រវិទូ បានត្រិះរិះរកឃើញហើយបង្កើតនូវចរន្តអគ្គិសនី (Courant électrique) មុនគេ ។ លោកជាតក្កវិទូមួយរូបខាងវិទ្យានេះ ។

ជ- គ្រូពេទ្យ Pasteur (ប៉ាស្ទ័រ) ជាតិបារាំងកើតក្នុងគ. ស១៨២២ ជាគីមីវិទូ (Chimiste) និងជាជីវសាស្ត្រវិទូ (Biologite) បានរកឃើញថ្នាំការពារទប់នឹងជម្ងឺឆ្កែឆ្កួត (Le vaccin contre la rage) កាលគាត់រកឃើញថ្នាំនេះ មានកុមារជាតិបារាំងម្នាក់ត្រូវឆ្កែឆ្កួតខាំជាច្រើនកន្លែង គេអស់សង្ឃឹមគ្រប់គ្នាក្នុងពេលនេះ មានមនុស្សម្នាក់ស្គាល់គ្រូពេទ្យប៉ាស្ទ័របាននាំកុមាររបួសនោះទៅឱ្យគាត់ព្យាបាលបានដូចបំណង ។ គាត់មានកេរ្តិ៍ឈ្មោះល្បីដោយសាររឿងនេះ ។ តមកគាត់បានត្រិះរិះរកថ្នាំកែរោគដទៃទៀតដូចជាអាសន្នរោគរបេងជាដើម ។ គាត់បានរកឃើញការប្រើក៏រិតកំដៅសំរាប់បូតិកា (Levibrionseptique) គឺការស្ងោរសំលាប់មេក្រុមីជូរផ្អូមដែលមានក្នុងទឹក

ដោះនិងស្រាទំពាំងបាយជូរជាដើម ។ គាត់រកឃើញមេក្រមីឬអតិសុខុមប្រាណមានពីរប្រភេទគឺជាមេរោគផ្សេងៗ មានរោគគ្រុនមួលជាដើម១ ជាមេក្រមីជូរផ្អូមហៅថា Jist ដែលជួយឱ្យនំប៉័ងប៊ីយ៉ែរ ទឹកក្រូច និងស្រាទំពាំងបាយជូរកើតពពុះ១ ។ គាត់រកឃើញវិធីការពារថា ដើម្បីកុំឱ្យទឹកដោះជូរផ្អូមត្រូវកំដៅទឹកដោះឱ្យក្ដៅដល់ក៏រិត ៦០អង្សា ដើម្បីឱ្យស្រាទំពាំងបាយជូរមានរសជាតិឆ្ងាញ់ កុំឱ្យជូរផ្អូមត្រូវកំដៅឱ្យក្ដៅក៏រិត៥៥អង្សា តមកទៀតគាត់បានត្រិះរិះរកឃើញ ថ្នាំការពារទល់នឹងបង្ការរោគបសុសត្វ (Le vaccin contre le charbon) គឺរោគឆ្លងម៉្យាងខាងបសុសត្វធ្វើឱ្យខ្លួនសត្វ មានចំណុចខ្មៅខ្មោចជុំៗ (ជម្ងឺអុតសត្វ) ។ គ្រូពេទ្យប៉ាស្ទ័រជាតក្កវិទូមួយរូបខាងវិជ្ជាពេទ្យផ្នែកនេះ ។

ឈ- គ្រូពេទ្យ Calmette (កាល់ម៉ិត) ជាតិបារាំងកើតក្នុងគ.ស ១៩៦៣ ជាអតិសុខុមប្រាណវិទូ (Bactériologist) បានត្រិះរិះរកឃើញថ្នាំបង្ការទល់នឹងរោគរបេង (Antituberculeux) ឈ្មោះ BCG ។ លោកជាតក្កវិទូមួយរូបខាងវិជ្ជាពេទ្យផ្នែកនេះ ។

ញ- លោក Marconi (ម៉ាកូនី) ជាតិអ៊ីតាលីកើតក្នុងគ.ស១៨៧៤ ជារូបសាស្ត្រវិទូ គាត់បានរៀនចេះដឹងខាងវិជ្ជាអគ្គិសនីតាមក្បួនថាអាចបញ្ជូន ថាមពលអគ្គិសនី ពីដុំដែក១ទៅដុំដែក១ទៀតបានមិនបាច់ប្រើខ្សែបន្តព្រោះនៅក្នុងអាកាសមានធាតុម៉្យាងឈ្មោះអេទែរ (Ether) អាចនាំថាមពលអគ្គិសនី ឱ្យដើរទៅតាមអាកាសបាន ។

អាស្រ័យហេតុនេះ លោកម៉ាកូនី បានត្រិះរិះរកឃើញផ្ទាល់ខ្លួនថា

អាចប្រើថាមពលអគ្គិសនី ឱ្យនាំលំលេងទៅកាន់ទីឆ្ងាយបានមិនបាច់ប្រើខ្សែបន្ត គ្រាន់តែធ្វើប្រដាប់បញ្ជូន និងប្រដាប់ទទួលប៉ុណ្ណោះ មិនយូរប៉ុន្មានគាត់អាចបង្កើតវិទ្យុ (Radio) បានដូចបំណង ។ លោកម៉ាកូនីជាតក្កវិទូមួយរូបខាងវិជ្ជាវិទ្យុនេះ ។

ប្រវត្តខ្លីៗរបស់អ្នកប្រាជ្ញទាំងឡាយ ក្នុងសម័យមុនគ. ស និងក្នុងគ. ស ដែលនាំមកជានិទស្សននេះ ជាសក្ខីភាពបញ្ជាក់ឱ្យឃើញសាជាថ្មីថា វិទ្យាសាស្ត្រ គ្រាន់តែជាឈ្មោះក្បួនវិទ្យាដែលទស្សនវិទូ និងតក្កវិទូក្នុងអតីត និងបច្ចុប្បន្នបានត្រិះរិះរាវរកបង្កបង្កើតឱ្យមានឡើង ។ ឯអ្នកវិទ្យាសាស្ត្រគ្រាន់តែជាអ្នករៀនបានចេះដឹងតាមក្បួនប៉ុណ្ណោះ ។ បើបានរៀនចេះដឹងហើយមានគំនិតចេះត្រិះរិះរាវរកបង្កើតអ្វីប្លែក ពីក្បួនដែលខ្លួនបានរៀននោះមាននាមថា ទស្សនវិទូ ឬតក្កវិទូទៅវិញ មិនឈ្មោះថាអ្នក វិទ្យាសាស្ត្រទៀតឡើយ ព្រោះមានចំណេះពិសេស ខ្ពស់ហួសពីអ្នកវិទ្យាសាស្ត្រធម្មតា ដែលគ្រាន់តែចេះដឹង ធ្វើកើតតាមក្បួនគេស្រាប់ ។

## អំពីលោកុត្តរទស្សនវិទ្យា

ជាបឋមសូមបញ្ជាក់អំពីពាក្យថា លោកុត្តរៈ នេះសិនព្រោះមានអ្នកខ្លះស្តាប់ឮប្រទ្បីថា លោកខាងមុខ បរលោកគឺលោកដទៃផ្សេងពីពិភពលោកនេះ ខ្លះទៀតស្តាប់បានថា ព្រោះនិព្វាន លឿនហួសដល់ទៅថ្នាក់ខ្ពស់ជាកំពូលតែម្តង រំលងថ្នាក់ក្រោយអស់ ។ ការស្តាប់បានហួសនេះឯង ដែលនាំឱ្យព្រះពុទ្ធសាសនា ជាសាសនាប្រចាំពិភពលោកនោះ គ្មានន័យក្នុងលោក

ទៅវិញ មកពីធ្លាប់ដឹងថាលោកកុត្តរៈធម៌គឺមគ្គ ៤ ផល៤ និព្វាន ១ ។

លោកុត្តរៈ «លោក + ឧត្តរ ។ លោកគឺពិភពលោកនេះឯងដែលមានមនុស្ស សត្វ ដី ទឹក ភ្លើង ខ្យល់ នៅខាងក្នុង ។ ឧត្តរ គឺឆ្លងប្រសើរក្រៃលែង ។ល។ រួមចូលគ្នាថា ឆ្លងលោកប្រសើរក្នុងលោក ក្រៃលែងក្នុងលោក លៃតាមដំណើរសេចក្ដី ដូចក្នុងន័យលោកុត្តរទស្សនវិជ្ជានេះ បានសេចក្ដីថាទស្សនវិជ្ជាសំរាប់ឆ្លងលោកគឺឆ្លងសេចក្ដីល្ងង់ខ្លៅ ការជិះជាន់ ទុក្ខសោកក្រខ្សត់ ឈឺស្លាប់ ទស្សនវិជ្ជាប្រសើរក្នុងលោក ទស្សនវិជ្ជាក្រៃលែង ជាងទស្សនវិជ្ជាទាំងអស់ក្នុងលោក ។

លោកុត្តរទស្សនវិជ្ជានេះ ជាពុទ្ធសាសនា (Bouddhisme) ឬទ្រឹស្ដីលោក (Théerie du monde) ។

ពុទ្ធសាសនា ឬទ្រឹស្ដីលោក គឺកុត្តរទស្សនវិជ្ជានេះជាប្រាកដនិយម [១] (Réclisme) ឬជាធម្មជាតិនិយម [២] (Naturglisme) មានភាពពិតប្រាកដចំពោះជីវភាព និងពិភពលោក បើចំពោះវត្ថុជា យថាវត្ថុនិយម [១] (Objectivisme) មិនមែនជាទុទិដ្ឋិនិយម [២] (Pessimisme) និងមិនមែនជាសុទិដ្ឋិនិយម [៣] (Optimisme) ឡើយ ។

---

(១) និន្នាការនៃជនដែលនិយាយពីធម្មជាតិតាមរូបដែលមានពិត ។

(២) និន្នាការនៃជនដែលទុកធម្មជាតិជាគោលការណ៍ ស្របគ្នានិងប្រាកដនិយម ។

(១) និន្នាការនៃជនដែលនិយាយពីកម្មវិស័យនៃវត្ថុអ្វីៗដែលភ្នែកឃើញវិញ្ញាណដឹងបាន ។

(២) និន្នាការនៃជនដែលឃើញតែខាងអាក្រក់ៗ ។

(៣) និន្នាការនៃជនដែលឃើញតែខាងល្អៗ ។

ព្រោះទ្រឹស្ដីពុទ្ធសាសនានេះ និយាយតែអំពីសេចក្ដីពិតរបស់ធម្មជាតិ អំពីហេតុបច្ច័យនៃធម្មជាតិ និងអំពីចលនានៃធម្មជាតិ គឺកម្មផលប៉ុណ្ណោះ មិនបាននិយាយតាមលទ្ធ ឬវាទៈរបស់គ្រូអាចារ្យណា ឬអំពីអានុភាពនៃអាទិទេពណាឡើយ ។

ពាក្យធម្មជាតិក្នុងទ្រឹស្ដីពុទ្ធសាសនានេះ មិនមែនមានន័យដូចក្នុងវិទ្យាសាស្ត្រធម្មជាតិ (Science naturelle) នោះទេ គឺមានអត្ថន័យធំទូលាយបានដល់ពិភពលោកទាំងមូល ។

លោកុត្តរទស្សនវិជ្ជា គឺពុទ្ធសាសនានេះ ជាទស្សនវិជ្ជាមានរបៀបមានវត្ថុសិក្សាត្រឹមត្រូវចប់ចុងចប់ដើម មានឯកភាពជាវិទ្យាវិធីតាមសង្កាត់ជាន់ថ្នាក់ ដែលហៅសរុប តាមពាក្យបច្ចេកទេសសំរាប់ប្រើក្នុងទស្សវិជ្ជានេះថាព្រះត្រៃបិដក គឺព្រះសូត្រ ព្រះវិន័យ ព្រះអភិធម្ម មិនមែនជាទស្សនវិជ្ជានៅផ្សងព្រេងកំពុងតែដេកនឹកគិត រាវរកបង្កើតបន្ថែមដូចលោកិយទស្សនវិជ្ជាដែលជាបិតាវិទ្យាសាស្ត្រនោះឡើយ ។

ទ្រឹស្ដីក្នុងលោកុត្តរទស្សនវិជ្ជានេះ បើបំប្រួញឱ្យខ្លីជាងពាក្យថាព្រះត្រៃបិដកនោះមកទៀត នៅតែមួយម៉ាត់ថា «ធម៌» ដែលប្រែជាច្បាប់ ជាធម្មជាតិ ថាសភាវៈទ្រទ្រង់លោក ។ល។ ដូចះបានអធិប្បាយហើយក្នុងទំព័រទី ១ នៃសៀវភៅនេះ ។

ពាក្យថាធម៌នេះ ចែកជាវិធីសិក្សា (Méthode) មាន៣គឺ :

១- វិធីសិក្សាហ្វឹកហាត់ បង្កើតឧត្តមភាពចរិយាឈ្មោះថាសីលសិក្ខា

២- វិធីសិក្សាហ្វឹកហាត់បង្កើតឯកភាពចិត្ត ឈ្មោះថាចិត្តសិក្ខា ។

៣-វិធីសិក្សាហ្វឹកហាត់ បង្កើតសមត្ថភាពបញ្ញា ឈ្មោះថាបញ្ញាសិក្ខា ។

វិធីសិក្សាទាំងអស់នេះ មិនមែនជាវាទៈ (Doctrine) មិនមែនជាទិដ្ឋិ (Dogme) មិនមែនជាលទ្ធិ (Religion) របស់ព្រះសម្ពុទ្ធគ្រប់អង្គរបស់អាទិទេព ឬរបស់បុរស បុគ្គលណាមួយឡើយ គឺជាទ្រឹស្តីលោកជាពុទ្ធសាសនា ព្រះសម្ពុទ្ធទាំងឡាយគ្រាន់តែមានប្រាជ្ញាញាណ អាចរាវរកឃើញត្រាស់ដឹងបានប៉ុណ្ណោះ ។

វិធិសិក្សាទាំងអស់នេះ ប្រកបដោយសច្ចៈរួមចុះក្នុងសច្ចៈ៤ដែលហៅថាចតុរារិយសច្ច ឬអរិយសច្ចៈ (Les nobles vérités) ជាសច្ចៈដ៏ប្រសើរខ្ពង់ខ្ពស់ពិតប្រាកដក្នុងលោកផ្ទុយពីបុថុជ្ជនសច្ច (Profane vérité) គឺសច្ចៈបណ្តោះអាសន្ននៅមានប្រែប្រួលដែលជាសច្ចៈក្នុងលោកិយទស្សនវិជ្ជា ។

## អរិយសច្ចៈ ៤ គឺ

១- ទុកសច្ចៈ ទុក្ខជាសេចក្តីពិត

២- សមុទយសច្ចៈ ហេតុនៃទុក្ខជាសេចក្តីពិត

៣- និរោធសច្ចៈ ការបំបាត់ទុក្ខជាសេចក្តីពិត

៤- មគ្គសច្ច ផ្លូវប្រតិ្តបត្តិបំបាត់ទុក្ខជាសេចក្តីពិត ។

អរិយសច្ចៈទាំងួននេះ ជាទីប្រជុំចុះនៃធមិទាំង៨ម៉ឺន៤ពាន់ធម្មក្ខន្ធ ដែលព្រះសម្ពុទ្ធសំដែងក្នុងរយៈពេលវេលា៤៥ឆ្នាំ ។ អរិយសច្ចៈទី១ជាបញ្ញាកិច្ចត្រូវកំណត់ដឹង ទី២ជាបហានកិច្ចត្រូវលះបង់ទី២ជាសច្ឆិកាតព្វកិច្ច

ត្រូវធ្វើឱ្យជាក់ច្បាស់ ទី៤ជាភាវេតព្វកិច្ចត្រូវចំរើនឱ្យកើតមាន ។ ទី២និងទី៤ ជាហេតុ ទី១និងទី៣ជាផល ។

មគ្គសច្ចទី៤ មានអង្គ ៨ ចែកជាសិក្ខាមាន ៣ គឺ

សម្មាទិដ្ឋ ១, សម្មាសង្កប្បៈ ១ **ជាបញ្ញាសិក្ខា** ។

សម្មាវាចារ ១, សម្មារកម្មន្តៈ ១ សម្មាអាជីវៈ ១ ជាសីលសិក្ខា ។

សម្មាវាយាមៈ ១, សម្មាសតិ ១ សម្មាសមាធិ ១ ជាចិត្តសិក្ខា ។

អរិយសច្ចៈទាំង៤នេះឯង ជាពុទ្ធសាសនាជាទ្រឹស្តីលោកមាន អត្ថន័យជ្រាលជ្រៅធំទូលាយក្រៃលែង ស្រូបប្រមូលនូវចលនាលោកទាំងអស់ ។

ពុទ្ធសាសនា គឺទ្រឹស្តីលោក ឬលោកកុត្តរទស្សនវិជ្ជានេះ ព្រះសម្មុទ្ធសមណគោតម បានត្រាស់ដឹងហើយ ប្រកាសប្រាប់ពិភពលោកមុនដំបូងបំផុត ជាបឋមទេសនា (Premier sermon) នៅឥសិបតនមិគទាយវ៍នក្នុងប្រទេសឥណ្ឌា ពីពេលនោះមកដល់ពេលនេះចំនួន២៦ពុទ្ធសតវត្សរ៍ហើយ គិតមកទល់ត្រឹមព. ស ២៥១៣នេះ ។

# វគ្គទី ២

## ការវែកញែកពុទ្ធសាសនា និង វិទ្យាសាស្ត្រ

ដើម្បីវែកញែក នូវទ្រឹស្តីទាំងពីរនេះ ឱ្យមានវិភាគបទ ( Analyse) ច្បាស់លាស់ ស្រួលគិតងាយយល់ត្រូវវែកញែកអំពីសមត្ថភាព ចំណេះវិជ្ជា

ត្រូវធ្វើឱ្យជាក់ច្បាស់ ទី៤ជាភាវេតព្វកិច្ចត្រូវចំរើនឱ្យកើតមាន ។ ទី២និងទី៤ ជាហេតុ ទី១និងទី៣ជាផល ។

មគ្គសច្ចទី៤ មានអង្គ ៨ ចែកជាសិក្ខាមាន ៣ គឺ

សម្មាទិដ្ឋ ១, សម្មាសង្កប្បៈ ១ ជាបញ្ញាសិក្ខា ។

សម្មាវាចារ ១, សម្មារកម្មន្តៈ ១ សម្មាអាជីវៈ ១ ជាសីលសិក្ខា ។

សម្មាវាយាមៈ ១, សម្មាសតិ ១ សម្មាសមាធិ ១ ជាចិត្តសិក្ខា ។

អរិយសច្ចៈទាំង៤នេះឯង ជាពុទ្ធសាសនាជាទ្រឹស្តីលោកមាន អត្ថន័យជ្រាលជ្រៅធំទូលាយក្រៃលែង ស្រូបប្រមូលនូវចលនាលោកទាំងអស់ ។

ពុទ្ធសាសនា គឺទ្រឹស្តីលោក ឬលោកកុត្តរទស្សនវិជ្ជានេះ ព្រះសម្មុទ្ធសមណគោតម បានត្រាស់ដឹងហើយ ប្រកាសប្រាប់ពិភពលោកមុនដំបូងបំផុត ជាបឋមទេសនា (Premier sermon) នៅឥសិបតនមិគទាយវ័នក្នុងប្រទេសឥណ្ឌា ពីពេលនោះមកដល់ពេលនេះចំនួន២៦ពុទ្ធសតវត្សរ៍ហើយ គិតមកទល់ត្រឹមព. ស ២៥១៣នេះ ។

# វគ្គទី ២

## ការវែកញែកពុទ្ធសាសនា និង វិទ្យាសាស្ត្រ

ដើម្បីវែកញែក នូវទ្រឹស្តីទាំងពីរនេះ ឱ្យមានវិភាគបទ ( Analyse) ច្បាស់លាស់ ស្រួលគិតងាយយល់ត្រូវវែកញែកអំពីសមត្ថភាព ចំណេះវិជ្ជា

និងសតិបញ្ញារបស់បុគ្គល អ្នករកឃើញអ្នកផ្តើមបង្កើតទ្រឹស្តីទាំងពីរនេះសិន។

តាមប្រវត្តិនៃទស្សនវិជ្ជាប៉ែកបស្ចឹមប្រទេសថា ទស្សនវិជ្ជាបានចាប់កំណើតឡើងក្នុងលោកមុនគេបំផុត នៅប្រទេសហ្វ្រិកដែលស្ថិតនៅនាឆ្នេរសមុទ្រមេឌីទែរ៉ាណេ ។

ក្នុងប្រទេសហ្វ្រិកសម័យបុរាណ មានឥសី៧រូបជាអ្នកប្រាជ្ញបញ្ញាវ័ន្ត គេបានរាប់បញ្ចូលឥសីមួយរូបឈ្មោះ Thalês (តាលែះ)ជាអ្នកប្រាជ្ញខាងគណិតវិទ្យា (Mathématicien) និងខាងតារាវិទ្យា (Astronome) ទៅក្នុងក្រុមឥសីទាំង៧នោះដែរ ។

ឥសីឈ្មោះតាលែះនេះឯង ជាអ្នកផ្តើមបង្កើតទស្សនវិជ្ជាមុនគេបំផុត ញុំាងអ្នកប្រាជ្ញខាងបស្ចឹមប្រទេសឱ្យភ្ញាក់គំនិតនេះត្រិះរិះពិចារណាចេះស្រឡាញ់ និងបង្កើតវិទ្យាផ្សេងៗ ។

បន្ទាប់មកទស្សនវិជ្ជាហ្វ្រិក បានផ្សាយនៅទ្វីបអឺរ៉ុប អ្នកអឺរ៉ុបក៏បានភ្ញាក់រលឹក កើតគំនិតប្រាជ្ញា ចេះដោះស្រាយបញ្ហាធម្មជាតិ បញ្ហាមនុស្សតាំងពីពេលនោះមក ។

អាស្រ័យហេតុនេះ ទើបក្នុងប្រវត្តិទស្សនវិជ្ជាគេទុកតាលែះនេះជាបិតារបស់ទស្សនវិជ្ជា ។ ឯទស្សនវិជ្ជាជាបិតារបស់វិទ្យាសាស្ត្រ ។

ដូច្នេះឃើញថា ទស្សនវិទូឈ្មោះតាលែះ ត្រូវជាជីតារបស់អ្នកវិទ្យាសាស្ត្រ ក្នុងសម័យនេះ ។

តាលែះកើតក្នុងឆ្នាំ ៦២៤មុនគ. ស គិតពីគាត់កើតមកដល់សព្វថ្ងៃនេះ ចំនួន ២៥៩៣ ឆ្នាំហើយ (៦៤៤មម + ១៩៦៩គ. ស =២៥៩៣ឆ្នាំ)។

ព្រះសម្មាសម្ពុទ្ធសមណគោតម ដែលបានរកឃើញទ្រឹស្តីពុទ្ធសាសនា ទ្រង់ឧប្បត្តិកើតនៅប្រទេសឥណ្ឌាក្នុងឆ្នាំ៥៨០មុនព.ស គិតពីឆ្នាំឧប្បត្តិកើតមក ដល់សព្វថ្ងៃនេះចំនួន២៥៩៣ឆ្នាំហើយដែរ(៨០ម.ព+២៥១៣មស=២៥៩៣ឆ្នាំ)។

តាមវិភាគបទខាងលើនេះ ឃើញថាព្រះសម្មាសម្ពុទ្ធជាអគ្គទស្សនវិទូ ដែលបានរកឃើញទ្រឹស្តីពុទ្ធសាសនានោះទ្រង់ឧប្បត្តិកើត ក្នុងឆ្នាំជំណាលនឹងទស្សនវិទូតាលែះ ដែលជាជីតារបស់អ្នកវិទ្យាសាស្ត្រនោះដែរ គ្រាន់តែព្រះអង្គឧប្បត្តិកើតនៅប្រទេសឥណ្ឌាតាលែះកើតនៅប្រទេសក្រិកប៉ុណ្ណោះ។

បើសម័យនោះ នៅប្រទេសក្រិកមានអ្នកប្រាជ្ញបញ្ញវ័ន្តចេះដឹងខាងគណិតវិទ្យា និងតារាវិទ្យា អាចបង្រៀនតាលែះឱ្យដេះដឹងបាន នៅប្រទេសឥណ្ឌា ក៏មានអ្នកប្រាជ្ញបញ្ញវ័ន ច្រើនដែរ ព្រោះសុទ្ធតែជាជនជាតិអរិយៈ (Aryas) មានអារ្យធម៌ខ្ពង់ខ្ពស់ជឿនលឿនក្នុងសម័យនោះ ដូចកាឡទេវិលតាបសដែលជាអ្នកប្រាជ្ញធំ មានចំណាស់ស្មើនឹងជីតារបស់តាលែះនិងព្រាហ្មណ៍បញ្ញវ័នទាំង៨រូប មានរាមព្រាហ្មណ៍ជាដើម ដែលព្រះបាទសុទ្ធោទនៈ អញ្ជើញទៅថ្វាយទំនាយព្រះសិទ្ធត្ថកុមារនោះ ក៏មិនមែនជាមនុស្សអន់ដែរ ។

ឯកាឡទេវិលតាបសនោះ មានប្រាជ្ញាញាណក្រៃលែងបានចេះដឹងនូវអរូបសមាបត្តិវិទ្យា ដែលកម្រមានមនុស្សក្នុងលោកចេះដឹងបាន និងពួកសាស្ត្រាចារ្យវិស្វាមិត្រ ដែលព្រះបាទសុទ្ធោទនៈអញ្ជើញឱ្យទៅបង្រៀនវិជ្ជាផ្លូវលោក មានអក្សរសាស្ត្រនិងគណិតសាស្ត្រជាដើម ចំពោះសិទ្ធត្ថកុមារនោះ ក៏សុទ្ធតែជាបញ្ញវ័ន្តឆ្នើមបំផុត ក្នុងប្រទេសឥណ្ឌាសម័យនោះ ។

អត្ថបទនៃពុទ្ធប្រវត្តិ ក្នុងគម្ពីរលលិតវិស្តារ ខាងលទ្ធិមហាយាន ដែលនិយាយអំពីការប្រឡងប្រជែង ចំពោះវិជ្ជាមុនពេលអភិសេកព្រះអង្គសិទ្ធត្ថៈ ជាមួយព្រះអង្គម្ចាស់ក្សត្រីពិម្ពានោះថា មានយុវជនមួយរូប ជាអ្នកអក្សរសាស្ត្រ (Litté rateur) ដែលមានឈ្មោះល្បីល្បាញ បានសុំចូលទៅប្រលងជាមួយព្រះអង្គម្ចាស់សិទ្ធត្ថៈ ដើម្បីបានព្រះអង្គម្ចាស់ក្សត្រីពិម្ពាមកខ្លួន ។ ពេលនោះបានជួប នឹងសាស្ត្រាចារ្យវិស្វាមិត្រក៏និយាយស្នើការនោះ លោកវិស្វាមិត្រប្រាប់ថា ព្រះអង្គម្ចាស់សិទ្ធត្ថៈបានរៀនពីខ្ញុំមែន ប៉ុន្តែមិនយូរប៉ុន្មានខ្ញុំអស់តម្រិះត្រឡប់ ជាព្រះអង្គម្ចាស់បង្រៀនខ្ញុំវិញ បើលោកចេះជាងខ្ញុំល្មមទៅប្រលងសាកល្បងដែរ ។ យុវជនឮដូច្នោះ ក៏កោតសរសើរក្រៃលែងមិនហ៊ានប្រលងប្រជែងជាមួយឡើយ ។

ក្នុងពេលជាមួយគ្នានោះ មានយុវៈព្រះអង្គម្ចាស់មួយអង្គទៀត ព្រះនាមអជ៊ុន ជាគណិតវិទូ (Mathématicien) មានព្រះទ័យចង់បានព្រះអង្គម្ចាស់ក្សត្រីពិម្ពាដែរ បានរិះគិតរើសរកចំណោទដែលពិបាកបំផុតក្នុងក្បួនគណិតវិទ្យា បានទៅប្រលងជាមួយព្រះអង្គម្ចាស់សិទ្ធត្ថៈៗ ដោះស្រាយរួច ហើយចោទសួរវិញព្រះអង្គម្ចាស់ អជ៊ុន ដោះស្រាយមិនរួច ។

បន្ទាប់មកទៀតមានយុវជន យុវក្សត្រ និងអ្នកប្រាជ្ញចាស់ៗជាច្រើនរូបដែលល្បីល្បាញក្នុងវិជ្ជាផ្សេងៗ មានយុទ្ធវិទ្យា (Stratégie) និងតារាវិទ្យា (Astronomie) ជាដើម បានចូលទៅប្រលងជាមួយព្រះអង្គម្ចាស់សិទ្ធត្ថៈមានប្រលងបាញ់ព្រួញជាដើម គ្មាននរណាម្នាក់យកជ័យជំនះបាន ។ល។

ម្យ៉ាងទៀតក្នុងពេលព្រះបាទសិទ្ធត្ថៈបព្វជ្ជា ហើយបានយាងគ្រប់

ច្រកល្អករកអ្នកប្រាជ្ញធំៗដើម្បីសិក្សាមិនមាន អ្នកប្រាជ្ញណាដែលចេះជាង ព្រះអង្គឡើយ ។ ថ្ងៃមួយបានជួបអាឡារតាបសនិងឧទកតាបស ដែលជាអ្នកប្រាជ្ញធំខាងផ្លូវលោក និងផ្លូវធម៌ចេះស្ទាត់ជំនាញខាងត្រៃវេទ ដែលជាវិជ្ជាមួយកើតមានក្នុងលោកប្រហែលបីពាន់ឆ្នាំមុនគ.ស ចំណែកផ្លូវធម៌វិញ តាបសទាំងពីរនេះ បានចេះដល់អរូបសមាបត្តិវិទ្យា ។ ព្រះអង្គបានទៅសិក្សាមិនយូរប៉ុន្មាន ក៏ចេះដឹងដល់អរូបសមាបត្តិវិទ្យានោះដូចតាបសដែរ ។

កាលបើតាបសទាំងពីរ អស់ចំណេះត្រឹមប៉ុណ្ណោះហើយព្រះអង្គក៏លាតាបសចេញទៅធ្វើទុក្ករកិរិយា ដោយជ្រាបច្បាស់ថាអរូបសមាបត្តិវិទ្យានេះ មិនមែនជាវិជ្ជាអាចត្រាស់ដឹងនូវពោធិញ្ញាណបានឡើយ ។ល។

តាមទស្សនៈខាងលើនេះ យើងអាចសំរេចអំពីសមត្ថភាពចំណេះវិជ្ជារបស់មនុស្សក្នុងសម័យនោះបានថា «ពួកតាបសឥសីពួកព្រាហ្មណ៍ និងសាស្ត្រាចារ្យវិស្វាមិត្រនោះ មានចំណេះវិជ្ជាខាងផ្លូវលោកយ៉ាងហោចណាស់ក៏ស្មើនឹងតាលែះដែរ ។ ឯព្រះអង្គម្ចាស់សិទ្ធត្ថៈ ដែលវៃឆ្លាតចេះដឹងលើសសរុបជាងពួកតាបសឥសីទៅទៀតនោះ ពិតជាព្រះអង្គមានចំណេះវិជ្ជាខាងលោកនិយម ដូចគណិតវិទ្យាជាដើមដល់កំរិតខ្ពស់បំផុត ។

មិត្តអ្នកអានខ្លះមុខជាឆ្ងល់ថា បើព្រះសម្មទ្ធបានចេះដឹងវិជ្ជាលោកនិយមច្បាស់លាស់ដល់កំរិតខ្ពស់ តាំងពីនៅជាព្រះអង្គម្ចាស់ម្ល៉េះ ហេតុអ្វីក៏ក្នុងព្រះត្រៃបិដកមិនឃើញព្រះអង្គសំដែង អំពីទ្រឹស្តីវិទ្យាសាស្ត្រផង ?

បញ្ហានេះឆ្លងចូលទៅក្នុងការវែកញែក ខាងទ្រឹស្តីពុទ្ធសាសនា និងវិទ្យាសាស្ត្រហើយ ។

# ការវែកញែកខាងទ្រឹស្តី

កម្មវត្ថុនៃការវែកញែក រកហេតុផលក្នុងបញ្ហាមាន២ចំណុចគឺ ចំណុចទី១ ព្រះសម្មាសម្ពុទ្ធគ្រប់ព្រះអង្គជាសព្វញ្ញូ មានប្រាជ្ញាញាណចេះដឹងសព្វគ្មានចន្លោះ សូម្បីហេតុអាចិកំបាំងដែលកើតមានហើយក្នុងអតីតកាលកន្លងទៅជាច្រើនអសង្ខេយ្យឆ្នាំក្តី ហេតុអាចិកំបាំងដែលបំរុងនិងកើតមានក្នុងអនាគតខាងមុនដ៏ច្រើនអសង្ខេយ្យឆ្នាំក្តី ក៏ព្រះអង្គអាចចេះដឹងយល់បានទាំងអស់ ។ ចំណេះវិជ្ជាលោកនិយនេះ ព្រះអង្គបានចេះដឹងច្បាស់លាស់តាំងពីនៅជាព្រះអង្គម្ចាស់សិទ្ធត្ថៈម្ល៉េះ ។ នេះជាហេតុផលមួយបញ្ជាក់ឱ្យដឹងបានថា វិជ្ជាលោកនិយមទាំងអស់ ព្រះអង្គបានចេះដឹងពិតមែន ។

ហេតុផលមួយទៀតរិតតែឱ្យដឹងច្បាស់ថា ព្រះអង្គពិតជាចេះមែន ដោយសំអាងទៅលើពុទ្ធដីកាក្នុងគម្ពីរ សំយុត្តនិកាយសុត្តន្តបិដកត្រង់សីលបាបណ្ណវគ្គថា កាលព្រះអង្គយាងទៅក្នុងសីលបាវ៉នជិតក្រុងកោសម្ពី បានយកព្រះហស្តចាប់ស្លឹកឈើមួយក្តាប់ហើយ ត្រាស់សួរភិក្ខុទាំងឡាយថា «ស្លឹកឈើក្នុងដៃតថាគតច្រើនជាងស្លឹកឈើក្នុងសីលបាវ៉នឬតិចជាង?» ភិក្ខុទាំងឡាយទូលថា «ស្លឹកឈើក្នុងព្រះហស្តព្រះអង្គតិចពេកណាស់ ?, ឯស្លឹកឈើក្នុងព្រៃនេះ មានចំនួនច្រើនជាងក្រៃលែង ។

អាស្រ័យហេតុនេះ ទើបព្រះអង្គសំដែងប្រាប់ភិក្ខុទាំងនោះថា «ធម៌ដែលតថាគត បានចេះដឹងហើយមានចំនួនច្រើនក្រៃលែង ដូចជាស្លឹកឈើក្នុងព្រៃនេះ ឯធម៌ដែលតថាគតសំដែងប្រាប់ដល់អ្នកទាំងឡាយ មានចំនួនតិចណាស់ ដូចស្លឹកឈើក្នុងដៃតថាគត» ។ល។

ក្នុងចំណុចទី១នេះ មានហេតុផលអាចឱ្យដឹងបានថា វិជ្ជាលោកនិយមទាំងអស់ មិនត្រឹមតែវិទ្យាសាស្ត្រដូចមានក្នុងពិភពលោកយើងសព្វថ្ងៃនេះទេ សម្បីមហាវិទ្យាសាស្ត្រយ៉ាងវិសេសប្លែក ដែលមានក្នុងភពដទៃៗទៀតនោះ ពិតជាព្រះអង្គចេះដឹងយ៉ាងច្បាស់លាស់ ។

ចំណុចទី២ បើព្រះអង្គចេះដឹងមែន ហេតុអ្វីមិនសំដែងឱ្យអ្នកពិភពលោកយើងនេះបានចេះដឹងផង កុំឱ្យគ្នាពិបាកដេកនឹកគិតរាវរក ដូចអ្នកប្រាជ្ញសព្វថ្ងៃនេះ ព្រោះព្រះអង្គប្រកបដោយមហាករុណាចំពោះអ្នកពិភពលោកស្រាប់ ។

ចំងល់នេះ មានហេតុផលត្រូវដោះស្រាយដូចខាងក្រោម ÷

ពុទ្ធប្រវត្តិវិទូទាំងឡាយ ធ្លាប់បានជ្រាបស្រាប់ហើយ ថាក្នុងសប្តាហ៍ទី ៤-៥-៦ និងទី ៧ បន្ទាប់អំពីថ្ងៃដែលព្រះអង្គបានត្រាស់ដឹងជាព្រះសម្ពុទ្ធថ្មីៗនោះ ព្រះអង្គបានត្រិះរិះពិចារណានូវធម៌ទាំងអស់ ដែលបានត្រាស់ដឹងហើយ និងពិចារណារៀបចំនូវទ្រឹស្តីពុទ្ធសាសនា គឺព្រះត្រៃបិដក រហូតដល់ពេលដែលមហាព្រហ្មមកអារាធនាព្រះអង្គ ដើម្បីសំដែងធម៌ប្រោសសត្វ ។

ពេលនោះហើយ ព្រះអង្គកំពុងជ្រើសរើសធម៌ដែលគួរនឹងសំដែងប្រកាសក្នុងពិភពលោក ។

ព្រះអង្គបានជ្រាបច្បាស់នូវប្រពៃណីព្រះពុទ្ធពីបុរាណកាលមកថា «ព្រះពុទ្ធទាំងឡាយ តែងតែសំដែងនូវធម៌ ដែលនាំសត្វលោកឱ្យបានសុខស្ងប់ បានធូរស្រាលចាកកាមគុណ ដែលជាហេតុឱ្យកើតទុក្ខ ។

ព្រះអង្គបានជ្រាបច្បាស់ដូច្នេះ ទើបមិនសំដែងរៀបរាប់អំពីទ្រឹស្តី

វិទ្យាសាស្ត្រ ទុកក្នុងព្រះត្រៃបិដក ហើយបានប្រកាសបញ្ជាក់ប្រាប់ពិភពលោក ក្នុងពេលសំដែងធម្មចក្កប្បវត្តនសូត្រ ជាបឋមទេសនា (Premier sermon) ដើម្បីកុំឱ្យសង្ស័យក្នុងរឿងនេះ «មជ្ឈិមា បដិបទា សេចក្តីប្រតិបត្តិជាកណ្តាលមិនមែនជាការប្រតិបត្តិបំរើកាម នាំទុក្ខមកឱ្យខ្លួន ដែលតថាគតបានត្រាស់ដឹងហើយ ជាបដិបទាឱ្យកើតបញ្ញា ការដឹងច្បាស់ ប្រព្រឹត្តទៅដើម្បីសេចក្តីស្ងប់ ដើម្បីសេចក្តីរំលត់ទុក្ខ» ។

មួយកន្លែងទៀត ពេលដែលព្រះអង្គប្រាប់ពួកភិក្ខុក្នុងសីសបាវ៉ន អំពីការដែលព្រះអង្គបានចេះដឹងធម៌ច្រើន ហើយសំដែងប្រាប់តិចនោះ ត្រង់វគ្គខាងចុង ព្រះអង្គបញ្ជាក់សួរថា «ចុះហេតុអ្វីក៏តថាគតមិនយកធម៌ទាំងអស់នោះមកសំដែង ?» ទ្រង់ឆ្លើយ ព្រះអង្គឯងថា «ព្រោះធម៌ទាំងអស់នោះមិននាំសត្វលោកទៅរកសេចក្តីរលត់ទុក្ខ » ។

ក្នុងចំណុចទី២នេះ មានហេតុអាចឱ្យដឹងច្បាស់ថាបានជាព្រះអង្គមិនសំដែង អំពីទ្រឹស្តីវិទ្យាសាស្ត្រ ទុកក្នុងព្រះត្រៃបិដកនោះ ព្រោះប្រពៃណីរបស់ព្រះពុទ្ធទាំងឡាយ តែងតែសំដែងធម៌ដែលនាំសត្វលោកឱ្យបានសេចក្តីសុខស្ងប់ឱ្យរំលត់ ទុក្ខនេះម៉្យាង ។

ម៉្យាងទៀតវិទ្យាសាស្ត្រដូចសព្វថ្ងៃនេះ ជាវិជ្ជាសាមញ្ញមិនមែនជាវិជ្ជាមានអត្ថន័យជ្រាលជ្រៅហួសនិស្ស័យប្រាជ្ញាមនុស្សបុថុជ្ជនឡើយមិនបាច់ព្រះអង្គសំដែងប្រាប់ក៏អ្នកពិភពលោកអាចត្រិះរាវរកចេះដឹងចងក្រងជាទ្រឹស្តីបានដែរ ។ ជាពិសេសវិទ្យាសាស្ត្រនេះ ជាវិជ្ជាពង្រីកបំប៉នកាមគុណនាំឱ្យរីកចំរើននូវរាគៈលោភៈ ទោសៈ មោហៈ កាន់តែធាត់ធំកាន់តែក្លៀវក្លា

សាហាវឡើង ដូចធ្លាប់បានដឹងឮក្នុងសម័យវិទ្យាសាស្រ្តនេះស្រាប់ ។

អាស្រ័យហេតុដូចខាងលើនេះ ទើបព្រះអង្គចេះដឹងហើយមិនសំដែងប្រាប់ ព្រោះព្រះអង្គអាណិតអាសូរចំពោះអ្នកពិភពលោកនោះឯង ។

សូមបញ្ជាក់ថា ព្រះសម្មាសម្ពុទ្ធជាអង្គសព្វញ្ញូទ្រង់ជ្រាបច្បាប់ថាពិភពលោកនេះជាទីក្រុងធំ ( Capitale )នៃកាមគុណកំពុងឆេះសន្ធោសន្ធៅដោយភ្លើងរាគៈ លោភៈ ទោសៈ មោហៈជានិច្ចរាល់ថ្ងៃដែលបណ្តាលមកពីកាមគុណនោះឯង ញុំាងអ្នកពិភពលោកឱ្យកើតចលាចលមានអសន្តិសុខទុក្ខលោក ស្លាប់ព្រាត់ប្រាសគ្មានស្រាកស្រាន្ត ដូចពុទ្ធភាសិត ក្នុងគម្ពីរធម្មបទ ដែលព្រះអង្គសំដែងប្រាប់ ពួកស្រ្តីជាសម្លាប់នាងវិសាខាថា÷

**កោ នុ ហាសោ កិមានន្ទោ និច្ចំ បជ្ជលិតេ សតិ**

**អន្ធការេន ឱនទ្ធា បទីបំ ន គវេសថ ។**

បើពិភពលោក ត្រូវភ្លើងគឺរាគៈ ជាដើម កំពុងឆេះសន្ធោ សន្ធៅជានិច្ចម្តេចក៏បែរជានាំគ្នាសើចក្អាកក្អាយ នាងទាំងឡាយ ត្រូវងងឹត គឺ អវិជ្ជារួបរិតហើយ ម្តេចនាងមិនស្វែងរកប្រទីបគឺប្រាជ្ញាឡើង !។

ដោយព្រះអង្គ មានមហាករុណាទិគុណ ចំពោះអ្នកពិភពលោកផងបានជ្រាបច្បាប់ឃើញច្បាស់យ៉ាងនេះផង ទើបព្រះអង្គមិនអាច ជួយបន្ថែមភ្លើងដុតពិភពលោកទៀត ។

ព្រះអង្គជ្រើសរើសយកតែធម៌ ជាមធ្យោបាយជួយលត់ភ្លើងរាគជាដើមនោះវិញ គឺពុទ្ធសាសនានេះឯង ។

ពុទ្ធសាសនានេះ មិនមែនគ្រាន់តែញ៉ាំង អ្នកពិភពលោកឱ្យបាន សុខស្ងប់ ហើយឱ្យល្ងង់ដប់គត់ដេកចាំស្លាប់នោះទេគឺឱ្យសុខ ស្ងប់ហើយ ឱ្យចេះដឹងវៃឆ្លាតប៉ិនប្រសប់ផង ឱ្យយកជ័យជំនះពីធម្មជាតិ មិនឱ្យធម្មជាតិចាប់បង្ខិល ឱ្យស្លាប់ឱ្យកើតបានផង ព្រោះពុទ្ធសាសនានេះឯង ជាទ្រឹស្តីលោក ជាក្បួនច្បាប់ជាវត្ថុសិក្សា ឬថាជាធម្មនុញ្ញរបស់ពិភពលោក សំរាប់បណ្តុះសតិបញ្ញាចំណេះវិជ្ជា និង ចរិយាមារយាទខ្ពង់ខ្ពស់ថ្លៃថ្នូររបស់អ្នកពិភព លោកឱ្យបានចំរើនរុងរឿង សុខ សន្តិភាព និង បានបរមសុខជាអមតៈ ។

ពិតមែនតែក្នុងទ្រឹស្តីពុទ្ធសាសនា យើងមិនបានឃើញក្បួនវិទ្យាសាស្ត្រ ដូចជាក្បួនធ្វើរថយន្ត អាកាសយាន និងក្បួនធ្វើវិទ្យុអគ្គិសនី ជាដើមនោះមែន ,ប៉ុន្តែទ្រឹស្តីពុទ្ធសាសនានេះឯង ជាប្រភព នៃវិទ្យាសាស្ត្រ នៃវឌ្ឍនធម៌ សីលធម៌ អារ្យធម៌ និង វប្បធម៌ក្នុងពិភពលោក ទាំងមូល ដូចជាមុខវិជ្ជា វត្ថុសិក្សាគ្រប់ផ្នែក ទាំងអស់ក្នុងទ្រឹស្តីវិទ្យាសាស្ត្រ សុទ្ធតែកើតមកអំពី អធិបតិធម៌ គឺសភាវៈ ជាធំក្នុងកិច្ចការ ឬហៅថាឥទ្ធិបាទធម៌គុណធម៌ ដូចជាជំហាននៃសេចក្តីសំរេច មាន៤គឺ :

១-**ឆន្ទ**: បំណង គឺការប៉ងប្រាថ្នា ចំពោះអ្វីមួយហើយតែងមានការពិនិត្យសង្កេត ជាកិច្ចសិក្សា ឬកត់សំគាល់នេះជាមូលហេតុទី១ ដែលនាំឱ្យកើតវិទ្យាសាស្ត្រគឺ Observation ។

បើមានការពិនិត្យសង្កេតបែបនេះហើយ តែងសន្មត់ស្មានទៅលើអ្វីមួយដែលបានកំណត់ទុកថានឹងមាន, នេះជាមួយហេតុទី២ដែលនាំឱ្យកើត-

វិទ្យាសាស្ត្រទៀតគឺ Hypothèse ។

២- **វិរិយៈ** សេចក្ដីព្យាយាម គឺការមិនខ្ជិលច្រអូសកាយនិងចិត្ត ខំខ្វល់ខ្វាយពិសោធន៍សាកល្បងរកការពិតតាមគំនិត, នេះជាមូលហេតុទី៣ ដែលនាំឱ្យកើតវិទ្យាសាស្ត្រគឺ Expérience ។

៣- **ចិត្តៈ** គំនិតគឺការចេះគិតគូរកត់ត្រាចងក្រងជាទ្រឹស្ដីក្បួនខ្នាត ឡើង តាមដំណើរការណ៍ ដែលបានសាកល្បងហើយ នេះមូលហេតុទី៤ ដែល នាំឱ្យកើតវិទ្យាសាស្ត្រគឺ Théorie ។

៤- **វិមំសា** ការត្រិះរិះពិចារណាប្រកបដោយទេពកោសល្យ, ការ អនុវត្តន៍លៃលកតាមវិធានដែលមានក្នុងទ្រឹស្ដី, នេះជាហេតុទី៥ ដែលនាំឱ្យ សំរេចកើតជាវិទ្យាសាស្ត្រគឺ Application ou la pratique ។

អធិបតិធម៌ ឬឥទ្ធិបាទធម៌នេះ មិនមែនមានប្រយោជន៍តែ ខាងការ បង្កើតវិទ្យាសាស្ត្រប៉ុណ្ណោះទេ ជាធម៌មានប្រយោជន៍ធំបំផុត ក្នុងពិភពលោក អាចញ៉ាំងវត្ថុបំណងរបស់អ្នកពិភពលោកឱ្យបានសំរេចគ្រប់យ៉ាង តាំងពី ប្រយោជន៍តូចទាបដល់ខ្ពង់ខ្ពស់ជាអមតៈ ដូចជាបុគ្គលដែលបានសំរេច ឈានសមាបត្តិ មគ្គផលនិព្វាន ក៏ព្រោះតែមានអធិបតិធម៌ ឬឥទ្ធិបាទធម៌ នេះឯង ។

អំពីទិដ្ឋធម្មិកធម៌ គឺហេតុឱ្យកើតផលប្រយោជន៍ក្នុងពិភពលោក នេះមាន៤ គឺ

១- ការប្រឹងប្រែងធ្វើការងារ មិនខ្ជិលច្រអូសជានិច្ច ឈ្មោះថា

ឧដ្ឋានសម្បទា ,

២- ការថែរក្សាដោយយកចិត្តទុកដាក់ជានិច្ចឈ្មោះថាអារក្ខសម្បទា

៣- ភាពជាអ្នកគប់មិត្តល្អ ឈ្មោះថា កល្យាណមិត្តតា

៤- ភាពនៃការចិញ្ចឹមជីវិតតាមលទ្ធភាព ឈ្មោះថា សមជីវិតា ។

ធម៌ទាំង២នេះឯង ជាប្រភព និងជាគ្រឹះយ៉ាងមាំសំរាប់បណ្តុះបណ្តាល និង ទ្រទ្រង់នូវអង្គការពិភពលោក អង្គការរដ្ឋនិងអង្គការគ្រួសារមួយៗឱ្យបានប្រកបដោយវឌ្ឍនធម៌ ចំរើនរុងរឿង ។ បើខ្វះធម៌ណាមួយ អង្គការនោះៗត្រូវមានវិបត្តិមិនខាន ។

ក្នុងរដ្ឋមួយៗមានអង្គការជាច្រើនដូចសេដ្ឋកិច្ច ( Economie ) សង្គមកិច្ច ( Action soclale ) និង នយោបាយ ( Politique )ជាដើម ។

ផ្នែកសេដ្ឋកិច្ច ដូចខាងឧស្សាហកម្ម ( Industrie ) និង ពាណិជ្ជកម្ម ( Commerce ) បើអ្នកកាន់ការទាំងឡាយ ក្នុងពិភពលោកខ្វះធម៌ទី១ គឺ ឧដ្ឋានសម្បទា កម្ជិលមិនប្រឹងប្រែងចំពោះករណីយកិច្ចរវល់តែប្រចាំគ្នាប្រណែនគ្នា អំពីប្រយោជន៍ផ្ទាល់ខ្លួនមិនខំរវៃឧស្សាហកម្ម និងពាណិជ្ជកម្មឱ្យដើរទាន់សម័យទេ សេដ្ឋកិច្ចត្រូវអមតៈបានឡើយ ព្រោះនៅមានការកុហកបោកប្រាស នៅមានអំពើពុករលួយ លួចបន្លំកេងកិប ស៊ូកស៊ីសំណូក ប្រប្លូកប្រឡប់ក្នុងដំណើរជីវិត ត្រូវសិក្សាបង្កើតថ្នាក់ឱ្យដល់គឺរិតសីលសិក្ខាបានដល់ការសិក្សាតាមមគ្គសច្ចវិទ្យា ត្រង់៣ ទី៤ និងទី៥ គឺ សម្មាវាចា, សម្មាកម្មន្តៈ សម្មាអាជីវៈ ជាច្រើនឆ្នាំទៀតដរាប ដល់អប់រំចរិយាមារយាទឱ្យបានថ្លៃថ្នូរស្អាតបរិសុទ្ធដែលហៅថា អរិយចរិយា ។

ទី២ ចិត្តសិក្ខា ក៏មានន័យត្រូវសិក្សា ចាប់តាំងពីចំណុចសូន្យឡើង ទៅដល់លោកុត្តរចិត្ត ដែលមានឯកភាពវិសេសក្រៃលែងខ្ពស់បំផុតដែរ គឺចាប់សិក្សាហាត់ចិត្តគំនិតស្មារតី ឱ្យនឹងល្អលះបង់នូវភាពរវើរវាយរាត់រាយសាវ៉ា ចាប់តាំងពីកុមារាកុមារីទៅ ។ មេរៀនទាំងឡាយដែលគ្រូដាក់ឱ្យសិក្សា និងពេលដែលគ្រូកំពុងពន្យល់ សុទ្ធតែជាវិធីសិក្សាហាត់ចិត្តសតិស្មារតី ឱ្យនឹងឱ្យមានឯកភាពទាំងអស់គឺពេលកំពុងទន្ទេញមេរៀន ពេលកំពុងស្តាប់គ្រូពន្យល់នោះ ជាការហាត់ទាក់ចងចិត្តសតិស្មារតីឱ្យនៅនឹងក្នុងអារម្មណ៍តែមួយ ដែលហៅថាភាវនា ថា សមាធិ ។ អ្នកហើយបរយានយន្ត និងអ្នកធ្វើកិច្ចការផ្សេងៗមានអ្នកកីឡាយជាដើម បើមិនហាត់ចិត្តសតិស្មារតីឱ្យនឹងល្អជាសមាធិទេ នឹងមានកំហុសមានគ្រោះថ្នាក់មិនខាន ។ ការសិក្សាហាត់ចិត្តសតិស្មារតី ឱ្យនៅនឹងជាសមាធិសាមញ្ញត្រឹមប៉ុណ្ណោះមិនអាចកំចាត់បង់នូវគ្រោះថ្នាក់ធំៗមានការកើតស្លាប់ជាដើមបានឡើយ, ត្រូវសិក្សាបង្កើតថ្នាក់ឱ្យដល់កំរិតចិត្តសិក្ខា បានដល់ការសិក្សាតាមមគ្គសច្ចវិទ្យាត្រង់ទី៦ ទី **៧** និងទី៨ គឺសម្មាវាយាម, សម្មាសតិ, សម្មាសមាធិ ជាច្រើនឆ្នាំទៀត ដរាប់ដល់ចិត្តមានឯកភាពប្រសើរវិសេសជាលោកុត្តរចិត្ត ។

ទី៣ បញ្ញាសិក្ខា ក៏មានន័យត្រូវសិក្សា ចាប់តាំងពីចំណុច សូន្យឡើងទៅដល់លោកុត្តរបញ្ញាដែរ គឺចាប់សិក្សាបណ្តុះបញ្ញាតាំងពីរៀន **ឧមោមួយពី . . . អាបេ . . . អង់ដឺ . . .** លោក ក្នុងសង្គមជាតិនិងក្នុងគ្រួសារមាន៤គឺ :

១- ការជួយគ្នាទៅវិញទៅមក ដោយគ្រឿងឧបភោគបរិភោគ គឺការផ្តល់ជំនួយ ឈ្មោះថា មូល ។

២- ការនិយាយពាក្យល្អពាក្យពិត ដែលនាំឱ្យកើតការពេញចិត្ត កើតផលប្រយោជន៍ដល់អ្នកស្តាប់ បានដល់ពាក្យសំដីដែលនិយាយផ្ទាល់ ឬនិយាយផ្សាយតាមសៀវភៅ តាមវិទ្យុតាមទស្សនាវដ្តីនិង តាមសារពត៌មាន ឈ្មោះថា មូល ។

៣- ការជួយគាំទ្រប្រយោជន៍គ្នា ដោយកាយវាចា ឬដោយការផ្សាយតាមសៀវភៅ តាមវិទ្យុ តាមទស្សនាវដ្តីនិងតាមសារពត៌មាន ឈ្មោះថា **អត្ថចរិយា** ។

៤- ការតាំងខ្លួនស្មើៗជាអព្យាក្រឹត និយមមិត្តភាពចំពោះមនុស្សជាតិ មិនប្រកាន់ឋានៈ ប័ក្សពួក ពណ៌សម្បុរ នយោបាយ ឈ្មោះថា **សមានត្តតា** ។

ធម៌ទាំង៤ នេះឯងជាប្រភព និង ជាគ្រឹះសំរាប់ បណ្តុះបណ្តាល និងទ្រទ្រង់នូវនយោបាយ ( Politique ) ក្នុងប្រទេសក្រៅប្រទេសឱ្យមានភាពល្អប្រសើរ និងជាប្រភពជាគ្រឹះសំរាប់ពង្រីក សំរាប់ទ្រទ្រង់នូវសង្គម ( Societé ) ឱ្យមានការរួបរួមគ្នាជាធ្លុងមួយ ។

ឯសង្គមកិច្ច ( Action Sociale ) ដូចជាការជួយទំនុកបំរុងមនុស្សអនាថាកំសត់ទុគ៌ត ការជីកអណ្តូង ជីកស្រះ លើកទំនប់ជួយដល់ពួកកសិករ ការសង់មន្ទីរពេទ្យ សម្រាប់ព្យាបាលអ្នកជំងឺការសង់សាលារៀន សំរាប់-

បណ្តុះចំណេះវិជ្ជាកុមារ និង យុវជន ការបង្កើតក្រុមកាកបាទក្រហម និង ការបង្កើតអង្គការសង្គ្រោះដទៃៗ ទៀតជាច្រើនក្នុងពិភពលោក សុទ្ធតែបាន កើតមកនិងគង់វង្សនៅបាន ដោយសង្គហធម៌ទាំង៤នេះឯង ។

ការនាំយកទ្រឹស្តីពុទ្ធសាសនា **មកវែក**ញែកបន្តិចនេះ គ្រាន់តែ បញ្ជាក់ឱ្យឃើញថា ពុទ្ធសាសនាជាទ្រឹស្តីលោក ចែងតែអំពីគោលការណ៍ លោក ដែលត្រូវប្រព្រឹត្តធ្វើយ៉ាងណា ឱ្យបានស្របតាមសភាវៈពិតរបស់ ពិភពលោក ដើម្បីបានចំរើនរុងរឿងបានសុខស្ងប់ និងបានបរមសុខជា អមតៈ តែប៉ុណ្ណោះ មិនមែនជាមន្តអាគមគាថា អាថិកំបាំង សំរាប់ជប់ប្រស់ ឱ្យកើតជានេះជានោះប្រាសចាកហេតុផល ឬសំរាប់ដឹកនាំមនុស្សឱ្យមាន ជំនឿផ្តេស ដូចជាសាសនាដទៃឡើយ ។

សូមបញ្ជាក់ថា ព្រះធម៌ទាំងអស់ ក្នុងទ្រឹស្តីពុទ្ធសាសនា នោះជាធម៌ អ្វីក៏ដោយ ដូចជាព្រះត្រៃលក្ខណ៍ ដែលពុទ្ធសាសនិក តែងសំគាល់ថាជាធម៌ កំសត់ធម៌សង្វេគ សំរាប់សូត្រកំដរខ្មោចនោះ ក៏រិតតែមានន័យទាក់ទង ចំពោះពិភពលោក កាន់តែច្រើនក្រៃលែង ជាងធម៌ទាំងអស់ទៅទៀត ព្រោះ ពិភពលោកនេះឯង ជាកាំជណ្តើរថ្នាក់ក្រោម សំរាប់ជាន់ឈរឱ្យមានជំហ មាំទាំទើបឈានឡើងទៅថ្នាក់លើតាមកាំជាបន្តបន្ទាប់គ្នាដរាបដល់កាំទីបំផុត គឺមគ្គផលនិព្វាន ។

ដូចជាវិធីសិក្សា ( Méthode )ទាំងបីក្នុងទ្រឹស្តីពុទ្ធសាសនាដែល ធ្លាប់ហៅថាត្រៃសិក្ខា និងធ្លាប់ស្តាប់យល់ថាជាធម៌ថ្នាក់ខ្ពស់សំរាប់រៀនទៅ បរលោកនោះគឺ :

ទី១ សីលសិក្ខា មានន័យត្រូវសិក្សាចាប់តាំងពីចំណុចសូន្យឡើងទៅដល់អរិយសីល ដែលមានសណ្ដាប់ធ្នាប់ចរិយា ថ្លៃថ្នូរបំផុតក្នុងលោកគឺចាប់សិក្សាហាត់ចរិយា មារយាទឱ្យមានសណ្ដាប់ធ្នាប់តាំងពីនៅជាទារកទារិកា ទើបរៀននិយាយស្ដីមិនទាន់ច្បាស់ មាតាបិតាបានឱ្យសិក្សាពីសណ្ដាប់ធ្នាប់ក្នុងគ្រួសារមានឱ្យរៀនឆ្លើយបាទចាស ឱ្យចេះគោរពចាស់ព្រឹទ្ធាចារ្យជាដើមដល់ធំទៅសាលារៀន គ្រូបង្រៀនឱ្យចេះដឹងគោរពច្បាប់សាលាច្បាប់ច្បាប់រដ្ឋ និង ច្បាប់សាសនា ឱ្យបានចេះដឹងអំពីសីលធម៌ ( Morale) និង ចរិយាធម៌ ( Ethique ) តាមសម័យលោកនិយម គឺឱ្យមានពាក្យសំដីការងារ និងការចិញ្ចឹមជីវិតថ្លៃថ្នូរ ។ ការសិក្សាត្រឹមប៉ុណ្ណេះ មិនទាន់មានចរិយាមាយាទ ថ្លៃថ្នូរពិតប្រាកដ ដែលអាចទទួលនូវសេចក្ដីសុខស្ងប់ និងបរមសុខជាធ្លាក់ចុះ ។

បើមានឧដ្ឋានសម្បទាហើយខ្វះអារក្ខសម្បទា មានការខ្ជះខ្ជាយមិនត្រួតពិនិត្យឱ្យដល់ទីកន្លែង ចេះតែប្រចាំ បណ្ដាក់គ្នាម្នាក់អាងលើម្នាក់នៅតែក្នុងការិយាល័យ រំពឹងតែលើក្រដាសលើបញ្ជីនោះផលនៃឧស្សាហកម្ម និងពាណិជ្ជកម្មត្រូវខូចខាត សេដ្ឋកិច្ចត្រូវធ្លាក់ចុះ ។

បើមានធម៌ទាំងពីរនេះហើយ ប៉ុន្តែខ្វះធម៌ទី៣ គឺកល្យាណមិត្តតា មានការទាក់ទងជាមួយអ្នកលក់អ្នកទិញ ជាមនុស្សទុច្ចរិតមានការតែបន្លំ និងនាំតែបន្លំដោយហេតុណាមួយឬក៏មានសហការីរបស់ខ្លួនជាមនុស្សពុករលួយត្រូវជើងនឹងអ្នកទិញឬអ្នកលក់ធ្វើឱ្យខូចខាតផលឧស្សាហកម្ម ពាណិជ្ជកម្មនោះសេដ្ឋកិច្ចត្រូវធ្លាក់ចុះ ។

បើមានធម៌ទី១-២-៣ នេះគ្រប់គ្រាន់ហើយ នៅខ្វះធម៌ទី៤គឺសមជីវិតា មានការចំណាយច្រើនជាងចំណូល ដោយការខ្ជះខ្ជាយ ឬដោយប្រើបុគ្គលិកច្រើនហួស ដែលបណ្ដាមកពីមិនចេះប្រើគឺអំពើដែលគេធ្វើតែម្នាក់កើតយើងធ្វើ៤ឬ៥ នាក់ទើបកើតហើយមិនល្អទៀតឬទិញរបស់មួយមុខៗចូលច្រើនហួសដើម្បីបានភាគរយ អំពីអ្នកលក់ ឯរបស់ដទៃទៀតគ្មានលុយទិញឱ្យគ្រប់គ្រាន់ ដែលនាំឱ្យរអាក់រអួលដំណើរឧស្សាហកម្ម ពាណិជ្ជកម្មនោះ សេដ្ឋកិច្ច ត្រូវធ្លាក់ចុះ ។ កាលបើសេដ្ឋកិច្ចធ្លាក់ចុះព្រោះខ្លួនខ្វះសមត្ថភាព ឬព្រោះខ្លួនទុច្ចរិតហើយ ខំតម្លើងថ្លៃទំនិញដើម្បីទប់ទល់នោះ រឹតតែនាំឱ្យចង្រៃ ធំដល់សង្គមជាតិអ្នកប្រើប្រាស់ថែមទៀត ។

ទិដ្ឋធម្មិកធម៌នេះ មានន័យធំទូលាយគ្រប់ករណីកិច្ចទាំងអស់របស់អ្នកពិភពលោក ដូចបាននាំកូនចំណុចតូចមួយខាងលើនេះ ជានិទស្សនស្រាប់ ។

អំពីសង្គមហាធម៌ គឺធម៌សំរាប់ មនុស្សសង្គ្រោះមនុស្ស ឬ ជាធម៌នាំឱ្យកើតការរាប់រកគ្នារវាងមនុស្សនិងមនុស្សក្នុងពិភពឡើងទៅដរាបមានបញ្ញាចេះដឹងវិជ្ជាដល់ថ្នាក់បណ្ឌិត ( Doctorat )ដែលពិភពលោកសន្មតថាអ្នកប្រាជ្ញបាន ។ ការសិក្សាត្រឹមប៉ុណ្ណោះនៅមិនទាន់ដល់គីរិត បញ្ញាសិក្ខាគឺនៅមិនទាន់ស្គាល់ពិភពលោកច្បាស់លាស គ្រាន់តែបាន ស្គាល់តាមក្បួនរាយរងបន្តិចបន្តួចប៉ុណ្ណោះ ត្រូវសិក្សាបង្កើនថ្នាក់ឱ្យដល់គីរិតបញ្ញាសិក្ខាបានដល់ការសិក្សាតាមមគ្គសច្ចវិទ្យាត្រង់អង្គទី១ និង ទី២ គឺសម្មាទិដ្ឋិ និងសម្មាសង្កប្បៈជាច្រើនឆ្នាំតទៅទៀតដរាបដល់មានបញ្ញាស្គាល់ពិភពលោក

បើមានធម៌ទី១-២-៣ នេះគ្រប់គ្រាន់ហើយ នៅខ្វះធម៌ទី៤គឺសមជីវិតា មានការចំណាយច្រើនជាងចំណូល ដោយការខ្ជះខ្ជាយ ឬដោយប្រើបុគ្គលិកច្រើនហួស ដែលបណ្ដាមកពីមិនចេះប្រើគឺអំពើដែលគេធ្វើតែម្នាក់កើតយើងធ្វើ៤ឬ៥ នាក់ទើបកើតហើយមិនល្អទៀតឬទិញរបស់មួយមុខៗចូលច្រើនហួសដើម្បីបានភាគរយ អំពីអ្នកលក់ ឯរបស់ដទៃទៀតគ្មានលុយទិញឱ្យគ្រប់គ្រាន់ ដែលនាំឱ្យរអាក់រអួលដំណើរឧស្សាហកម្ម ពាណិជ្ជកម្មនោះ សេដ្ឋកិច្ច ត្រូវធ្លាក់ចុះ ។ កាលបើសេដ្ឋកិច្ចធ្លាក់ចុះព្រោះខ្លួនខ្វះសមត្ថភាព ឬព្រោះខ្លួនទុច្ចរិតហើយ ខំតម្លើងថ្លៃទំនិញដើម្បីទប់ទល់នោះ រឹតតែនាំឱ្យចង្រៃ ធំដល់សង្គមជាតិអ្នកប្រើប្រាស់ថែមទៀត ។

ទិដ្ឋធម្មិកធម៌នេះ មានន័យធំទូលាយគ្រប់ករណីកិច្ចទាំងអស់របស់អ្នកពិភពលោក ដូចបាននាំកូនចំណុចតូចមួយខាងលើនេះ ជានិទស្សនស្រាប់ ។

អំពីសង្គមហាធម៌ គឺធម៌សំរាប់ មនុស្សសង្គ្រោះមនុស្ស ឬ ជាធម៌នាំឱ្យកើតការរាប់រកគ្នារវាងមនុស្សនិងមនុស្សក្នុងពិភពឡើងទៅដរាបមានបញ្ញាចេះដឹងវិជ្ជាដល់ថ្នាក់បណ្ឌិត ( Doctorat )ដែលពិភពលោកសន្មតថាអ្នកប្រាជ្ញបាន ។ ការសិក្សាត្រឹមប៉ុណ្ណោះនៅមិនទាន់ដល់គីរិត បញ្ញាសិក្ខាគឺនៅមិនទាន់ស្គាល់ពិភពលោកច្បាស់លាស គ្រាន់តែបាន ស្គាល់តាមក្បួនរាយរងបន្តិចបន្តួចប៉ុណ្ណោះ ត្រូវសិក្សាបង្កើនថ្នាក់ឱ្យដល់គីរិតបញ្ញាសិក្ខាបានដល់ការសិក្សាតាមមគ្គសច្ចវិទ្យាត្រង់អង្គទី១ និង ទី២ គឺសម្មាទិដ្ឋិ និងសម្មាសង្កប្បៈជាច្រើនឆ្នាំតទៅទៀតដរាបដល់មានបញ្ញាស្គាល់ពិភពលោក

ច្បាស់លាស់ អាចបំបាត់ជាតិជរាព្យាធិមរណៈបាន ។ល។

នេះជាអត្ថន័យសង្ខេបចំពោះធម៌គឺត្រៃសិក្ខា ឯធម៌ដទៃទៀតទាំងអស់ ក៏សុទ្ធតែមានន័យទាក់ទងក្នុងពិភពលោក ចាប់តាំងចំណុចសូន្យឡើងទៅ ដល់មគ្គផលនិព្វានដូចគ្នាទាំងអស់ មិនមែនមានន័យតែខាងបរលោកមួយកំណាត់ដូចមនុស្សមានតែក្បាលឥតដៃជើងឥតដងខ្លួននោះឡើយព្រោះពុទ្ធសាសនាជាទ្រឹស្ដីលោក ។

ត្រង់ចំណុចសំខាន់នេះ អ្នកពិភពលោក មានការយល់ច្រឡំច្រើនគ្នាណាស់ ច្រឡំរហូតដល់មើលងាយពុទ្ធសាសនាថា ជាសាសនានាំមនុស្សឱ្យល្ងង់ ត្រង់ខ្លួនដែលល្ងង់សព្វជាតិ មិនទាំងស្គាល់ពុទ្ធសាសនាជាអ្វីសោះនោះ ថាជាអ្នកប្រាជ្ញទៅវិញ ។

អាស្រ័យហេតុនេះ ពួកមនុស្សដែលល្ងង់ជប់គត់ គ្មានចេះដឹងធម៌វិន័យផ្លូវលោកផ្លូវធម៌ឥតស្គាល់ខុសត្រូវនោះ ពិតជាមិនមែនអ្នកកាន់ពុទ្ធសាសនា មិនមែនអ្នកស្គាល់ពុទ្ធសាសនាឡើយ ទោះបីបានបួសរៀនស្លៀកស្បង់ចីពរហើយ ក៏នៅតែមិនមែនទៀត ព្រោះព្រះពុទ្ធសាសនា ជាឃ្លាំងនៃក្បួនច្បាប់ចំណេះវិជ្ជា សីលធម៌ អារ្យធម៌ វឌ្ឍនធម៌ វប្បធម៌ផង ជាប្រភពបណ្ដុះបណ្ដាលឱ្យកើតវិជ្ជាទាំងឡាយ មានវិទ្យាសាស្ត្រជាដើមផង ដូចមានភ័ស្តុតាង ដែលនិយាយហើយ ក្នុងសៀវភៅនេះស្រាប់ ។

ពុទ្ធសាសនានិងវិទ្យាសាស្ត្រ ដូចបានវែកញែកប្រៀបធៀបបន្តិចមកនេះ បើអនុលោមទៅតាមអ្នកវិទ្យាសាស្ត្រនិយម ( Scientisme ) ឃើញថាពុទ្ធសាសនានិងវិទ្យាសាស្ត្រមានភាពចុះសំរុងគ្នាដោយច្រើន គ្រាន់តែ-

វិទ្យាសាស្ត្រ និយាយមិនដល់ថ្នាក់ខ្ពស់ មិនដល់ខ្លឹមសាររបស់ធម្មជាតិ គឺកម្ម ផលនិងមគ្គផល និព្វានប៉ុណ្ណោះ ទើបវិទ្យាសាស្ត្រ ត្រឡប់កើតជាឧបករណ៍ សំរាប់បំពេញបំប៉នកាមគុណ បណ្ដុះបណ្ដាល រាគៈ លោភៈ ទោសៈ មោហៈ ឱ្យកាន់តែធាត់ធំ កាន់តែសាហាវឡើង ទាំងឱ្យពិភពលោកកាន់តែវឹកវរ មិន បានសុខស្ងប់ ។

បើអ្នកវិទ្យាសាស្ត្រ យកទ្រឹស្ដីពុទ្ធសាសនាតែបន្តិចគឺយកមនុស្សធម៌ បានដល់សីល៥ ដែលជានិច្ចសីលនោះ ទៅបញ្ចូលក្នុងទ្រឹស្ដីខ្លួន ហើយនាំ គ្នាអនុវត្តតាមឱ្យបានពិតប្រាកដ វិទ្យាសាស្ត្រ និងក្លាយទៅជាវត្ថុទិព្វ សំរាប់ ពិភពលោកមិនខាន ព្រោះមានភាព និងមានបឋមវិធានស្របនឹងពុទ្ធ សាសនាដែរ ។

**(ចប់ដោយសង្ខេប)**

# បញ្ជីអត្ថបទ


| | | |
|---|---|---|
| ពុទ្ធសាសនាគឺអ្វី ? | ទំព័រ | ១ |
| ពុទ្ធសាសនាមានលក្ខណៈពិសេសបីយ៉ាង | - | ៦ |
| ពុទ្ធសាសនានៅប្រទេសកម្ពុជា | - | ១៩ |
| ពុទ្ធសាសនាជាសាសនារបស់រដ្ឋ | - | ៣៧ |
| វត្តនិងអង្គការអក្សរសាស្ត្រជាដើម | - | ៤០ |
| អំពីវិទ្យាសាស្ត្រ | - | ៦២ |
| ដើមកំណើតវិទ្យាសាស្ត្រ | - | ៦៥ |
| អំពីទស្សនវិជ្ជា និង តក្កវិជ្ជា | - | ៧១ |
| ប្រភេទ នៃទស្សនវិជ្ជា | - | ៧៤ |
| អំពីលោកិយទស្សនវិជ្ជា | - | ៧៤ |
| អំពីលោកុត្តរ ទស្សនវិជ្ជា | - | ៨៨ |
| ការវែកញែកពុទ្ធសាសនា និងវិទ្យាសាស្ត្រ | - | ៩២ |